សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Économiques
Royal University of law and Economics

# សារណាបញ្ចប់ការសិក្សា

# ការដោះស្រាយវិវាទអគារសហកម្មសិទ្ធិនៅកម្ពុជា

ស្រាវជ្រាវចាប់ពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ **ម៉ូរី ទេវោហា**
**គួ បូរមី**

សាស្ត្រាចារ្យណែនាំ
បណ្ឌិត **ព្រុំ រិទ្ធី**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី២០

ឆ្នាំចូលសិក្សា ២០១៦
ឆ្នាំសរសេរសារណា ២០២០

# សេចក្តីថ្លែងអំណរគុណ

សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រមួយនេះ គឺជាសក្ខីភាពបង្ហាញឱ្យឃើញពីកិច្ចខិតខំប្រឹងប្រែងដោយស្មារតីសាមគ្គីភាព និងផ្អែកលើសមត្ថភាពនៃការសិក្សាស្រាវជ្រាវជាគោល។ លទ្ធផលដ៏វិសេសវិសាលបែបនេះ អាចកើតឡើងបាន ក៏អាស្រ័យដោយមានការចូលរួមចំណែកពីគ្រប់មជ្ឈដ្ឋានទាំងអស់។

អាស្រ័យហេតុនេះ យើងខ្ញុំទាំងពីររូប សូមគោរព និងដឹងគុណចំពោះអ្នកមានគុណទាំងពីរ ដែលបានផ្តល់កំណើត និងយកចិត្តទុកដាក់ចិញ្ចឹមបីបាច់ថែរក្សាដោយផ្តល់ភាពកក់ក្តៅ សេចក្តីស្រឡាញ់ និងអប់រំទូន្មានប្រៀនប្រដៅកូនប្រកបដោយព្រហ្មវិហារធម៌ ឱ្យកូនប្រព្រឹត្តខ្លួនតាមគន្លងល្អៗ រហូតដល់ពេលនេះ ដែលធ្វើឱ្យរូបកូនក្លាយទៅជាបញ្ញាវ័ន្តពោរពេញទៅដោយចំណេះដឹង ដែលសង្គមត្រូវការ ។

យើងខ្ញុំទាំងពីររូប សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ **ឯកឧត្តមសាកលវិទ្យាធិការ** ដែលបានផ្តល់លទ្ធផលឱ្យយើងខ្ញុំបានបន្តការសិក្សាក្នុងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ លើសពីនេះទៅទៀតបានផ្តល់ឱកាសដល់យើងខ្ញុំទាំងពីររូប អាចចូលរួមសរសេរសារណាបញ្ចប់ឆ្នាំសិក្សាថ្នាក់បរិញ្ញាបត្រនេះ។

ទន្ទឹមនឹងនេះយើងខ្ញុំ ក៏សូមធ្វើការថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះសាស្ត្រាចារ្យ **បណ្ឌិត ព្រុំ រិទ្ធី** ដែលលោក បានចំណាយពេលវេលាយ៉ាងមានតម្លៃខិតខំពន្យល់ ណែនាំ ចែករំលែកបទពិសោធន៍ល្អៗ ជួយកែសម្រួលសព្វបែបយ៉ាងក្នុងអត្ថបទនេះដើម្បីជួយជំរុញឱ្យសារណារបស់យើងខ្ញុំសម្រេចចេញជាផ្លែផ្កា។

ជាទីបញ្ចប់នេះ យើងខ្ញុំទាំងពីររូប គ្មានអ្វីក្រៅពីលើកម្រាមដៃទាំងដប់ គោរព និង ជូនពរ បវរមហាប្រសើរគោរពជូន លោកអ្នកមានគុណ និងថ្នាក់ដឹកនាំ លោក លោកស្រី សាស្ត្រាចារ្យ និងមិត្តភក្តិទាំងអស់ ឱ្យទទួលបាននូវអាយុយឺនយូរ សុខភាពល្អ សុភមង្គល និងភាពចម្រុងចម្រើន ជោគជ័យគ្រប់ភារកិច្ចជានិរន្តរ៍។

# អារម្ភកថា

ក្រោយពីបានសិក្សារៀនសូត្រ និងទទួលការបណ្តុះបណ្តាលនៅក្នុង **សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ដែលជាគ្រឹះស្ថានអប់រំសាធារណៈរបស់រដ្ឋ អស់រយៈពេល៤ឆ្នាំ។ នៅក្នុងសាកលវិទ្យាល័យនេះ គឺពិតជាស្ថាប័នបណ្តុះបណ្តាលថ្នាក់ឧត្តមសិក្សាមួយដ៏គួរឱ្យចាប់អារម្មណ៍ ព្រោះសម្បូរទៅដោយសាស្ត្រាចារ្យល្បីៗ ដែលមានបទពិសោធន៍គ្រប់គ្រាន់ក្នុងការបង្ហាត់បង្រៀន និងណែនាំនិស្សិតឱ្យយល់ច្បាស់ពីជំនាញ ដែលសិស្សនិស្សិតបានជ្រើសរើសយកមកសិក្សា ក្នុងនោះដែរ ចំពោះជំនាញដែលយើងខ្ញុំទាំងពីរបានជ្រើសរើសយកមកសិក្សានោះ គឺបរិញ្ញាបត្រនីតិសាស្ត្រ។

ក្នុងការសិក្សាថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច យើងខ្ញុំទាំងពីរពិតជាមានសេចក្តីសោមនស្សរីករាយជាខ្លាំង ដោយទទួលបាននូវពុទ្ធិជាច្រើន ទាំងផ្នែកទ្រឹស្តី និងការអនុវត្តនៅក្នុងផ្នែកនេះ។ ដោយចំណេះដឹងដែលទទួលបាននេះហើយ ក៏បានជំរុញឱ្យ ពួកយើងខ្ញុំធ្វើការសម្រេចចិត្តជ្រើសរើសយកការសរសេរសារណាបញ្ចប់ការសិក្សានេះឡើង ដោយកំណត់យកប្រធានបទ "**ការដោះស្រាយវិវាទអគារសហកម្មសិទ្ធិនៅកម្ពុជា**" នេះមកធ្វើជាប្រធានបទក្នុងការស្រាវជ្រាវ ដើម្បីធ្វើជាជំនួយស្មារតី ក៏ដូចជាឯកសារសិក្សាបន្ថែមសម្រាប់និស្សិតជំនាន់ក្រោយ អ្នកស្រាវជ្រាវ ឬអ្នកដែលចង់ស្វែងយល់ពីយន្តការក្នុងការដោះស្រាយរាល់វិវាទនានានៃអគារសហកម្មសិទ្ធិក្រៅប្រព័ន្ធតុលាការ និងនីតិវិធីដោះស្រាយវិវាទក្នុងប្រព័ន្ធតុលាការ។ ដោយសារតែនៅប្រទេសកម្ពុជា ចំនួននៃអគារសហកម្មសិទ្ធិមានការកើនឡើងរីកដុះដាលជាខ្លាំង ប្រជាពលរដ្ឋក៏រស់នៅច្រើន ម្ល៉ោះហើយក្នុងជីវភាពរស់នៅប្រចាំ ប្រាកដជាលេចឡើងនូវវិវាទតូច-ធំមួយចំនួនពាក់ព័ន្ធនឹងបញ្ហាអគារសហកម្មសិទ្ធិនេះផងដែរ។

យ៉ាងណាមិញការស្រាវជ្រាវលើប្រធានបទនេះ គឺនៅមានចំនុចខ្វះចន្លោះ ទាំងពាក្យពេចន៍ និងអត្ថន័យ អាស្រ័យហេតុនេះ សូមលោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យ សិស្សនិស្សិត និងមិត្តអ្នកអានទាំងអស់ មេត្តាខន្តីអភ័យទោសដល់ការស្រាវជ្រាវរបស់ក្រុមយើងខ្ញុំផង ហើយក្រុមយើងខ្ញុំមានសេចក្តីរីករាយយ៉ាងក្រៃលែង ក្នុងទទួលយកការរិះគន់ក្នុងន័យស្ថាបនាពីសំណាក់ លោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យ សិស្សនិស្សិត និងមិត្តអ្នកអានទាំងអស់ ដើម្បីរួមចំណែកក្នុងការកែលម្អកិច្ចការស្រាវជ្រាវមួយយនេះឱ្យមានភាពល្អប្រសើរ៕

# មាតិកា

**ទំព័រ**


**សេចក្តីផ្តើម**..................................................................................................០១

**១. លំនាំបញ្ហានៃការស្រាវជ្រាវ** ....................................................................... ០១

**២. ចំណោទបញ្ហានៃការស្រាវជ្រាវ** ..................................................................... ០១

**៣. គោលបំណងនៃការស្រាវជ្រាវ**.......................................................................... ០២

**៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ**............................................................. ០២

**៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ** .................................................................. ០២

**៦. វិធីសាស្ត្រស្រាវជ្រាវ**.......................................................................................០៣

**៧. រចនាសម្ពន្ធនៃការស្រាវជ្រាវ** ...........................................................................០៣


## ជំពូកទី១

## វិវាទអគារសហកម្មសិទ្ធិ


**១.១. ការមិនអនុវត្តករណីយកិច្ចតាមកិច្ចសន្យា**.............................................................. ០៤

**១.២. ការមិនគោរពបទបញ្ជាផ្ទៃក្នុងសម្រាប់អគារសហកម្មសិទ្ធិ**............................................ ០៥

**១.៣. ការថយចុះនៃគុណភាពសំណង់** ......................................................................... ០៦

**១.៤. ការធ្វើសកម្មភាពពាក់ព័ន្ធនឹងសំណង់** ................................................................ ០៧

**១.៥. ការរំលោភបំពានសិទ្ធិអ្នកជិតខាង** ..................................................................... ០៨


## ជំពូកទី២

## នីតិវិធីដោះស្រាយវិវាទអគារសហកម្មសិទ្ធិក្រៅប្រព័ន្ធតុលាការ


**២.១. ការដោះស្រាយវិវាទអគារសហកម្មសិទ្ធិដោយភាគី**................................................. ១០

២.១.១. ការចរចា.............................................................................................. ១១

២.១.២. ដំណើរការនៃការចរចា ............................................................................ ១១

២.១.២.១. ដំណាក់កាលត្រៀម ............................................................................ ១១

២.១.២.២. ដំណាក់កាលចាប់ផ្តើម.......................................................................... ១២

២.១.២.៣. ដំណាក់កាលបញ្ចប់ ............................................................................ ១២

២.១.៣. វិធីសាស្ត្រជាមូលដ្ឋាននៃការចរចា ...........................................................១៣

២.១.៣.១. ការចរចាបែបបែងចែក ........ ១៣
២.១.៣.២. ការចរចាផ្អែកលើផលប្រយោជន៍ ........ ១៤
**២.២. ការដោះស្រាយវិវាទអគារសហកម្មសិទ្ធិដោយមានអ្នកសម្របសម្រួល** ........ ១៥
២.២.១. ការសម្របសម្រួល ........ ១៥
២.២.២. បុគ្គលដែលអាចក្លាយជាអ្នកសម្របសម្រួល ........ ១៦
២.២.៣. តួនាទីរបស់អ្នកសម្របសម្រួល ........ ១៩
២.២.៤. ដំណើរការនៃការសម្របសម្រួល ........ ១៩
២.២.៤.១. ដំណាក់កាលត្រៀម ........ ១៩
២.២.៤.២. ដំណាក់កាលចាប់ផ្តើម ........ ២០
២.២.៤.៣. ដំណាក់កាលបញ្ចប់ ........ ២១

## ជំពូកទី៣

## នីតិវិធីដោះស្រាយវិវាទអគារសហកម្មសិទ្ធិក្នុងប្រព័ន្ធតុលាការ

**៣.១. ប្រធាននៃបណ្តឹង** ........ ២៣
៣.១.១. សមត្ថកិច្ចតុលាការ ........ ២៣
៣.១.២. ភាគី ........ ២៤
៣.១.៣. អ្នកតំណាង ........ ២៥
**៣.២. អំពីបណ្តឹងរដ្ឋប្បវេណី** ........ ២៥
៣.២.១. អត្ថន័យនៃបណ្តឹងរដ្ឋប្បវេណី ........ ២៥
៣.២.២. នីតិវិធីនៃការដាក់ពាក្យបណ្តឹង ........ ២៦
៣.២.២.១. ចំណុចដែលត្រូវសរសេរក្នុងពាក្យបណ្តឹង ........ ២៦
៣.២.២.២. របៀបនៃការដាក់ពាក្យបណ្តឹង ........ ២៦
៣.២.៣. ការកំណត់កាលបរិច្ឆេទនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកដំបូង ........ ២៧
**៣.៣. ការជំនុំជម្រះលើបណ្តឹងរដ្ឋប្បវេណី** ........ ២៧
៣.៣.១. នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកដំបូង ........ ២៧
៣.៣.១.១. អត្ថន័យ ........ ២៧
៣.៣.១.២. សកម្មភាពក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ........ ២៨

៣.៣.១.៣. ការបញ្ចប់នីតិវិធីត្រៀមទាញហេតុផល ............................................................ ២៩
៣.៣.២. នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ............................................................ ២៩
៣.៣.២.១. អត្ថន័យ ............................................................ ២៩
៣.៣.២.២. ដំណើរការនៃការទាញហេតុផលដោយផ្ទាល់មាត់ ............................................................ ២៩
៣.៣.២.៣. ការបញ្ចប់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ............................................................ ៣១
**សេចក្ដីសន្និដ្ឋាន** ............................................................ ៣២
**អនុសាសន៍** ............................................................ ៣៣
**គន្ថនិទ្ទេស**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

របបសង្គមខ្មែរមានការផ្លាស់ប្រែជាច្រើនសម័យកាល ក្នុងនោះសង្កេតឃើញថាសម័យអភិវឌ្ឍដែលត្រូវបានពិភពលោកទទួលស្គាល់ និងបន្សល់បាននូវសមិទ្ធផលជាផ្លែផ្កាវិជ្ជមាននោះគឺ សម័យព្រះរាជាណាចក្រកម្ពុជាទី២ រាប់ចាប់ពីឆ្នាំ១៩៩៣ បាននាំមកនូវវឌ្ឍនភាពទាំងវិស័យនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។ ដំណើរបោះជំហានទៅមុខមិនឈប់ឈរនេះ ក៏ដោយសារមានគោលនយោបាយដ៏ឈ្លាសវៃ និងត្រឹមត្រូវបំផុតរបស់រាជរដ្ឋាភិបាលកម្ពុជាជាត្រីវិស័យតម្រង់ទិសងាកឆ្ពោះទៅរកកំណែទម្រង់ស៊ីជម្រៅ និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ក្រោមគោលនយោបាយបើកជំហរជើងមេឃដើម្បីបង្កើតបាននូវវប្បធម៌សន្តិភាព ក្រោមស្មារតីសាកលភាវូបនីយកម្មជាមួយបណ្តាប្រទេសនានា ទាំងក្នុងតំបន់ និងសកលលោកទាំងមូល។ កត្តាទាំងនេះហើយ បានធ្វើឱ្យគ្រប់វិស័យនៃសង្គមមានការរីកចម្រើន សូម្បីតែវិស័យអចលនទ្រព្យ ពិសេសអគារសហកម្មសិទ្ធិមានដូចជាភូមិគ្រឹះ ពាក់កណ្តាលភូមិគ្រឹះ ផ្ទះល្វែងដែលមានច្រើនល្វែង ឬច្រើនជាន់ជាប់គ្នា ខុនដូ ប្រភេទផ្ទះផ្សេងទៀតដែលមានរចនាសម្ពន្ធជាប់គ្នាក៏រីកដុសដាលខ្លាំង តាំងពីបណ្តាខេត្តនានា រហូតជ្រៀតចូលស្ទើរពាសពេញរាជធានីភ្នំពេញតែម្តង។

កំណើននៃអគារសហកម្មសិទ្ធិ ស្របពេលដែលប្រជាពលរដ្ឋមួយចំនួនមានការផ្លាស់ប្រែរបៀបរបបក្នុងការរស់តាមបែបទំនើបទាន់សម័យ ក៏ដូចជាកត្តាលទ្ធភាពសេដ្ឋកិច្ចជាដើម ខណៈដែលប្រជាពលរដ្ឋមួយភាគតូចពុំទាន់អាចសម្របខ្លួនជាមួយនឹងបរិយាកាសនៃការរស់នៅបែបថ្មី ជាលក្ខណៈសហកម្មសិទ្ធិនេះ ទើបបណ្តាលឱ្យកើតឡើងនូវវិវាទមួយចំនួនក្នុងអគារសហកម្មសិទ្ធិ ដែលភាគច្រើនរវាងសហកម្មសិទ្ធិករនិងសហកម្មសិទ្ធិករ សហកម្មសិទ្ធិករនិងអ្នកអភិវឌ្ឍអចលនវត្ថុ សហកម្មសិទ្ធិនិងអង្គការគ្រប់គ្រងក្នុងអគារសហសិទ្ធិ។

ដោយមើលឃើញពីការកើនឡើងនៃអគារសហកម្មសិទ្ធិ រួមជាមួយនឹងវិវាទដែលកើតមានជារឿយៗ ទើបយើងខ្ញុំលើកយកប្រធានបទ "**ការដោះស្រាយវិវាទអគារសហកម្មសិទ្ធិនៅកម្ពុជា**" មកធ្វើជាកម្មវត្ថុនៃការសិក្សាស្រាវជ្រាវបញ្ចប់ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រនេះ។ ឯកសារបានរំលេចឡើងនូវយន្តការដោះស្រាយតាមពីររបៀបគឺ ដំណោះស្រាយក្នុងប្រព័ន្ធតុលាការ និងដំណោះស្រាយក្រៅប្រព័ន្ធតុលាការ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

វិវាទនៃអគារសហកម្មសិទ្ធិកើតឡើងច្រើនរូបភាព ក្រោមមូលហេតុផ្សេងៗគ្នា។ បញ្ហាវិវាទទាំងនេះ ក៏បានក្លាយជាប្រធានបទដ៏សំខាន់សម្រាប់អ្នកសិក្សាស្រាវជ្រាវយកមកធ្វើជាមូលដ្ឋានក្នុងការពិចារណា ដើម្បីស្វែងរកនូវដំណោះស្រាយជាធាតុចូលក្នុងការអនុវត្តលើវិវាទអគារសហកម្មសិទ្ធិនេះ។ ដូច្នេះក្នុងករណីដែលវិវាទអគារសហកម្មសិទ្ធិកើតឡើង តើមានមធ្យោបាយយ៉ាងដូចម្តេចខ្លះ ដើម្បីបញ្ចប់វិវាទ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រធានបទ "ការដោះស្រាយវិវាទអគារសហកម្មសិទ្ធិនៅកម្ពុជា" មានគោលបំណងសំខាន់ៗ ចំនួន៣ រួមមាន៖ (១) ការចង់សិក្សាស្វែងយល់ឱ្យបានស៊ីជម្រៅជុំវិញបញ្ហាវិវាទអគារសហកម្មសិទ្ធិនៅកម្ពុជា ដោយផ្អែកលើដំណោះស្រាយដែលមានស្រាប់ ដែលបាននឹងកំពុងតែអនុវត្តសព្វថ្ងៃនេះ។ (២) ស្វែងរកគោលគំនិតជាអាទិភាព ដើម្បីបំពេញបន្ថែមលើយន្តការដោះស្រាយដែលកំពុងអនុវត្តបច្ចុប្បន្ន និងធានាបាននូវប្រសិទ្ធភាព ប្រសិទ្ធផលក្នុងការកាត់បន្ថយ និងឈានទៅដល់ការលុបបំបាត់រាល់វិវាទនៃអគារសហកម្មសិទ្ធិនៅកម្ពុជា។ (៣) បន្សល់ទុកជាឯកសារ ឬជាលំនាំស្រាវជ្រាវសម្រាប់អ្នកសិក្សាបន្តវេនយកទៅកែកុនបំពេញបន្ថែមឱ្យស្របនឹងស្ថានភាពជាក់ស្តែងនៃការអភិវឌ្ឍសង្គម។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ដែនកំណត់នៃការស្រាវជ្រាវក្នុងប្រធានបទនេះ គឺផ្តោតសំខាន់ទៅលើទ្រឹស្តីនៃការដោះស្រាយវិវាទដែលបានកំណត់ក្នុងក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ សម្រាប់ដោះស្រាយវិវាទក្នុងប្រព័ន្ធតុលាការ ដោយលើកត្រឹមតែនីតិវិធីជំនុំជម្រះលើបណ្តឹងរដ្ឋប្បវេណីលើកទី១ក្នុងសាលាដំបូងតែប៉ុណ្ណោះ។ ចំណែកការដោះស្រាយក្រៅប្រព័ន្ធតុលាការផ្អែកលើមូលដ្ឋានដែលបានលើកឡើងក្នុងសៀវភៅគោលរបស់អង្គការដែលជាអង្គការក្រៅរដ្ឋាភិបាល និងអ្នកជំនាញផ្នែកច្បាប់បានបកស្រាយយ៉ាងលម្អិតលើបញ្ហានេះ។ ចំពោះអាជ្ញាធរដែនដី ដូចជា រដ្ឋបាលភូមិ ឃុំ សង្កាត់ ស្រុក ខណ្ឌ ខេត្ត ក្រុង រាជធានី ដែលច្បាប់បានផ្តល់សិទ្ធិជាអ្នកសម្របសម្រួលវិវាទជូនប្រជាពលរដ្ឋត្រង់ចំណុចនេះមិនធ្វើការលើកឡើងទាំងអស់នោះទេ ដោយលើកយកតែរដ្ឋបាលឃុំ សង្កាត់ មកធ្វើការបកស្រាយក្នុងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។ ជាមួយគ្នានេះ ការលើកយកពីមូលហេតុនៃវិវាទអគារសហកម្មសិទ្ធិ និងដំណោះស្រាយ ចំពោះអគារសហកម្មសិទ្ធិដែលកើតមានឡើងក្រោយការចូលជាធរមានរបស់អនុក្រឹត្យស្តីពីការគ្រប់គ្រងនិងប្រើប្រាស់អគារសហកម្មសិទ្ធិឆ្នាំ២០០៩។ ចំពោះមូលហេតុនេះទៀតសោត គិតត្រឹមតែវិវាទទាំងឡាយណាដែលមាននៅក្នុងអគារសហកម្មសិទ្ធិ មិនមែនជាវិវាទជាមួយប្រជាពលរដ្ឋដែលនៅក្បែរអគារនោះទេ ព្រមទាំងមិនលើកឡើងអំពីជនបរទេសដែលមានសិទ្ធិលើអគារសហកម្មសិទ្ធិនោះទេ។ ឯកសារទាំងនេះឆ្លុះបញ្ចាំងពីយន្តការដោះស្រាយលើករណីវិវាទអគារសហកម្មសិទ្ធិដែលស្ថិតក្នុងបរិបទកម្ពុជា។

## ៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រធានបទ "ការដោះស្រាយវិវាទអគារសហកម្មសិទ្ធិនៅកម្ពុជា" មានសារៈសំខាន់ចំនួន២ រួមមាន៖ (១) ជាមេរៀន និងបទពិសោធ ដើម្បីបង្ការ និងទប់ស្កាត់ ដើម្បីកុំឱ្យមានវិវាទនេះ កើតមានឡើងព្រោះថា សារណានេះ បានបង្ហាញឱ្យឃើញអំពីមូលហេតុនៃវិវាទអគារសហកម្មសិទ្ធិ ដែលកើតឡើងរវាងគូភាគីទាំងបីប្រភេទដូចដែលបានលើកឡើង។ (២) ផ្តល់ចំណេះដឹងក្នុងការដោះស្រាយវិវាទអគារសហកម្មសិទ្ធិ ដោយ

បង្ហាញអំពីមធ្យោបាយដោះស្រាយវិវាទ ទាំងក្រៅប្រព័ន្ធ និងក្នុងប្រព័ន្ធតុលាការ ដែលក្នុងនោះ មធ្យោបាយទី១ គឺការដោះស្រាយវិវាទអគារសកម្មសិទ្ធិក្រៅប្រព័ន្ធតុលាការ ក៏បានបង្ហាញអំពីវិធីក្នុងដោះស្រាយវិវាទរួមមាន របៀបនៃការចរចា និងរបៀបនៃការសម្របសម្រួល សម្រាប់ភាគីនៃវិវាទប្រើប្រាស់វិធីសាស្ត្រទាំងនេះ ឱ្យអស់លទ្ធភាពជាមុនសិន ចាំឈានទៅដល់ការប្តឹងទៅតុលាការ។ ដោយឡែកមធ្យោបាយទី២ គឺការដោះស្រាយវិវាទអគារសហកម្មសិទ្ធិក្នុងប្រព័ន្ធតុលាការ បង្ហាញឱ្យឃើញពីនីតិវិធីរបស់តុលាការក្នុងការដោះស្រាយវិវាទ។

## ៦. វិធីសាស្ត្រស្រាវជ្រាវ

ការស្រាវជ្រាវសរសេរសារណាបញ្ចប់ការសិក្សានេះ ដោយការសិក្សាស្វែងយល់ពីប្រធានបទ និងបានប្រមូលឯកសារតាមវិធីសាស្ត្រមួយចំនួនដូចជា ការស្រាវជ្រាវលើប្រធានបទ គឺផ្អែកទៅលើទ្រឹស្តីដែលមានចែងក្នុងច្បាប់ និងបទដ្ឋានគតិយុត្តនានា រួមទាំងសៀវភៅមេរៀន ដែលពាក់ព័ន្ធនឹងអគារសហកម្មសិទ្ធិ។ ការស្វែងរកឯកសារ និងទិន្នន័យធ្វើឡើងតាមរយៈបណ្ណាល័យ និងការស្រាវជ្រាវតាមរយៈអ៊ិនធឺណែត ពីគេហទំព័រផ្សេងៗដែលពាក់ព័ន្ធនឹងប្រធានបទ។

## ៧. រចនាសម្ពន្ធនៃការស្រាវជ្រាវ

សារណាបញ្ចប់ការសិក្សាក្រោមប្រធានបទ "ការដោះស្រាយវិវាទអគារសហកម្មសិទ្ធិនៅកម្ពុជា" គឺចែកចេញជា៣ជំពូក។ ក្នុងនោះជំពូកទី១ រៀបរាប់អំពីមូលហេតុចម្បងៗដែលនាំឱ្យកើតមានឡើងវិវាទនៃអគារសហកម្មសិទ្ធិ។ ជំពូកទី២ ពិភាក្សាពីការដោះស្រាយវិវាទអគារសហកម្មសិទ្ធិដោយស្ម័គ្រចិត្ត រួមមាន យន្តការចរចា និងយន្តការក្នុងការសម្របសម្រួល ដើម្បីបញ្ចប់វិវាទដោយមិនចាំបាច់មានសេចក្តីសម្រេចពីតុលាការ។ ជំពូកទី៣ បង្ហាញអំពីការដោះស្រាយវិវាទដោយបង្ខំ នៅក្នុងប្រព័ន្ធតុលាការកម្ពុជា ដោយតុលាការដោះស្រាយវិវាទអគារសហកម្មសិទ្ធិផ្អែកលើនីតិវិធីនៃការជំនុំជម្រះលើកទី១ រួមមាន អំពីបណ្តឹងរដ្ឋប្បវេណី ការចាត់ចែងបណ្តឹង ការជំនុំជម្រះលើបណ្តឹងរដ្ឋប្បវេណី។ ផ្នែកចុងក្រោយនៃសារណាបញ្ចប់ការសិក្សានេះ ក៏បានរៀបចំឱ្យមានសេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍ដែលជាគំនិតរួមចំណែកក្នុងការកែទម្រង់ បង្ការការកើតឡើងនៃវិវាទ និងផ្តល់គោលការណ៍ជាមូលដ្ឋានផ្អែកច្បាប់ក្នុងការដោះស្រាយចំពោះមូលហេតុនៃវិវាទអគារសហកម្មសិទ្ធិមួយចំនួនផងដែរ។

# ជំពូកទី១
# វិវាទអគារសហកម្មសិទ្ធិ

កំណើននៃការអភិវឌ្ឍសេដ្ឋកិច្ច និងកំណើននៃប្រជាជន បាននាំមកនូវសំណង់អគារជាច្រើនពាសពេញផ្ទៃប្រទេស ពិសេសអគារសហកម្មសិទ្ធិ។ ក្នុងនោះដែរ អគារសហកម្មសិទ្ធិកំពុងតែជាទីចាប់អារម្មណ៍ពីសំណាក់ប្រជាពលរដ្ឋមួយចំនួន ដោយសារតែអគារសហកម្មសិទ្ធិបង្កភាពលក្ខណៈងាយស្រួល និងផាសុខភាព ក្នុងការរស់នៅប្រកបដោយភាពស៊ីវិល័យ។ ប៉ុន្តែប្រសិនក្រឡេកមើលម្ខាងទៀត អគារសហកម្មសិទ្ធិមិនប្រាកដថាគ្មានលេចឡើងនូវបញ្ហាវិវាទក្នុងជីវភាពរស់នៅ និងទំនាក់ទំនងអគារសហកម្មសិទ្ធិនោះទេ ដោយវិវាទទាំងឡាយអាចកើតឡើងពី សហកម្មសិទ្ធិករ អ្នកអភិវឌ្ឍអចលនវត្ថុ និងក្រុមប្រឹក្សាភិបាល ឬគណៈកម្មការគ្រប់គ្រងអគារសហកម្មសិទ្ធិ ដែលជាបុគ្គលបង្កឱ្យមានវិវាទកើតឡើង ហើយក៏ជាភាគីនៃវិវាទអគារសហកម្មសិទ្ធិ។ ដូចនេះក្នុងជំពូកនេះនឹងធ្វើការបកស្រាយទៅមូលហេតុនៃវាទអគារសហកម្មសិទ្ធិមួយចំនួនរួមមាន ១.១. ការមិនអនុវត្តករណីយកិច្ចតាមកិច្ចសន្យាលក់ទិញអគារសហកម្មសិទ្ធិ ១.២. ការមិនគោរពបទបញ្ជាផ្ទៃក្នុងអគារសហកម្មសិទ្ធិ ១.៣. ការថយចុះនៃគុណភាពសំណង់ ១.៤. ការធ្វើសកម្មភាពនៃសំណង់ ១.៥. ការលោភបំពានសិទ្ធិអ្នកជិតខាង។

## ១.១. ការមិនអនុវត្តករណីយកិច្ចតាមកិច្ចសន្យា

នៅពេលដែលបង្កើតកិច្ចសន្យាលក់ទិញអគារសហកម្មសិទ្ធិ នោះអ្នកអភិវឌ្ឍអចលនវត្ថុដែលជាអ្នកលក់ត្រូវមានករណីយកិច្ចសំខាន់គឺផ្ទេរកម្មសិទ្ធិ និងសិទ្ធិផ្សេងទៀតលើអគារសហកម្មសិទ្ធិ ឱ្យទៅសហកម្មសិទ្ធិករ ហើយសហកម្មសិទ្ធិករដែលជាអ្នកទិញត្រូវអនុវត្តករណីយកិច្ចបង់ថ្លៃជាប្រាក់ឱ្យទៅអ្នកអភិវឌ្ឍអចលនវត្ថុ។[1] មិនត្រឹមតែប៉ុណ្ណោះ ភាគីនៃកិច្ចសន្យាក៏អាចកំណត់ករណីយកិច្ច និងលក្ខខណ្ឌមួយចំនួនផ្សេងៗទៀត ដែលមាននៅក្នុងកិច្ចសន្យាលក់ទិញ អាស្រ័យលើការព្រមព្រៀងគ្នា និងតម្រូវការចាំបាច់របស់ភាគីនីមួយៗ។

នៅក្នុងករណីខ្លះ អ្នកអភិវឌ្ឍអចលនវត្ថុដែលជាអ្នកលក់មិនអាចអនុវត្តករណីយកិច្ចមួយចំនួនដូចជាផ្ទេរសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិដែលខ្លួនបានលក់ និងករណីយកិច្ចប្រគល់កម្មវត្ថុនៃកិច្ចសន្យាដែលបានលក់ ព្រមទាំងមិនអាចថែរក្សាកម្មវត្ថុដែលបានលក់រហូតដល់ពេលប្រគល់ទៅឱ្យសហកម្មសិទ្ធិករដែលជាអ្នកទិញ តាមការកំណត់ក្នុងកិច្ចសន្យាបានឡើយ។ តួយ៉ាងនៅពេលដែលដល់កាលបរិច្ឆេទអនុវត្ត ដែលត្រូវប្រគល់ចំណែកឯកជនឱ្យសហកម្មសិទ្ធិករចូលរស់នៅហើយ តែបែរជាអ្នកអភិវឌ្ឍអចលនវត្ថុមិនអាចប្រគល់ចំណែកឯកជនបាន ដោយសារតែអគារសហកម្មសិទ្ធិសាងសង់មិនទាន់រួចជាស្ថាពរ ឬម្យ៉ាងទៀតមិនទាន់ដល់កាលបរិច្ឆេទអនុវត្តប្រគល់ផ្ទះទេ ស្រាប់តែអ្នកអភិវឌ្ឍអចលនវត្ថុធនក្ស័យ មិនអាចដំណើរការសាងសង់អគារបានទៀត។ ចំណែកឯករណីមួយចំនួនទៀត អគារសហកម្មសិទ្ធិសាងសង់រួចរាល់ជាស្ថាពរហើយ នៅពេល

[1] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៥១៥ (ពីពេលនេះតទៅ ហៅថាក្រមរដ្ឋប្បវេណីឆ្នាំ២០០៧)។

ដែលប្រគល់ចំណែកឯកជននៃអគារសហកម្មសិទ្ធិឱ្យទៅសហកម្មសិទ្ធិករ បែរជាអ្នកអភិវឌ្ឍអចលនវត្ថុធ្វើខុសនឹងករណីយកិច្ចក្នុងការធានាវត្ថុដែលគ្មានវិការៈ [2] ដោយអ្នកអភិវឌ្ឍអចលនវត្ថុបានប្រគល់នូវចំណែកឯកជនមានភាពមិនស្របគំរូប្លង់ដែលបានកំណត់ក្នុងកិច្ចសន្យា ជាស្តែងដូចជា នៅក្នុងគំរូប្លង់បង្ហាញថា ក្នុងចំណែកឯកជននៃអគារសហកម្មសិទ្ធិ រួមមានទូរដាក់សម្ភារៈផ្ទះបាយ ម៉ាស៊ីនត្រជាក់ និងសម្ភារៈប្រើប្រាស់មួយចំនួនទៀត នៅពេលដែលសហកម្មសិទ្ធិករពិនិត្យក្នុងចំណែកឯកជនរបស់ខ្លួន រកមានការខ្វះខាត់នូវសម្ភារៈខាងលើ។

ចំពោះសហកម្មសិទ្ធិករដែលជាអ្នកទិញ មិនអាចអនុវត្តករណីកិច្ចបង់ថ្លៃទិញជាប្រាក់ នៅពេលដែលកាលបរិច្ឆេទក្នុងការអនុវត្តមកដល់ តាមការកំណត់ក្នុងកិច្ចសន្យា ទោះបីជាការទិញនោះដោយបង់រំលោះ ឬទិញបង់ផ្តាច់ក្តី។ មួយវិញទៀត សហកម្មសិទ្ធិមានភាពយឺតយ៉ាវក្នុងការអនុវត្តករណីយកិច្ចបង់ថ្លៃទិញ ទៅឱ្យអ្នកអភិវឌ្ឍអចលនវត្ថុតាមកាលបរិច្ឆេទដែលបានកំណត់ក្នុងកិច្ចសន្យា ក្នុងករណីដែលសហកម្មសិទ្ធិបានទទួលការប្រគល់ចំណែកឯកជននៃអគារសហកម្មសិទ្ធិរួចរាល់ហើយ។

ជារួមមក មានស្ថានភាពជាច្រើនបណ្តាលដែលឱ្យមានវិវាទដែលកើតឡើងដោយសារការមិនអនុវត្តករណីកិច្ចក្នុងកិច្ចសន្យាទិញលក់អគារសហកម្មសិទ្ធិ។ ក្នុងស្ថានភាពជាច្រើននេះ កត្តាសំខាន់ៗមួយចំនួនដែលធ្វើឱ្យអ្នកអភិវឌ្ឍអចលនវត្ថុ និងសហកម្មសិទ្ធិករមិនអាចអនុវត្តករណីយកិច្ចតាមកិច្ចសន្យាបានរួមមាន កត្តាសុចរិតភាព និងភាពស្មោះត្រង់[3] និងកត្តាធនធាន ព្រមទាំងកត្តាដែលជះឥទ្ធិពលមួយចំនួនទៀត។

## ១.២. ការមិនគោរពបទបញ្ជាផ្ទៃក្នុងសម្រាប់អគារសហកម្មសិទ្ធិ

សម្រាប់អគារសហកម្មសិទ្ធិ អនុក្រឹត្យស្តីពីការគ្រប់គ្រងនិងប្រើប្រាស់អគារសហកម្មសិទ្ធិឆ្នាំ២០០៩ បានកំណត់អំពីកាតព្វកិច្ចរបស់អ្នកអភិវឌ្ឍនអចលនវត្ថុដែលសាងសង់អគារសហកម្មសិទ្ធិ ដោយតម្រូវឱ្យរៀបចំបទបញ្ជាផ្ទៃក្នុងសម្រាប់គ្រប់គ្រងមួយជាចាំបាច់ មុននឹងប្រកាសលក់ចំណែកឯកជននៃអគារសហកម្មសិទ្ធិ។[4] លើសពីនេះ សហកម្មសិទ្ធិករអាចធ្វើការព្រមព្រៀងក្នុងការចែងនូវវិធានផ្សេងៗជាច្រើនទាក់ទងនឹងកាតព្វកិច្ច និងបន្ទុកនានា នៅក្នុងបញ្ញាផ្ទៃក្នុងនៃអគារសហកម្មសិទ្ធិដែលក្រៅពីអនុក្រឹត្យបានកំណត់ថែមទៀត ប៉ុន្តែការកំណត់ទាំងនោះ មិនត្រូវប៉ះពាល់ដល់ទំនៀមទម្លាប់ល្អ និងសណ្តាប់ធ្នាប់សាធារណៈ។ ដូច្នេះនៅពេលដែលមានបទបញ្ជាផ្ទៃក្នុង សហកម្មសិទ្ធិករទាំងអស់ និងភាគីដែលពាក់ព័ន្ធត្រូវគោរពរាល់កាតព្វកិច្ច និងបន្ទុកនានាដែលមានកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងនៃអគារសហកម្មសិទ្ធិ។[5] ផ្ទុយទៅវិញ ក្នុងករណីខ្លះសហកម្មសិទ្ធិករនីមួយៗ

[2] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៥៤០។

[3] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៥៤០។

[4] អនុក្រឹត្យស្តីពីការគ្រប់គ្រងនិងប្រើប្រាស់អគារសហកម្មសិទ្ធិ, លេខ១២៦ អនក្រ. បក, ២៣ សីហា ២០០៩, មាត្រា៨ (ចាប់ពីពេលនេះតទៅហៅថាអនុក្រឹត្យស្តីពីការគ្រប់គ្រងនិងប្រើប្រាស់អគារសហកម្មសិទ្ធិលេខ១២៦ អនក្រ. បក)

[5] អនុក្រឹត្យស្តីពីការគ្រប់គ្រងនិងប្រើប្រាស់អគារសហកម្មសិទ្ធិលេខ១២៦ អនក្រ. បក, មាត្រា១៤។

មិនបានគោរពបទបញ្ជាផ្ទៃក្នុងនៃអគារសហកម្មសិទ្ធិនោះទេ រួមមាន ការដែលមិនទទួលខុសត្រូវក្នុងការជួសជុល ថែទាំ និងបន្ទុកផ្សេងៗទៀតលើចំណែកឯកជន និងចំណែករួម ព្រមទាំងចំណាយទាក់ទងនឹងការប្រើប្រាស់ផ្សេងៗ លើចំណែករួម ដូចជា ការមិនបង់ថ្លៃលើសេវាជួសជុល និងថែទាំងអគារ ព្រមទាំងប្រព័ន្ធលូ ប្រព័ន្ធបង្ហូរទឹក ឧស្ម័ន អគ្គិសនី ខ្សែរកាប និងការមិនបង់ថ្លៃលើសេវាប្រើប្រាស់ជណ្តើរយន្ត ឬអនាម័យ ព្រមទាំងចំណាយពាក់ព័ន្ធនឹងការប្រើប្រាស់ក្នុងជីវភាពប្រចាំថ្ងៃលើចំណែករួម។ ជាមួយនេះ សហកម្មសិទ្ធិករខ្លះបានធ្វើសកម្មភាពមួយចំនួនត្រូវបានហាមឃាត់ក្នុងអគារសហកម្មសិទ្ធិ ឧទាហរណ៍ បទបញ្ជាផ្ទៃក្នុងកំណត់ថា មិនអនុញ្ញាតឱ្យសហកម្មសិទ្ធិករទាំងអស់យកបរិវេណជុំវិញអាងហែលទឹក សម្រាប់ធ្វើជាកន្លែងចម្អិនម្ហូបអាហារ តែបែរជាមានសហកម្មសិទ្ធិករណាមួយនោះ យកកន្លែងនោះ មកធ្វើជាកន្លែងអាំងសាច់ សម្រាប់កម្មវិធីជួបជុំគ្នាទៅវិញ។

## ១.៣. ការថយចុះនៃគុណភាពសំណង់

បច្ចុប្បន្នភាពអគារសហកម្មសិទ្ធិកំពុងតែរីកដុះដាលយ៉ាងសន្ធឹកសន្ធាប់ទាំងកំពុងតែសាងសង់ និងសាងសង់រួច នៅតាមបណ្តាទីក្រុងមួយចំនួននៅកម្ពុជា ដែលជាកត្តាមួយចូលរួមធ្វើឱ្យទីក្រុងកម្ពុជាមានសោភណ្ឌភាព ជាពិសេសនៅទូទាំងរាជធានីភ្នំពេញអគារសហកម្មសិទ្ធិចាប់ពីឆ្នាំ២០០៥ ដល់២០១៧ មានចំនួនរហូតដល់៩៩៦ អគារ។[6] អគារសហកម្មសិទ្ធិដែលទើបសាងសង់រួចដាក់ឱ្យដំណើរការសម្រាប់ប្រជាពលរដ្ឋរស់នៅនាពេលឥលូវ សំណង់នៅមានគុណភាពរឹងមាំជាប់ធន់នៅឡើយ ប៉ុន្តែលក្ខខណ្ឌនៃអាយុកាលសំណង់ និងលក្ខខណ្ឌធម្មជាតិ ឬការសាងសង់អគារទាំងមូល ឬផ្នែកណាមួយនៃអគារ មិនបានពេលលេញតាមស្តង់ដារនេះជាកត្តាដែលធ្វើឱ្យប៉ះពាល់ដល់គុណភាព និងសោភណ្ឌភាពនៃសំណង់របស់អគារសហកម្មសិទ្ធិ ទទួលរងនូវការពុកផុយ ការទ្រុឌទ្រោម ទៅលើផ្នែកណាមួយ ឬផ្នែកទាំងមូលនៃអគារសហកម្មសិទ្ធិតែម្តង។

ឧទាហរណ៍ ករណីដែលបានផុតរយៈពេលក្នុងការធានាលើគុណភាពនៃសំណង់ពីសំណាក់អ្នកអភិវឌ្ឍអចលនវត្ថុ ស្រាប់តែមានបំពង់សេផ្នែកខ្លះរបស់អគារសហកម្មសិទ្ធិមានទឹកជ្រាបចេញពីបង្គន់នៃចំណែកឯកជនរបស់សហកម្មសិទ្ធិករណាម្នាក់នៅជាន់លើ ស្រក់ធ្លាក់ចុះមកលើចំណែកឯកជនរបស់សហកម្មសិទ្ធិករដទៃទៀតដែលជាអ្នកជិតខាងនៅជាន់ក្រោម ហើយសហកម្មសិទ្ធិករទាំងពីរមិនមានការឯកភាពគ្នាក្នុងការចាត់ចែងលើចំណាយសម្រាប់សាហ៊ុយជួសជុលនោះទេ ពោលគឺទុកឱ្យការជ្រាបទឹកនោះប៉ះពាល់បន្ថែមទៀត។ ទន្ទឹមនឹងនេះ ប្រសិនបើក្នុងបទបញ្ជាផ្ទៃក្នុងរបស់អគារសហកម្មសិទ្ធិ បានកំណត់ថាសហកម្មសិទ្ធិទាំងបានបង់ថ្លៃសេវាជួសជុល និងថែទាំអគារឱ្យគណៈកម្មការ ដើម្បីធ្វើការជួសជុល និងថែទាំអគារជាប្រចាំ ដូច្នេះគណៈកម្មការត្រូវទទួលបន្ទុកលើសាហ៊ុយចំណាយទាំងនោះ។

---

[6] ការិយាល័យសំណង់, មន្ទីររៀបចំដែនដី នគររូបនីយកម្ម សំណង់ និងសុរិយោដីរាជធានីភ្នំពេញ, *ស្ថិតិសំណង់ខ្ពស់ក្នុងរាជធានីភ្នំពេញ*។

ក្នុងករណីដែលសំណង់នៃអគារសហកម្មសិទ្ធិឆាប់ទ្រុឌទ្រោមធ្ងន់ធ្ងរខ្លាំងពេក ដោយសារតែចង់គេងចំណេញខ្លាំងពេកហួសហេតុ កាលពីពេលដែលសាងសង់អគារសហកម្មសិទ្ធិ ព្រមទាំងការសាងសង់អគារសហកម្មសិទ្ធិដោយមិនគោរពតាមមាត្រដ្ឋានបច្ចេកទេសសំណង់ ឬបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងសំណង់ ដែលជាហេតុនាំឱ្យមានការប្រឈមមុខនឹងការបាក់រលំ និងបញ្ហានានា ដោយតម្រូវឱ្យសាងសង់ជុះជុលជាថ្មីនូវអគារសហកម្មសិទ្ធិឡើងវិញ។ គួសបញ្ជាក់ផងដែលថាកត្តាទ្រុឌទ្រោមនៃសំណង់ ជាលក្ខខណ្ឌចាំបាច់ទាមទារឱ្យសហកម្មសិទ្ធិករទាំងអស់ មានកាតព្វកិច្ចចូលរួមបង់ថ្លៃសេវាថែទាំ និងជួសជុលជាប្រចាំដែលជាបន្ទុករួមដោយមានកំណត់ក្នុងកិច្ចសន្យា ឬបទបញ្ជាផ្ទៃក្នុង ដើម្បីការពារ និងថែរក្សាភាពគុណភាពនៃសំណង់របស់អគារឱ្យបានរឹងមាំស្ថិតស្ថេរយូរអង្វែង។

## ១.៤. ការធ្វើសកម្មភាពពាក់ព័ន្ធនឹងសំណង់

សហកម្មសិទ្ធិករ នៃអគារសហកម្មសិទ្ធិដែលបានធ្វើសកម្មភាពពាក់ព័ន្ធនឹងសំណង់ទាំងឡាយណាលើចំណែកឯកជនរបស់ខ្លួន ក្នុងគោលបំណងបំពេញតម្រូវការជីវភាពរស់នៅប្រចាំថ្ងៃ និងភាពសុខស្រួលក្នុងការរស់នៅផ្ទាល់ខ្លួន ប៉ុន្តែពេលខ្លះសកម្មភាពទាំងនោះអាចលេចឡើងជាបញ្ហាវិវាទគ្រប់ពេលវេលា ក្នុងករណីខ្លះសកម្មភាពទាំងនោះ ធ្វើឡើងដោយអចេតនា ធ្វេសប្រហែស ខ្ជីខ្ជា ដែលបង្កើតជាកំហុស ឬម្យ៉ាងទៀត ការធ្វើសកម្មភាពសាងសង់នោះ ធ្វើឡើងដោយគ្មានការអនុញ្ញាតពីច្បាប់ ឬការអនុញ្ញាតពីសហកម្មសិទ្ធិករដទៃទៀត ឬធ្វើឡើងដោយអំពើចិត្ត ជ្រុលហួសពីព្រំដែននៃសិទ្ធិលើចំណែកឯកជនរបស់ខ្លួន ឬបំពានគំនូសប្លង់ និងគ្មានស្តង់ដារតាមមាត្រដ្ឋានបច្ចេកទេសដែលបានកំណត់ ដែលបណ្តាលឱ្យប៉ះពាល់ដល់ផលប្រយោជន៍នៃចំណែកឯកជនរបស់សហកម្មសិទ្ធិករដទៃទៀត ឬផលប្រយោជន៍រួមនៃអគារសហកម្មសិទ្ធិទាំងមូល។

រូបភាពនៃសកម្មភាពសាងសង់សំណង់ទាំងអស់រួមមាន ការសាងសង់ឡើងវិញ ការពង្រីក និងការសង់បន្ថែម ការជួសជុល ឬការកែប្រែ ការរុះរើសំណង់ ឬការប្តូរទ្រង់ទ្រាយលើចំណែកឯកជនរបស់ខ្លួនដែលមានស្រាប់ដូចជា ការកែប្រែការប្រើប្រាស់ផ្នែកមួយចំនួននៃអគារសហកម្មសិទ្ធិ ឬទិដ្ឋភាពនៃអគារសហកម្មសិទ្ធិតួយ៉ាងការធ្វើបង្គន់អនាម័យបន្ថែម ការចោះជញ្ជាំងអឌ្ឍសិទ្ធិលើសពីពាក់កណ្តាលនៃកម្រាស់ជញ្ជាំង ការបន្តភ្ជាប់ទៅបំពង់លូ ការបង្កើនផ្ទៃក្រឡាកម្រាលសំណង់ ឬធ្វើការអ្វីដែលបណ្តាលឱ្យខូចខាតដល់ឧបករណ៍ប្រើប្រាស់រួមគ្នាមានដូចជា ផ្នែកណាមួយនៃប្រព័ន្ធបណ្តាញទឹក ភ្លើង ខ្សែរកាប និងបណ្តាញឧស្ម័ន។[7] ជាងនេះទៀតរាល់សាងសង់ពុះបំបែក ការសាងសង់បន្ថែមជាន់(ឡៅតឺ) លើចំណែកឯកជនរបស់ខ្លួនជាច្រើនចំណែក ឬសហកម្មសិទ្ធិករនៅជាន់លើបំផុត នៃអគារសហកម្មសិទ្ធិ សាងសង់បន្តសម្រាប់ប្រើប្រាស់ផលប្រយោជន៍ខ្លួនឯង ហើយលក់សិទ្ធិលើចំណែកដែលបានសាងសង់បន្តជាន់ទៅឱ្យអ្នកផ្សេង ការបំពាក់

[7] អនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់, លេខ៨៦ អនក្រ.បក, ១៩ ធ្នូ ១៩៩៧, មាត្រា២ (ចាប់ពីពេលនេះតទៅហៅថាអនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់លេខ៨៦ អនក្រ.បក)។

បរិក្ខារសំណង់ និងគ្រឿងសង្ហារឹមធ្ងន់ៗ ដែលសកម្មភាពនៃការសាងសង់ និងការរៀបចំទាំងនេះ អាចនាំឱ្យប៉ះពាល់ដល់មូលដ្ឋានគ្រឹះ ប្រព័ន្ធនៃការទ្រទម្ងន់ និងរចនាសម្ពន្ធផ្សេងទៀតរបស់អគារសហកម្មសិទ្ធិ ព្រមទាំងអាចប៉ះពាល់ដល់សុវត្ថិភាព និងរបៀបរៀបរយរបស់អគារសហម្មសិទ្ធទាំងមូល។

លើសពីនេះទៀត នៅក្នុងចំណែកឯកជនគឺមានជញ្ជាំងនៅជាប់ជាមួយនឹងចំណែកឯកជនដទៃទៀត ដែលប្រើប្រាស់រួមគ្នា ដែលជញ្ជាំងនោះហៅថា ជញ្ជាំងអឌ្ឍសិទ្ធិ។ ពេលដែលជួសជុល ឬសាងសង់ឡើងវិញនូវជញ្ជាំងអឌ្ឍសិទ្ធិនោះ ការទទួលបន្ទុកចំណាយទៅលើសាហ៊ុយនៃការជួសជុល និងការសាងសង់ឡើងវិញជាបន្ទុករបស់សហកម្មសិទ្ធិករដែលមានសិទ្ធិលើជញ្ជាំងអឌ្ឍសិទ្ធិ។[8] ពេលខ្លះសហកម្មសិទ្ធិដែលត្រូវទទួលបន្ទុកចំណាយលើសាហ៊ុយនៃការជួសជុល និងការសាងសង់ឡើងវិញលើជញ្ជាំងអឌ្ឍសិទ្ធិនោះ មិនព្រមចំណាយលើសកម្មភាពទាំងនោះទេ។ ករណីមួយចំនួនទៀតកម្មសិទ្ធិករនៃអឌ្ឍសិទ្ធិម្នាក់ៗ បានបោះផ្ទឹម ឬវនូតចូលលើពីពាក់កណ្ដាលនៃកម្រាស់ជញ្ជាំង ដើម្បីធ្វើការផ្សេងៗ ដោយប្រើជញ្ជាំងនោះ។

## ១.៥. ការរំលោភបំពានសិទ្ធិអ្នកជិតខាង

សិទ្ធិលើចំណែកឯកជនរបស់សហកម្មសិទ្ធិករអាចប្រើប្រាស់ អាស្រ័យផល និងចាត់ចែង លើចំណែកឯកជនរបស់ខ្លួនបានដោយសេរី ក្នុងទំហំដែលច្បាប់បានកម្រិត ហើយធ្វើយ៉ាងណាប្រើប្រាស់សិទ្ធិសេរីភាពក្នុងការប្រើប្រាស់ចំណែកឯកជនរបស់ខ្លួន ព្រមទាំងចំណែករួមដោយមិនបំពានលើសិទ្ធិរបស់សហកម្មសិទ្ធិករដទៃ។[9] ប៉ុន្តែចំពោះការប្រើប្រាស់សិទ្ធិលើចំណែករួម ឬចំណែកឯកជនមួយចំនួនរបស់សហកម្មសិទ្ធិករ ក្នុងករណីខ្លះលេចចេញនូវផលប៉ះពាល់ដល់សហកម្មសិទ្ធិករដទៃទៀតដែលជាអ្នកជិតខាង ឬប្រើប្រាស់សិទ្ធិជ្រុលហួសពីទំហំនៃសិទ្ធិរបស់ខ្លួនដែលច្បាប់ផ្ដល់ឱ្យ ឬប្រើប្រាស់សិទ្ធិរបស់ខ្លួនដោយបំពាន ក្នុងគោលបំណងព្យាបាទរាំងស្ទះ ឬបំពានដល់ការប្រើប្រាស់សិទ្ធិរបស់អ្នកដទៃ ដែលបញ្ហានេះបង្កឡើងជាអំពីរំខានដល់ជីវភាពរស់នៅរបស់សហកម្មសិទ្ធិករដទៃទៀត ទោះជាមានចេតនា ឬអចេតនាក៏ដោយ។

ឧទាហរណ៍៖ ករណីដែលសហកម្មសិទ្ធិករប្រើប្រាស់ចំណែកឯកជនរបស់ខ្លួនជាភោជនីយដ្ឋាន ឬបា(bar) ឌីស្កូ(disco) ដែលអាចបណ្ដាលឱ្យរំខានជីវភាពរស់នៅរបស់សហកម្មសិទ្ធិករដទៃទៀត។ ទីទៃពីនេះ ក្នុងករណីដែលសហកម្មសិទ្ធិណាម្នាក់បានដាក់សម្ភារៈដូចជា តុ ឬទូរ ដាក់បាំងផ្លូវច្រកចេញនៃចំណែករួម ដែលបណ្ដាលឱ្យប៉ះពាល់ដល់សហកម្មសិទ្ធិករដទៃទៀតធ្វើដំណើរចេញចូលមានភាពតូចចង្អៀត។ មួយវិញទៀត ករណីអគ្គីភ័យដែលបណ្ដាលមកពីកំហុសរបស់សហកម្មសិទ្ធិករ ដោយឆាបឆេះចេញពីចំណែកឯកជនរបស់សហកម្មសិទ្ធិករណាម្នាក់ ហើយរាលដាលដល់ចំណែកឯកជនដទៃទៀតដូចជា ករណីផ្ទុះធុងហ្គាស ភ្លើងធូប...។ល។ លើសពីនេះទៅទៀត ករណីខ្លះទៀត អគ្គីភ័យកើតឡើងចេញពីចំណែករួម ដូចអង្គភាពសារព័ត៌មានដំណឹងពលរដ្ឋបាន

[8] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា២១៥។

[9] អនុក្រឹត្យស្ដីពីការគ្រប់គ្រងនិងប្រើប្រាស់អគារសហកម្មសិទ្ធិលេខ១២៦ អនក្រ. បក, មាត្រា១១។

ផ្សាយ ករណីអគារ ខុនដូ De Castle មានទីតាំងស្ថិតតាមបណ្តោយផ្លូវ ៣១៥ ភូមិ ៧ សង្កាត់បឹងកក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២០ បានកើតឡើងករណីអគ្គីភ័យមួយ ដែលបណ្តាលមកពីឆ្លងចរន្តអគ្គីសនីប្រអប់ភ្លើងនៅចំណុចជាន់ទី៦ និងជាន់ទី៧ ក្នុងខុនដូនោះតែម្តង ប៉ុន្តែត្រូវបានកម្លាំងរបស់ការិយាល័យអគ្គីភ័យរាជធានីភ្នំពេញពន្លត់បានទាន់ពេលវេលា មិនបង្កឱ្យខូចខាតខ្លាំងឡើយ។ [10] ពេលខ្លះ ករណីអគ្គីភ័យនេះធ្ងន់ធ្ងរមិនត្រឹមតែប៉ះពាល់ដល់ទ្រព្យសម្បត្តិនៅក្នុងអគារសហកម្មសិទ្ធិប៉ុណ្ណោះទេ ថែមទាំងអាចឆក់យកអាយុជីវិតមនុស្សដែលរស់នៅក្នុងអគារទាំងមូល។

អំពើរំខានដល់ជីវភាពរស់នៅរបស់សហកម្មសិទ្ធិករ អាចបណ្តាលមកពី ឧស្ម័ន ចំហាយទឹក ក្លិនផ្សេងៗ ម្រែងភ្លើង កំដៅ សម្លេង រំញ័រ សំរាម ឬ ការទុកដាក់វត្ថុមានគ្រោះថ្នាក់ ឬវត្ថុដែលរំខានដល់អ្នកជិតខាង និងវត្ថុគ្មានអនាម័យ រួមទាំងសកម្មភាពមួយចំនួនដែលប៉ះពាល់ទៅដល់សហកម្មសិទ្ធិករដទៃទៀតដែលជាអ្នកជិតខាង ដោយកើតចេញពីចំណែកឯកជនរបស់ខ្លួន ឬចំណែករួមនៅក្នុងអគារសហកម្មសិទ្ធិ។ ក្នុងនោះដែរ អំពើរំខានដូចបានរៀបរាប់ខាងលើ អាចកើតឡើងដោយចេតនារបស់សហកម្មសិទ្ធិករមានឆន្ទៈប្រព្រឹត្តអំពើផ្ទាល់ ព្រោះថាសកម្មភាពរស់ខ្លួនដែលបានធ្វើ ប្រាកដជាមានផលប៉ះពាល់ នៅតែបន្តសកម្មភាពនោះ ប៉ុន្តែពេលខ្លះក៏កើតចេញដោយអចេតនា ព្រោះថាសហកម្មសិទ្ធិករមានការធ្វេសប្រហែស ខ្ជីខ្ជា និងមិនប្រុងប្រយ័ត្ន បង្កជាមូលហេតុនៃវិវាទ។

ក្នុងករណីខ្លះសហកម្មសិទ្ធិករយកចំណែករួមដែលជាកម្មសិទ្ធិអវិភាគ ធ្វើជាកម្មវត្ថុនៃការបែងចែង និងរំលោភយកចំណែករួម យកមកធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួនផ្តាច់មុខ ឬបង្ខំឱ្យលក់ចំណែករួមដាច់ដោយឡែកពីចំណែកឯកជន រួចរក្សាទុកចំណែកឯកជនសម្រាប់ប្រើប្រាស់។ មិនត្រឹមតែប៉ុណ្ណោះ មានការរារាំង និងរំខានដល់ការប្រើប្រាស់លើចំណែករួមរបស់សហកម្មសិទ្ធិករដទៃ សម្រាប់ផលប្រយោជន៍ផ្ទាល់ខ្លួន និងការព្យាបាទអ្នកជិតខាង ដូចជា ការហាមឃាត់សហកម្មសិទ្ធិករដទៃទៀតមិនឱ្យប្រើប្រាស់ជណ្តើរយន្តរួម ការកាត់បំពង់បង្ហូរទឹក និងសកម្មភាពប៉ះពាល់ផ្សេងទៀត។

[10] រិទ្ធី, "ឆ្លងចរន្តអគ្គិសនីប្រអប់ភ្លើងជាន់ទី៦,៧ នៅក្នុង ខន់ដូរ De Castle ក្លាយជាអគ្គីភ័យ ឆេះផ្ទើស សមត្ថកិច្ចនាំថយន្តទៅអន្តរាគមន៍," *ដំណឹងពលរដ្ឋ (Peolenews.asia)*, ០៧ សីហា ២០២០។

# ជំពូកទី២
# នីតិវិធីដោះស្រាយវិវាទអគារសហកម្មសិទ្ធិក្រៅប្រព័ន្ធតុលាការ

នៅពេលដែលមានវិវាទនៃអគារសហកម្មសិទ្ធិកើតឡើង ជាបឋមភាគីនៃវិវាទនឹងប្រើប្រាស់វិធីផ្សេងៗជាច្រើន ដើម្បីស្វែងរកដំណោះស្រាយរួមមួយដ៏ល្អប្រសើរ ដោយមិនចាំបាច់ឆ្លងកាត់ប្រព័ន្ធតុលាការ។ សម្រាប់ដំណោះស្រាយក្រៅប្រព័ន្ធតុលាការប្រមូលផ្តុំទៅដោយទម្រង់ជាច្រើននៃវិធីដោះស្រាយវិវាទ ដែលវិធីមួយចំនួនមានលក្ខណៈសាមញ្ញ និងមានលក្ខណៈទូទៅក្នុងការអនុវត្តជាក់ស្តែង រួមមាន ការចរចា ការសម្របសម្រួល ឬសន្ធានកម្ម ឬការផ្សះផ្សា និងអាជ្ញាកណ្តាល។ ប៉ុន្តែដោយសារតែអាជ្ញាកណ្តាល គឺផ្តោតទៅលើតែវិស័យការងារ និងពាណិជ្ជកម្មតែប៉ុណ្ណោះ ទើបបានជាជំពូកនេះ មិនលើកយកមកបង្ហាញ។ ចំណែកឯនៅក្នុងចំណុច ២.២ ការដោះស្រាយវិវាទនៃអគារសហកម្មសិទ្ធិដោយមានអ្នកសម្របសម្រួល ដែលបានជ្រើសរើសយកពាក្យថា ការសម្របសម្រួល ពីព្រោះថាបើពិនិត្យទៅលើអត្ថន័យពាក្យថា សន្ធានកម្ម ការម្របសម្រួល ឬការផ្សះផ្សា មានអត្ថន័យប្រហាក់ប្រហែលគ្នា ដែលក្នុងនោះលើកឡើងជាពិសេសអំពីការដោះស្រាយវិវាទដោយមានជំនួយពីតតិយជន ក្នុងការស្វែងរកដំណោះស្រាយសម្រាប់គូភាគី ហើយអ្នកសម្របសម្រួលមិនអាចបង្ខិតបង្ខំលើភាគីណាមួយនៅក្នុងការដោះស្រាយបានឡើយ។ ម្យ៉ាងទៀតពាក្យថា ការសម្របសម្រួល មានលក្ខណៈប្រើប្រាស់ជាទូទៅ ទើបជំពូកនេះ លើកពាក្យនេះ មកធ្វើការបកស្រាយ។ នៅក្នុងជំពូកនេះនឹងបកស្រាយទៅលើ ២.១. ការដោះស្រាយវិវាទដោយភាគី និង ២.២. ការដោះស្រាយដោយមានអ្នកសម្របសម្រួល។

## ២.១. ការដោះស្រាយវិវាទអគារសហកម្មសិទ្ធិដោយភាគី

សហកម្មសិទ្ធិករ អ្នកអភិវឌ្ឍអចលនវត្ថុ និងអង្គការគ្រប់គ្រងអាគារសហកម្មសិទ្ធិ អាចជាភាគីនៃវិវាទអគារសហកម្មសិទ្ធិ។ ក្នុងចំណោមភាគីទាំងបីនោះ ភាគីណាមួយដែលទទួលរងនូវការខូចខាត តែងតែទទូចចង់បានដំណោះស្រាយសមស្របមួយពីសំណាក់ភាគីនៃវិវាទម្ខាងទៀត ដោយមធ្យោបាយដោះស្រាយស្ម័គ្រចិត្ត។ ចំពោះមធ្យោបាយនៃការដោះស្រាយវិវាទអគារសហកម្មសិទ្ធិ ដោយគ្មានការអនុវត្តដោយបង្ខំ ហើយរក្សាបានផលប្រយោជន៍ដ៏ប្រសើរគឺជាការចរចា។ ការចរចា គឺជាផ្នែកចម្បងមួយនៅក្នុងមធ្យោបាយនានាក្នុងការដំណោះស្រាយវិវាទអគារសហកម្មសិទ្ធិ ថែមទាំងជាជំហានដំបូងដែលភាគីប្រើប្រាស់វិធីនេះ។ ក្នុងនេះដែរដំណើរការនៃការចរចា ឆ្លងកាត់ដំណាក់កាលបីរួមមាន ដំណាក់កាលត្រៀម ដំណាក់កាលចាប់ផ្តើម និងដំណាក់កាលបញ្ចប់ការចរចា។ នៅក្នុងដំណើរការនៃការចរចា មានវិធីសាស្ត្រជាមួយចំនួន ដើម្បីអាចឈានទៅរកដំណោះស្រាយក្នុងការព្រមព្រៀងបញ្ចប់វិវាទ ពោលគឺវិធីសាស្ត្រចរចាបែបបែងចែក និងវិធីសាស្ត្រចរចាផ្អែកលើផលប្រយោជន៍។

### ២.១.១. ការចរចា

ការចរចាគឺជា "ដំណើរការនៃការឆ្លើយឆ្លងគ្នាទៅវិញទៅមក ដែលតាមរយៈនេះ ភាគីទាំងអស់ដាក់ជូន ឬពិចារណាលើសម្មើផ្សេងៗ រហូតដល់សម្មើណាមួយត្រូវបានធ្វើឡើងហើយត្រូវបានគេទទួលយក"[11]។ ក្នុងន័យនេះសំដៅលើទម្រង់នៃការដោះស្រាយបញ្ហាវិវាទ ដោយស្ម័គ្រចិត្តក្នុងគោលបំណងផ្សះផ្សាគ្នា ដោយផ្អែកលើការព្រមព្រៀង ហើយជាមធ្យោបាយដោះស្រាយវិវាទមួយដែលមានលក្ខណៈជាកិច្ចពិភាក្សា។

សហកម្មសិទ្ធិករអាចធ្វើការជួបប្រជុំគ្នា ដើម្បីជជែកពិភាក្សាតែពីរនាក់ ឬជាក្រុម ក្នុងនោះដែរក៏អាចទាមទារឱ្យសហកម្មសិទ្ធិករដែលជាភាគីវិវាទ ធ្វើសេចក្តីអះអាងអំពីអង្គហេតុដែលជាមូលហេតុនៃចំណុចវិវាទទៅវិញទៅមក ឈានទៅរកអ្នកទទួលខុសត្រូវដែលបានបង្កនូវកំហុស ឆ្លើយតបទៅនឹងការចង់បាន ឬតម្រូវការរបស់សហកម្មសិទ្ធិករដែលទទួលរងព្យាសនកម្ម ឱ្យភាគីម្ខាងទៀតព្រមព្រៀងផ្តល់នូវដំណោះស្រាយសមរម្យ និងពេញចិត្ត។ ជារួមមក ការដោះស្រាយវិវាទអគារសហកម្មសិទ្ធិ ដោយគ្មានភាគីទីបី ចូលរួមជួយសម្រមសម្រួលដោះស្រាយជាទម្រង់មួយ ហៅថា ការចរចាទ្វេភាគីរវាងសហកម្មសិទ្ធិករ និងភាគីម្ខាងទៀតនៃវិវាទ។ ជាទូទៅ ការប្រាស្រ័យទាក់ទងគ្នាក្នុងកិច្ចចរចាអាចធ្វើឡើងតាមរយៈចំពោះមុខជាជំនួបផ្ទាល់តាមបែបធម្មតា ឬកិច្ចប្រជុំពិភាក្សាជាផ្លូវការ ឬប្រព័ន្ធទំនាក់ទំនងសង្គមដូចជា ទូរសព្ទ ឬសារអេឡិចត្រូនិច តេលេក្រាម ហ្វេសប៊ុក សំបុត្រអ៊ីម៉ែលជាដើម។

### ២.១.២. ដំណើរការនៃការចរចា

នៅក្នុងដំណើរនៃការចរចាពុំមានកំណត់នៅក្នុងបទបញ្ញត្តិច្បាប់ណាមួយឱ្យបានជាក់លាក់នោះទេ។ [12] ប៉ុន្តែដើម្បីអាចឱ្យមូលហេតុនៃវិវាទអគារសហកម្មសិទ្ធិដែលកើតមានឡើង យកមកធ្វើការចរចាឈានទៅដល់ការស្រុះស្រួលបញ្ចប់វិវាទ ត្រូវឆ្លងកាត់ដំណើរការនៃការចរចាចំនួន៣រួមមាន ដំណាក់កាលត្រៀម ដំណាក់កាលចាប់ផ្តើម និងដំណាក់បញ្ចប់ក្នុងការចរចា។

#### ២.១.២.១. ដំណាក់កាលត្រៀម

ដើម្បីអាចឱ្យមានការចរចារវាងគូភាគីនៃវិវាទអគារសហកម្មសិទ្ធិបាន ជាបឋមសហកម្មសិទ្ធិករណាម្នាក់ដែលមានបំណងចង់ធ្វើការចរចាត្រូវជូនដំណឹងស្តីអំពីមូលហេតុនៃវិវាទទៅកាន់សហកម្មសិទ្ធិករម្ខាងទៀត ដែលពាក់ព័ន្ធនឹងចំណុចវិវាទ។ ការជូនដំណឹងស្តីអំពីវិវាទ មានគោលដៅក្នុងការជម្រាប់ជាព័ត៌មាន និងជាការអញ្ជើញដើម្បីឱ្យមកចូលរួមការចរចាគ្នា ហើយក៏ជាដំណាក់កាលមួយសម្រាប់ការវាស់ស្ទង់នូវទឹកចិត្តរបស់ភាគីម្ខាងទៀត

[11] ស៊្វីន អ៊ែម អូស្ទីរមីឡឺរ៍, *ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការប្រទេសកម្ពុជា៖ សៀវភៅសិក្សាស្តីពីទស្សនាទានសំខាន់ៗ*, បោះពុម្ពលើកទី២ (រាជធានីភ្នំពេញ, ២០១០), ១៣។

[12] ស៊្វីន អ៊ែម អូស្ទីរមីឡឺរ៍, *ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការប្រទេសកម្ពុជា៖ សៀវភៅសិក្សាស្តីពីទស្សនាទានសំខាន់ៗ*, បោះពុម្ពលើកទី២ (រាជធានីភ្នំពេញ, ២០១០), ៦៦។

ថាតើមានឆន្ទៈក្នុងការចរចាដែរឬទេ? ក្នុងករណីដែលភាគីម្ខាងទៀត យល់ព្រមតបការអញ្ជើញ វាជាឱកាសមួយក្នុងការរៀបចំឆ្លើយតបនឹងចំណុចវិវាទត្រលប់ទៅវិញ។ ផ្ទុយទៅវិញប្រសិនបើភាគីម្ខាងទៀត បដិសេធចំពោះការអញ្ជើញនោះ ការចរចាមិនអាចធ្វើឡើងបានទេ។

នៅក្នុងការជូនដំណឹងនេះ សហកម្មសិទ្ធិករអាចកំណត់កាលបរិច្ឆេទ ពេលវេលា និងទីកន្លែងណាមួយដែលអាចឱ្យភាគីទាំងសងខាងចូលរួមធ្វើការចរចាគ្នាបាន។ ជាទូទៅមធ្យោបាយនៃការជូនដំណឹងមានច្រើនប្រភេទ អាស្រ័យទៅការយល់ឃើញក្នុងការទំនាក់ទំនងរបស់ភាគីនៃវិវាទ ដោយធ្វើយ៉ាងណាឱ្យតែដំណឹងនោះបានទៅដល់ភាគីម្ខាងទៀត។

### ២.១.២.២. ដំណាក់កាលចាប់ផ្ដើម

នៅពេលដំណើរការចរចាគ្នា ជាពេលវេលាមួយដែលភាគីនៃវិវាទទាំងសងខាងលើកឡើងអំពីបញ្ហាវិវាទអគារសហកម្មសិទ្ធិនៅចំពោះមុខគ្នា[13] ក្នុងការពិភាក្សា តទល់វែកញែកហេតុផលនៃការបង្កបញ្ហា ថាតើបញ្ហាវិវាទបង្កឡើងពីមូលហេតុអ្វី? អ្នកណាជាអ្នកបង្ក? អ្នកណាជាអ្នកទទួលខុសត្រូវ? ដោយធ្វើសេចក្ដីអះអាងបំភ្លឺរៀបរាប់អំពីអង្គហេតុដែលម្នាក់ៗយល់ឃើញ ព្រមទាំងបង្ហាញនូវភស្តុតាង ដើម្បីស្វែងរកការពិត និងលើកឡើងអំពីការទាមទារចង់បានរវាងភាគីទាំងសងខាង ដោយព្យាយាមពន្យល់ បញ្ចុះបញ្ចូល សម្រុះសម្រួលគ្នា ដើម្បីធ្វើការសម្បទានឱ្យគ្នាទៅវិញទៅមកក្នុងការរកដំណោះស្រាយរួម។

សម្រាប់រយៈពេល និងលទ្ធផលនៃការចរចា ពេលខ្លះអាចខ្លី អាចវែង ពេលខ្លះច្រើនដង ពេលខ្លះជោគជ័យ ឬបរាជ័យក្នុងការត្រូវរ៉ូវគ្នា គឺអាស្រ័យទៅលើឆន្ទៈរបស់ភាគីទាំងសងខាងនៅក្នុងការជជែកពិភាក្សា ឥរិយាបទ និងសិស្បៈនៃការផ្សះផ្សា ឬស្ថានភាព និងកាលទេសៈក្នុងការផ្សះផ្សា ព្រមទាំងទំហំនៃកម្មវត្ថុវិវាទអគារសកម្មសិទ្ធិដែលកើតឡើង។ ចំណែកឯការចរចាខ្លះមិនអាចធ្វើឡើងតែមួយដងទេ ពោលគឺអាចធ្វើឡើងជាច្រើនដង ទើបអាចទទួលបានដំណោះស្រាយរួមដែលសមស្រប។

### ២.១.២.៣. ដំណាក់កាលបញ្ចប់

នៅពេលដែលការចរចាត្រូវបានបញ្ចប់ ជាលទ្ធផលនៃការចរចាអាចទទួលបាននូវលទ្ធផលពីរផ្សេងគ្នាគឺជោគជ័យ ឬបរាជ័យក្នុងការព្រមព្រៀងបញ្ចប់វិវាទ។ ក្នុងករណីដែលភាគីទាំងសងខាងមានឆន្ទៈដូចគ្នា ក្នុងការឯកភាពគ្នាសម្រាប់ដំណោះស្រាយរួម ដោយព្រមទទួលស្គាល់ ឬលះបង់នៃការទាមទារឱ្យអនុវត្តកាតព្វកិច្ចណាមួយចំពោះគ្នាទៅវិញទៅមក ឬទទួលយកនូវលក្ខខណ្ឌដែលបានដាក់ឱ្យគ្នាទៅវិញទៅមក នោះមានន័យថាលទ្ធផលនៃការចរចាទទួលបាននូវភាពជោគជ័យ។[14]

[13] វិន អ៊ែម អូស៊ីរមីឡឺរ៍, *ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការប្រទេសកម្ពុជា៖ សៀវភៅសិក្សាស្ដីពីទស្សនាទានសំខាន់ៗ*, បោះពុម្ពលើកទី២ (រាជធានីភ្នំពេញ, ២០១០), ៧០។

[14] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្ដីព្រៀងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, *សេចក្ដីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី*, ១៖ ២។

ការព្រមព្រៀងបញ្ចប់វិវាទ ក្នុងករណីខ្លះគូភាគីអាចធ្វើឡើងដោយផ្ទាល់មាត់ ដោយសារតែកម្មវត្ថុនៃវិវាទមានតម្លៃតិចតួច ឬកម្មវត្ថុនៃវិវាទនោះអាចធ្វើបដិទានបានភ្លាមៗ ឬអាចផ្តល់នូវតាវកាលិកជាក់ស្តែង ដោយមិនចាំបាច់អនុវត្តកម្មវត្ថុនៃការព្រមព្រៀងនៅពេលអនាគតនោះទេ។ ប៉ុន្តែគូភាគីគួរតែធ្វើឡើងជាទម្រង់លិខិតលាយលក្ខណ៍អក្សរ ទោះជាកម្មវត្ថុនៃវិវាទនោះមានតម្លៃប៉ុនណាក៏ដោយ ទើបអាចធានាបាននូវប្រសិទ្ធភាពនៃការអនុវត្តកាតព្វកិច្ច និងលក្ខខណ្ឌដែលបានកំណត់នៅក្នុងកិច្ចព្រមព្រៀង[15] មានន័យថា អាចជៀសវាងនូវជម្លោះម្តងទៀតនៅពេលក្រោយ។ ជាពិសេសគូភាគីមានភាពងាយស្រួលក្នុងការអនុវត្តតាមកិច្ចព្រមព្រៀងដោយគ្មានភាពស្រពិចស្រពិល និងមិនអាចប្រកែកថាភ្លេចភ្លាំងនូវលក្ខខណ្ឌណាមួយ ឬម្យ៉ាងទៀតមិនអាចបំភ្លៃប្រែក្រឡាស មិនទទួលស្គាល់ថា បានធ្វើការព្រមព្រៀងជាមួយភាគីនៃវិវាទម្ខាងទៀតពីមុនមកទេ។ ក្នុងករណីភាគីនៃវិវាទមានភាពឃឺតយ៉ាវ ឬអលទ្ធភាពក្នុងការអនុវត្ត ឬអនុវត្តកាតព្វកិច្ចមិនបានពេញលេញ ឬមិនអនុវត្តកាតព្វកិច្ចទាល់តែសោះ[16] ភាគីនៃវិវាទម្ខាងទៀតអាចយកកិច្ចព្រមព្រៀងដែលធ្វើឡើងជាលាយលក្ខណ៍អក្សរនេះធ្វើជាភស្តុតាងយ៉ាងរឹងមាំសម្រាប់ប្តឹងទៅតុលាការ។

ការព្រមព្រៀងក្នុងការបញ្ចប់វិវាទនេះ ត្រូវបានក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧ បានទទួលស្គាល់សិទ្ធិនេះហៅថា ការសះជា ដែលសំដៅទៅលើកិច្ចសន្យាមួយ ដែលក្នុងនោះភាគីធ្វើឡើងដើម្បីផ្សះផ្សាបញ្ចប់វិវាទណាមួយ ដោយការព្រមព្រៀងគ្នា និងអនុគ្រោះឱ្យគ្នាទៅវិញទៅមក។[17] ក្នុងករណីដែលភាគីមិនចង់ដោះស្រាយ ឬមិនមានការព្រមព្រៀងគ្នា នោះនឹងគ្មានដំណោះស្រាយឡើយ មានន័យថា ការចរចានោះ ទទួលបាននូវភាពបរាជ័យក្នុងការបញ្ចប់វិវាទ។

### ២.១.៣. វិធីសាស្ត្រជាមូលដ្ឋាននៃការចរចា

#### ២.១.៣.១. ការចរចាបែបបែងចែក

"នៅក្នុងការចរចាបែបបែងចែក ភាគីនៃវិវាទសន្មតថាមានធនធានដែលមានចំនួនជាក់លាក់មួយ ដែលពួកគេត្រូវបែងចែករវាងគ្នា និងគ្នា"[18] ត្រង់ចំណុចនេះសំដៅលើការកំណត់កម្មវត្ថុ និងទំហំនៃការទាមទារ ដើម្បីធ្វើបដិទាននូវព្យសនកម្មដែលបណ្តាលមកពីមូលហេតុនៃវិវាទអគារសហកម្មសិទ្ធិ ពោលគឺសហកម្មសិទ្ធិករជាមួយនឹងភាគីម្ខាងនៃវិវាទ ប្រកាន់ភ្ជាប់នូវគោលជំហររៀងៗខ្លួនក្នុងការផ្តល់នូវដំណោះស្រាយដោយឆន្ទៈឯកតោភាគី

[15] វិន អ៊ែម អូស្ទីរមីឡឺរ, *ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការប្រទេសកម្ពុជា៖ សៀវភៅសិក្សាស្តីពីទស្សនាទានសំខាន់ៗ*, បោះពុម្ពលើកទី២ (រាជធានីភ្នំពេញ, ២០១០), ៧២។

[16] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៣៨៩។

[17] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៧២៤។

[18] ស៊្វីន អ៊ែម អូស្ទីរមីឡឺរ, *ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការប្រទេសកម្ពុជា៖ សៀវភៅសិក្សាស្តីពីទស្សនាទានសំខាន់ៗ*, បោះពុម្ពលើកទី២ (រាជធានីភ្នំពេញ, ២០១០), ១៨។

ហើយបង្ហាញដំណោះស្រាយដែលខ្លួនមាននោះទៅឱ្យភាគីនៃវិវាទម្ខាងទៀត ដើម្បីពិនិត្យនឹងយល់ព្រមទទួលយកដោយមិនបានធ្វើសម្បទានឱ្យគ្នាទៅវិញទៅមកទេ។ ដូច្នេះហើយ ប្រសិនបើភាគីម្ខាងទទួលបានកាន់តែច្រើន នោះភាគីម្ខាងទៀតទទួលបានកាន់តែតិចនៅក្នុងការចរចាដោះស្រាយបញ្ចប់វិវាទអគារសហកម្មសិទ្ធិ។ ជាលទ្ធផល ភាគីម្ខាង ឬក៏ភាគីទាំងសងខាង អាចមានការមិនពេញចិត្តគ្នា ហើយបណ្ដាលឱ្យទំនាក់ទំនងល្អជាមួយគ្នាទាំងក្នុងពេលបច្ចុប្បន្ន និងអនាគត នឹងត្រូវបំផ្លាញដោយសារតែមធ្យោបាយដាក់សម្ពាធដែលត្រូវបានប្រើប្រាស់នៅក្នុងដំណាក់កាលចរចានេះ។

ឧទាហរណ៍៖ សហកម្មសិទ្ធិករណាម្នាក់បានអះអាងថា ទ្រព្យសម្បត្តិនៅក្នុងផ្ទះរបស់ខ្លួនត្រូវបានខូចខាតដែលបណ្ដាលមកពីអគ្គិភ័យឆេះនៅក្នុងផ្ទះរបស់សហកម្មសិទ្ធិករម្ខាងទៀតដែលនៅជាប់គ្នា។ ទ្រព្យសម្បត្តិរបស់សហកម្មសិទ្ធិករដែលខូចខាតរួមមាន ម៉ាស៊ីនត្រជាក់មួយគ្រឿង ទូរទស្សន៍ចាប់ជាប់ជញ្ជាំងមួយគ្រឿង ទូរទឹកកកមួយគ្រឿង ព្រមទាំងជញ្ជាំង និងសម្ភារៈរាយរងមួយចំនួនទៀត។ នៅពេលភាគីទាំងពីរធ្វើការចរចាតាមបែបបែងចែក ភាគីទាំងសងខាងគឺប្រកាន់គោលជំហររៀងៗខ្លួន ដោយភាគីខាងរងគ្រោះទាមទារឱ្យសង់ការខូចខាតពេលលេញទាំងអស់ ចំណែកភាគីដែលបង្ក មិនព្រមសង់តាមអ្វីដែលភាគីរងគ្រោះទាមទារនោះទេ ដោយយល់ឃើញថា ការខូចខាតនោះ កើតឡើងដោយអចេតនា ពុំមែនជាអំពើដែលភាគីខាងជនបង្កបង្កើតឡើងនោះឡើយ។ ដូចនេះហើយ ភាគីខាងជនបង្កមិនព្រមសង់ពេញលេញតាមសំណើភាគីខាងជនរងគ្រោះ ប៉ុន្តែជនរងគ្រោះនៅតែទទូចចង់ឱ្យភាគីខាងជនបង្ក បង់ថ្លៃខូចខាតឱ្យស្មើនឹងតម្លៃដើមនៃវត្ថុទាំងនោះ។

**២.១.៣.២. ការចរចាផ្អែកលើផលប្រយោជន៍**

"ការចរចាផ្អែកលើផលប្រយោជន៍មានលក្ខណៈសហការជាងការចរចាបែបបែងចែក"[19] ក្នុងន័យនេះចង់បញ្ជាក់ថា នៅក្នុងការចរចាភាគីទាំងសងខាងមានឆន្ទៈព្រមព្រៀងសម្បទានឱ្យគ្នាទៅវិញទៅមក ដោយឈរលើផលប្រយោជន៍រួមជាធំ និងស្មគ្រចិត្តលះបង់រៀងៗខ្លួន ដើម្បីបញ្ចប់វិវាទ។ ក្នុងនោះដែរ ការយល់ច្បាស់អំពីការខាតបង់ដែលបានកើតឡើងដោយមូលហេតុនៃវិវាទអគារសហកម្មសិទ្ធិម្ដងរួចទៅហើយ ប្រសិនបើមិនព្រមដោះស្រាយឱ្យបានសមរម្យ និងអាចទទួលយកបានទាំងសងខាងទេ ប្រហែលជានឹងខាតបង់ផលប្រយោជន៍កាន់តែរីកធំឡើងហើយ ដូច្នេះភាគីទាំងសងខាងមិនអាចប្រកាន់គោលជំហររៀងៗខ្លួនក្នុងការចរចាស្វែងរកដំណោះស្រាយតែមួយឡើយ។ ការប្រើប្រាស់ការពិភាក្សាគ្នា និងការផ្លាស់ប្ដូរគំនិតទស្សនៈទៅវិញទៅមកដោយសាមគ្គីភាព ក្នុងការស្វែងរកវិធីសាស្ត្រយ៉ាងណា ដើម្បីបង្កើតនូវដំណោះស្រាយឱ្យបានច្រើនគឺជាមធ្យោបាយដ៏ល្អប្រសើរ ជាជាងការចង់ឈ្នះចង់ចាញ់គ្នា សំខាន់នោះគឺបង្កើតជម្រើសក្នុងដំណោះស្រាយឱ្យគ្នាទៅវិញទៅមក

[19] ស៊ីវិន អ៊ែម អូស្ទីរមីឡឺរ, *ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការប្រទេសកម្ពុជា៖ សៀវភៅសិក្សាស្ដីពីទស្សនាទានសំខាន់ៗ*, បោះពុម្ពលើកទី២ (រាជធានីភ្នំពេញ, ២០១០), ១៩។

កាន់តែច្រើន ដោយសារពេលខ្លះ ភាគីទាំងសងអាចរកឃើញនូវផលប្រយោជន៍សំខាន់ផ្សេងៗទៀត អាចជំនួសឱ្យគ្នាទៅវិញទៅមក ទើបអាចរកដំណោះស្រាយរួមបាន ។

ឧទាហរណ៍៖ សហកម្មសិទ្ធិករពុំបានបង់ថ្លៃទិញផ្ទះចំនួន០៣ខែ គិតជាទឹកប្រាក់សរុប៧៥០ (ប្រាំពីររយហាសិប) ដុល្លាអាមេរិក។ ភាគីខាងអ្នកអភិវឌ្ឍអចលនវត្ថុទាមទារឱ្យភាគីខាងសហកម្មសិទ្ធិករបង់ប្រាក់សរុបទាំងអស់ចំនួន០៣ខែឱ្យខ្លួន ប៉ុន្តែភាគីខាងសហកម្មសិទ្ធិករពុំមានលទ្ធភាពបង់ឱ្យអ្នកអភិវឌ្ឍអចលនវត្ថុនោះទេ។ នៅក្នុងការចរចាផ្អែកលើផលប្រយោជន៍ ភាគីទាំងសងខាងបានពិភាក្សាគ្នាអំពីបញ្ហានានា រហូតឈានដល់ស្ថានភាពការងារ និងជីវភាពរស់នៅរបស់សហកម្មសិទ្ធិករ ដោយឃើញថា សហកម្មសិទ្ធិករមានជំនាញផ្នែកលក់អចលនវត្ថុ។ ចំណែកផលប្រយោជន៍ចម្បងរបស់អ្នកអភិវឌ្ឍអចលនវត្ថុគឺយកថ្លៃលក់មកសង់ថ្លៃសំណង់ និងបើកប្រាក់ឈ្នួលឱ្យបុគ្គលិក និងចំណាយផ្សេងៗរបស់ខ្លួន រីឯសហកម្មសិទ្ធិករយកប្រាក់ថ្លៃទិញចំនួន០៣ខែនោះដើម្បីព្យាបាលម្ដាយឈឺនៅពេទ្យ ដូច្នេះអ្នកអភិវឌ្ឍអចលនវត្ថុកំពុងត្រូវការបុគ្គលិកផ្នែកលក់ផង ក៏សម្រេចចិត្តឱ្យភាគីខាងសហកម្មសិទ្ធិករមកបម្រើការងារដើម្បីជាការទូរទាត់បំណុលតែម្ដង ហើយភាគីខាងសហកម្មសិទ្ធិករក៏បានយល់ព្រមតាមសំណើររបស់អ្នកអភិវឌ្ឍអចលនវត្ថុ។ ជារួមមក ការអនុវត្តវិធីនេះ ភាគីទាំងសងខាងអាចមានការពេញចិត្តនូវអ្វីដែលទទួលបានប្រកបដោយភាពរីករាយ ហើយចំណងទំនាក់ទំនងរវាងគ្នាអាចនឹងរក្សាបានដដែល។

## ២.២. ការដោះស្រាយវិវាទអគារសហកម្មសិទ្ធិដោយមានអ្នកសម្របសម្រួល

ប្រសិនបើភាគីនៃវិវាទអគារសហកម្មសិទ្ធិធ្វើការចរចាគ្នាហើយ នៅតែមិនទាន់ទទួលបានលទ្ធផលត្រូវរ៉ូវគ្នាទេ ភាគីនៃវិវាទអាចងៀកមកស្វែងរកជំនួយពីអ្នកសម្របសម្រួលក្នុងការដោះស្រាយវិវាទអគារសហកម្មសិទ្ធិ។ ការសម្រួបសម្រួលជាទម្រង់នៃការពិភាក្សា ដែលតម្រូវអ្នកសម្របសម្រួលដើរតួយ៉ាងសំខាន់ក្នុងការវិធីសាស្ត្រនានាដើម្បីផ្ដល់នូវដំណោះស្រាយជូនភាគីនៃវិវាទអគារសហកម្មសិទ្ធិ។ ក្នុងនេះដែរ ដំណើរការនៃការសម្របសម្រួលឆ្លងកាត់ដំណាក់កាលបីមានដូចជា ដំណាក់កាលត្រៀម ដំណាក់កាលចាប់ផ្ដើម និងដំណាក់កាលបញ្ចប់ការសម្របសម្រួល។

### ២.២.១. ការសម្របសម្រួល

"ការសម្របសម្រួល គឺជាដំណើរការដោយស្ម័គ្រចិត្ត និងសម្ងាត់ដែលភាគីទី៣ជាអ្នកអព្យាក្រឹត្យ (ហៅថាអ្នកសម្របសម្រួល) ដើម្បីជួយសម្របសម្រួលឱ្យភាគីទំនាស់អាចពិភាក្សាគ្នាអំពីបញ្ហាតម្រូវការ និងផលប្រយោជន៍របស់ពួកគេ ដើម្បីស្វែងរកដំណោះស្រាយមួយដែលអាចទទួលយកបានទាំងអស់គ្នា"[20]។ ចំពោះដំណោះស្រាយរបស់អ្នកសម្របសម្រួលមិនមែនជាការអនុវត្តដោយបង្ខំនោះទេ ហើយក៏មិនអាចសម្រេចសេចក្ដី

[20] សមាគមអាដហុក ការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា, *ឧបករណ៍សម្រាប់ដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការ*, (២០១៣), ៣។

ជំនួសភាគីវិវាទនៃអគារសហកម្មសិទ្ធិទាំងសងខាងបានដែរ ព្រោះថាអ្នកសម្របសម្រួលមិនមែនជាតួអង្គមានឆន្ទានុសិទ្ធិក្នុងការសម្រេចសេចក្ដីដូចអង្គចៅក្រមនោះទេ។

គួសបញ្ជាក់ផងដែលថា អ្នកសម្របសម្រួលមិនត្រូវប្រកាន់បក្សពួក និងពុករលួយ ក្នុងការជួយសម្របសម្រួលឱ្យភាគីដោះស្រាយវិវាទអគារសហកម្មសិទ្ធិដោយមិនលំអៀង ព្រមទាំងមិនត្រូវមានចេតនាទុច្ចរិតក្នុងការសម្របសម្រួលឡើយ ហើយពុំមានសិទ្ធិអំណាចក្នុងការចាប់បង្ខំឱ្យភាគីយកដំណោះស្រាយណាមួយឡើយ។ ផ្ទុយទៅវិញ ភាគីវិវាទនៃអគារសហកម្មសិទ្ធិនៅតែមានសិទ្ធិអំណាចក្នុងការសម្រេចថាតើខ្លួនចង់ ឬមិនចង់ដោះស្រាយ។ ប្រសិនបើភាគីវិវាទនៃអគារសហកម្មសិទ្ធិមិនចង់ដោះស្រាយ ឬមិនមានការព្រមព្រៀងគ្នានោះគ្មានដំណោះស្រាយឡើយ ទោះជាមានការខិតខំប្រឹងប្រែងរបស់អ្នកសម្របសម្រួលដែលជាអាជ្ញាកណ្ដាលយ៉ាងណាក៏ដោយ។ ដូចនេះហើយ ការសម្របសម្រួល គឺជាការចរចាដែលមានជំនួយ ដែលជំនួយនោះបានមកពីភាគីទី៣ ឬហៅម្យ៉ាងទៀតថាជាអ្នកសម្របសម្រួល។

ដំណោះស្រាយតាមរយៈការសម្របសម្រួល ភាគីវិវាទនៃអគារសហកម្មសិទ្ធិកាត់បន្ថយការចំណាយប្រាក់លើសាហ៊ុយជួលមេធាវី និងសាហ៊ុយផ្សេងទៀត ព្រមទាំងមិនចាំបាច់ត្រូវបង់ពន្ធប្រាក់ប្រដាប់ក្ដីតុលាការដូចការដែលប្ដឹងទៅតុលាការនោះទេ។ បើពិនិត្យលើដំណើរការនៃការសម្របសម្រួលវិញ មានភាពឆាប់រហ័សហើយមិនចាំបាច់រង់ចាំរយៈពេលនៃការសម្រេចក្ដី និងមិនមានភាពស្មុគស្មាញ ដូចការដែលត្រូវដោះស្រាយគ្នាក្នុងប្រព័ន្ធតុលាការទេ។

### ២.២.២. បុគ្គលដែលអាចក្លាយជាអ្នកសម្របសម្រួល

#### ក.ក្រុមប្រឹក្សាភិបាល ឬគណៈកម្មការគ្រប់គ្រងអគារសហកម្មសិទ្ធិ

នៅក្នុងអគារសហកម្មសិទ្ធិអាចមានក្រុមប្រឹក្សាភិបាល ឬគណៈកម្មការគ្រប់គ្រងដែលត្រូវបានជ្រើសតាំងដោយមហាសន្និបាតដែលមានការចូលរួមពីសហកម្មសិទ្ធិករទាំងអស់។[21] ប្រសិនបើសហកម្មសិទ្ធិករនៃអគារសហកម្មសិទ្ធិដែលមានកម្មសិទ្ធិករចាប់ពី៥ ឡើងទៅ ត្រូវរៀបចំអង្គការគ្រប់គ្រងអគារសហកម្មសិទ្ធិ ដោយការបង្កើតជាក្រុមប្រឹក្សាភិបាល ឬគណៈកម្មការគ្រប់គ្រង ដើម្បីទទួលបន្ទុកកិច្ចការសហកម្មសិទ្ធិ។[22] ក្នុងនេះដែរការទទួលបន្ទុកកិច្ចការសហកម្មសិទ្ធិ សំដៅលើការផ្ដល់សិទ្ធិឱ្យក្រុមប្រឹក្សាភិបាល ឬគណៈកម្មការគ្រប់គ្រងជាអ្នកអនុវត្ត និងត្រួតពិនិត្យការគោរពបទញ្ញាផ្ទៃសម្រាប់គ្រប់គ្រង ហើយផ្ដល់នូវសេវាសាធារណៈផ្សេងៗសម្រាប់បម្រើឱ្យសហកម្មសិទ្ធិករទូទៅ ព្រមទាំងជួយដោះស្រាយ និងសម្របសម្រួលមូលហេតុនៃវិវាទដែលកើតមានឡើងនៅក្នុងអគារសហកម្មសិទ្ធិដែលខ្លួនគ្រប់គ្រង ពីសំណាក់ភាគីវិវាទអគារសហកម្មសិទ្ធិសំណូមពរ ឬពឹងពាក់ឱ្យជួយស្វែងរកដំណោះស្រាយ។ ស្របគ្នានេះដែរ អនុក្រឹត្យស្ដីពី ការគ្រប់គ្រង និងប្រើប្រាស់អគារ

[21] ច្បាប់ភូមិបាល, លេខ នស/រកម/០៨០១/១៤, ៣០ សីហា ២០០១, មាត្រា១៨៤។

[22] អនុក្រឹត្យស្ដីពីការគ្រប់គ្រងនិងប្រើប្រាស់អគារសហកម្មសិទ្ធិលេខ១២៦ អនក្រ. បក, មាត្រា៨។

សហកម្មសិទ្ធិ បានកំណត់ថា "វិវាទទាំងឡាយដែលកើតឡើងរវាងសហកម្មសិទ្ធិករនៃអគារសហកម្មសិទ្ធិ ត្រូវដោះស្រាយជាជំហានដំបូងដោយការសម្រុះសម្រួលក្នុងក្របខណ្ឌនៃក្រុមប្រឹក្សាភិបាល ឬគណៈកម្មាធិកាគ្រប់គ្រងអគារសហកម្មសិទ្ធិ"[23]។ នៅក្នុងដំណើរការនេះ ប្រសិនបើការសម្របសម្រួលពីសំណាក់ក្រុមប្រឹក្សាភិបាល ឬគណៈកម្មការគ្រប់គ្រង អាចឈានទៅដល់ការព្រមព្រៀង ពោលគឺការស្របសម្រួលទទួលបានលទ្ធផលជោគជ័យក្នុងការបញ្ចប់វិវាទ នោះក្រុមប្រឹក្សាភិបាល ឬគណៈកម្មការគ្រប់គ្រង អាចធ្វើជាកិច្ចព្រមព្រៀងសះជាជាលាយលក្ខណ៍អក្សរ ឬការព្រមព្រៀងដោយផ្ទាល់មាត់ អាស្រ័យលើកម្មវត្ថុនៃវិវាទអគារសហកម្មសិទ្ធិ ដើម្បីបញ្ជាក់ពីការព្រមព្រៀងបញ្ចប់វិវាទដោយស្ម័គ្រចិត្ត និងពិតប្រាកដ ពីសំណាក់គូភាគីនៃវិវាទអគារសហកម្មសិទ្ធិ ។ ប្រសិនបើក្រុមប្រឹក្សាភិបាល ឬគណៈកម្មការគ្រប់គ្រង ព្យាយាមពិភាក្សាសម្របសម្រួលអស់លទ្ធភាពហើយដូច្នេះក្រុមប្រឹក្សាភិបាល ឬគណៈកម្មការគ្រប់គ្រង ជួយផ្តល់ជាអនុសាសន៍ក្នុងការស្វែងរកវិធីដោះស្រាយផ្សេងៗទៀត ពីសំណាក់បុគ្គលផ្សេងៗ ឬធ្វើបណ្តឹងទៅតុលាការតែម្តង។

### ខ. រដ្ឋបាលឃុំ សង្កាត់

"ឃុំសង្កាត់នីមួយៗត្រូវមានក្រុមប្រឹក្សាមួយហៅថាក្រុមប្រឹក្សាឃុំ សង្កាត់។ ក្រុមប្រឹក្សាឃុំ សង្កាត់ជាអង្គការតំណាងឱ្យប្រជាពលរដ្ឋនៅក្នុងឃុំ សង្កាត់របស់ខ្លួន និងមានបេសកម្មបម្រើផលប្រយោជន៍ទូទៅក្នុងឃុំសង្កាត់របស់ខ្លួន"[24]។ "ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ជាមេឃុំ ចៅសង្កាត់"[25] ដែលក្នុងនោះ មេឃុំ ចៅសង្កាត់ក្នុងឋានៈតំណាងឱ្យប្រជាពលរដ្ឋ មានតួនាទី និងភារកិច្ចការពារផលប្រយោជន៍ប្រជាពលរដ្ឋដែលរស់នៅក្នុងឃុំសង្កាត់ និងគោរពការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋរបស់ខ្លួនក្នុងមូលដ្ឋាន។[26] ជាមួយគ្នានេះនៅពេលដែលប្រជាពលរដ្ឋក្នុងមូលដ្ឋានមានវិវាទកើតឡើង ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ឆ្នាំ២០០១ បានផ្តល់សិទ្ធិឱ្យរដ្ឋបាលឃុំ សង្កាត់ ដែលជាអ្នកមានតួនាទីបម្រើកិច្ចការមូលដ្ឋានមានភារកិច្ច "សំរបសំរួលទស្សនៈរបស់ប្រជាពលរដ្ឋដើម្បីឱ្យមានការយោគយល់អធ្យាស្រ័យទៅវិញទៅមក"[27]។ ក្នុងកិច្ចការងារសម្របសម្រួលនេះដែរ ឃុំ សង្កាត់ មានគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ ដែលមានតួនាទីចម្បងពីររួមមាន ជួយឃុំសង្កាត់ ក្នុងការផ្សះផ្សាវិវាទ និងផ្តល់យោបល់ ជួយកិច្ចការនានាតាមការចាំបាច់។[28]

[23] អនុក្រឹត្យស្តីពីការគ្រប់គ្រង និងប្រើប្រាស់អគារសហកម្មសិទ្ធិលេខ១២៦ អនក្រ. បក, ប្រការ៧។

[24] ច្បាប់ស្តីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់, លេខ នស/រកម/០៣០១/០៥, ២៨ កុម្ភៈ ២០០១, មាត្រា៩ (ពីពេលនេះតទៅហៅថា ច្បាប់ស្តីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ឆ្នាំ២០០១)។

[25] ច្បាប់ស្តីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ឆ្នាំ២០០១, មាត្រា២៥។

[26] ហៀង សាង, *នីតិរដ្ឋបាលទូទៅ*, បោះពុម្ពលើកទី៤ (ភ្នំពេញ៖ ស៊ីហេង, ២០១៧), ១៩៥។

[27] ច្បាប់ស្តីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ឆ្នាំ២០០១, មាត្រា៤៣។

[28] គណៈកម្មការនីតិកម្ម និងយុត្តិធម៌ព្រឹទ្ធសភា និងលេខាធិការដ្ឋានអមគណៈកម្មការនីតិកម្ម និងយុត្តិធម៌ព្រឹទ្ធសភា, ចងក្រង, *ឯកសារជំនួយស្មារតីស្តីពីការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅឃុំ សង្កាត់* (២០១៧), ៥។

ពាក់ព័ន្ធជុំវិញបញ្ហាខាងលើ វិវាទរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋានកើតឡើងជាច្រើន មានលក្ខណៈចម្រុះ ប៉ុន្តែសហកម្មសិទ្ធិករ និងភាគីនៃវិវាទអគារសហកម្មសិទ្ធិផ្សេងទៀត ក៏ជាប្រជាពលរដ្ឋដែលរស់នៅក្នុងមូលដ្ឋានដែរ។ អញ្ចឹងហើយមូលហេតុវិវាទនៃអគារសហកម្មសិទ្ធិ ក៏នៅក្នុងចំណោមវិវាទនោះដែរ បើដូច្នេះមូលហេតុវិវាទនៃអគារសហកម្មសិទ្ធិដែលកើតឡើងក្នុងរដ្ឋបាលដែនដីឃុំ សង្កាត់ទាំងឡាយ នោះឃុំ សង្កាត់ក្នុងដែនដីដែលមានសមត្ថកិច្ចមានសិទ្ធិអាចជួយដោះស្រាយវិវាទអគារសហកម្មសិទ្ធិផងដែរ។ ដូចនេះហើយ ឃុំ សង្កាត់ ត្រូវចាត់វិធានការសមស្រប ដើម្បីដោះស្រាយវិវាទនៅមូលដ្ឋានដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួនក្នុងករណីមានសំណូរពរនានាពីប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ឃុំ សង្កាត់ត្រូវពិនិត្យ និងដោះស្រាយសំណូមពរឱ្យបានសមស្រម ក្នុងករណីដែលសំណូមពរ នោះស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ឃុំ សង្កាត់ត្រូវចាត់វិធានការដោះស្រាយ រួចហើយត្រូវជូនដំណឹងទៅប្រជាពលរដ្ឋ និងធ្វើសេចក្តីរាយការណ៍ជូនក្រសួង ស្ថាប័នមានសមត្ថកិច្ច ឬក្រុមប្រឹក្សាដែលពាក់ព័ន្ធដើម្បីដោះស្រាយ។

ចំពោះវិវាទដែលមានលក្ខណៈឯកជនត្រូវបាន ដោះស្រាយដោយផ្អែកតាមពាក្យបណ្តឹងរបស់ភាគីដាក់ទៅរដ្ឋបាលឃុំសង្កាត់ដើម្បីធ្វើការផ្សះផ្សា និងសម្រុះសម្រួលដោះស្រាយ។ នៅក្នុងដំណាក់កាលនេះ ប្រសិនបើការសម្របសម្រួលពីសំណាក់ រដ្ឋបាលឃុំ សង្កាត់ ទទួលបានលទ្ធផលជោគជ័យក្នុងការបញ្ចប់វិវាទ នោះការព្រមព្រៀងក្នុងការបញ្ចប់ ក្នុងករណីខ្លះ អាចធ្វើឡើងជាលិខិតលាយលក្ខណ៍អក្សរ ឬកំណត់ហេតុដើម្បីបញ្ជាក់ពីការព្រមព្រៀងបញ្ចប់វិវាទដោយស្ម័គ្រចិត្ត និងពិតប្រាកដ ពីសំណាក់គូភាគីនៃវិវាទអគារសហកម្មសិទ្ធិ ដោយកំណត់អំពីលក្ខខណ្ឌក្នុងនោះផងដែរ។ ប្រសិនបើ មេឃុំ ចៅសង្កាត់ ឬគណៈកម្មាធិការដោះស្រាយទំនាស់ឃុំសង្កាត់ ព្យាយាមពន្យល់ឱ្យមានការផ្សះផ្សាគ្នាអស់លទ្ធភាពហើយ នោះមេឃុំ ចៅសង្កាត់ ឬគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ ណែនាំភាគីនៃវិវាទអគារសហកម្មសិទ្ធិឱ្យធ្វើសំណើទៅអាជ្ញាដែលពាក់ព័ន្ធ ឬធ្វើបណ្តឹងទៅតុលាការ។

### គ. បុគ្គលផ្សេងទៀតដែលអាចក្លាយជាអ្នកសម្របសម្រួល

បុគ្គលផ្សេងៗទៀតដែលអាចក្លាយជាអ្នកសម្របសម្រួលសំដៅលើ បុគ្គលទាំងឡាយ ដែលមានសិទ្ធិក្នុងការសម្របសម្រួលលើវិវាទក្រៅអំពីក្រុមប្រឹក្សាភិបាល ឬគណៈកម្មការគ្រប់គ្រង ឬអាជ្ញាធរមានសមត្ថកិច្ចដែលក្នុងច្បាប់បានផ្តល់នូវសិទ្ធិ និងតួនាទី ល្គឹកណាត្រូវបានភាគីនៃវិវាទទាំងសងយល់ព្រមឯកភាពគ្នាផ្តល់សិទ្ធិឱ្យបុគ្គលនោះជួយក្នុងការសម្របសម្រួល ក្នុងការស្វែងរកដំណោះស្រាយបញ្ចប់វិវាទ។ ត្រង់ចំណុចនេះ បុគ្គលទាំងនោះ រួមមាន ប្រជាពលរដ្ឋទូទៅ ដែលត្រូវបានភាគីនៃវិវាទជ្រើសរើសរហូតមានការឯកភាពគ្នារវាងភាគីទាំងពីរអាចជា សាច់ញាតិ ចាស់ទុំ អាចារ្យវត្ត ព្រះសង្ឃ គ្រូបង្រៀន មេធាវី។ល។[29]

---

[29] សមាគមអាដហុក ការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា, *ឧបករណ៍សម្រាប់ដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការ*, (២០១៣), ២៣។

### ២.២.៣. តួនាទីរបស់អ្នកសម្របសម្រួល

អ្នកសម្របសម្រួលដើរតួយ៉ាងសំខាន់ណាស់ក្នុងកិច្ចសម្របសម្រួល។ ដូច្នេះអ្នកសម្របសម្រួលត្រូវដឹងពីតួនាទីរបស់ខ្លួនក្នុងនាមជាអ្នកសម្របសម្រួល ដើម្បីកុំឱ្យប្រាស់ចាកពីអ្នកសម្របសម្រួលទៅជាអ្នកអាកាត់សេចក្ដីជំនួសភាគី។ តួនាទីចម្បងៗរបស់អ្នកសម្របសម្រួលនោះរួមមាន ការប្រើប្រាស់ជំនាញ និងទេពកោសល្យដើម្បីធ្វើឱ្យគូរភាគីនៃអគារសហកម្មសិទ្ធិបានជួបគ្នាក្នុងកិច្ចពិភាក្សា និងស្វែងរកយុទ្ធិសាស្ត្រថ្មីៗ ដែលមានលក្ខណៈសមស្រប ក្នុងការស្វែងរកដំណោះស្រាយប្រកបដោយភាពយុត្តិធម៌ និងគំនិតច្នៃប្រឌិត ព្រមទាំងជួយផ្ដល់ជាទស្សនាទាន និងលើកទឹកចិត្តដល់ភាគីក្នុងស្រុះស្រួលគ្នា ទោះជានៅក្នុងស្ថានភាពតានតឹងប៉ុនណាដោយផ្ដល់នូវគំនិតអប់រំក្នុងការពិចារណាអំពីការសម្របសម្រួលគ្នា និងផលវិបាកដែលកើតចេញពីការបន្តវិវាទរវាងគ្នានឹងគ្នា។[30]

### ២.២.៤. ដំណើរការនៃការសម្របសម្រួល

#### ២.២.៤.១. ដំណាក់កាលត្រៀម

ការស្របសម្រួលអាចប្រព្រឹត្តឡើងបាន លុះត្រាណាទាល់តែសហកម្មសិទ្ធិករ និងភាគម្ខាងទៀតនៃវិវាទអគារសហកម្មសិទ្ធិ មានការឯកភាពគ្នាដោយទទួលយកនូវការសម្របសម្រួលពីសំណាក់ភាគីទីបីដែលជាអ្នកសម្របសម្រួល។[31] សហកម្មសិទ្ធិករដែលមានបំណងធ្វើការចរចាដោយមានជំនួយពីអ្នកសម្របសម្រួលត្រូវស្វែងរកអ្នកសម្របសម្រួលមួយណា ដែលអាចមានលទ្ធភាពជួយស្រុះស្រួលគ្នាបាន ហើយផ្ដល់ព័ត៌មានអំពីមូលហេតុនៃវិវាទឱ្យច្បាស់លាស់ ទៅកាន់អ្នកសម្របសម្រួល។ អ្នកសម្រុះសម្រួលធ្វើការសិក្សាប្រភេទវិវាទឱ្យច្បាស់លាស់ ថាតើវិវាទដែលបានកើតឡើងនោះជាវិវាទដែលច្បាប់អនុញ្ញាតឱ្យធ្វើការសម្របសម្រួលដែរឬទេ? ជាគោលការណ៍មានតែវិវាទទាក់ទងរឿងរដ្ឋប្បវេណីទេ ដែលអាចធ្វើការសម្រុះសម្រួលបាន។[32]

ជាបឋម អ្នកសម្រួលសម្រួលត្រូវជូនដំណឹងស្ដីអំពីមូលហេតុនៃវិវាទទៅកាន់សហកម្មសិទ្ធិករម្ខាងទៀតដែលពាក់ព័ន្ធនឹងចំណុចវិវាទនោះ ដើម្បីជាការអញ្ជើញភាគីនៃវិវាទម្ខាងទៀតឱ្យមកចូលរួមក្នុងការសម្របសម្រួល ព្រមទាំងស្ទង់មើលឆន្ទៈរបស់ភាគីម្ខាងទៀតចង់ស្វែងរកដំណោះស្រាយតាមការសម្របសម្រួលដែរឬទេ? ករណីភាគីម្ខាងទៀត យល់ព្រមតបការអញ្ជើញ នេះជាឱកាសមួយឱ្យភាគីទាំងសងខាងរៀបចំខ្លួនត្រៀមឆ្លើយតបនឹងចំណុចនៃវិវាទត្រលប់ទៅវិញ។ ផ្ទុយទៅវិញ ប្រសិនបើភាគីម្ខាងទៀតបានបដិសេដចំពោះការអញ្ជើញនោះការសម្របសម្រួលមិនអាចប្រព្រឹត្តឡើងបានទេ។ នៅក្នុងការអញ្ជើញនេះ អ្នកសម្របសម្រួលអាចកំណត់កាលបរិច្ឆេទ ពេលវេលា និងទីកន្លែងណាមួយ ឱ្យបានច្បាស់លាស់ ដែលអាចឱ្យសហកម្មសិទ្ធិករដែលជា

[30] សមាគមអាដហុក ការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា, *ឧបករណ៍សម្រាប់ដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការ*, (២០១៣), ៥។
[31] សមាគមអាដហុក ការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា, *ឧបករណ៍សម្រាប់ដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការ*, (២០១៣), ៨។
[32] សមាគមអាដហុក ការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា, *ឧបករណ៍សម្រាប់ដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការ*, (២០១៣), ២៧។

ភាគីវិវាទទាំងសងខាងចូលរួមក្នុងការសម្របសម្រួលបាន ដោយប្រើប្រាស់មធ្យោបាយនៃការអញ្ជើញមានច្រើនប្រភេទរួមមាន អាចអញ្ជើញដោយផ្ទាល់មាត់ តាមរយៈលិខិតលាយលក្ខណ៍អក្សរ ឬតាមរយៈទូរសព្ទ ឬតាមរយៈប្រព័ន្ធទំនាក់ទំនងសង្គម និងមធ្យោបាយផ្សេងៗ។[33] សម្រាប់គណៈកម្មការគ្រប់គ្រងអគារសហកម្មសិទ្ធិ ឬបុគ្គលផ្សេងទៀតដែលអាចក្លាយជាអ្នកសម្របសម្រួលអាចប្រើប្រាស់មធ្យោយខាងលើមួយណាក៏បាន ឱ្យតែមានភាពងាយស្រួយ និងប្រសិទ្ធភាព ចំណែកឯការអញ្ជើញរបស់អាជ្ញាធរមានសមត្ថកិច្ច ឃុំ សង្កាត់ វិញ អាចប្រើប្រាស់ការអញ្ជើញជាផ្លូវការមានដូចជា លិខិតកោះហៅ ឬលិខិតអញ្ជើញតាមផ្លូវរដ្ឋបាល ជាមធ្យោយដើម្បីជូនដំណឹងដើម្បីឱ្យភាគីណាមួយចូលរួមដោះស្រាយវិវាទអគារសហកម្មសិទ្ធិ។ ប៉ុន្តែក្នុងស្ថានភាពមួយចំនួនការអញ្ជើញដែលមានលក្ខណៈសាមញ្ញ តាមរយៈដោយផ្ទាល់មាត់ ឬតាមទូរសព្ទ ឬប្រព័ន្ធទំនាក់ទំនងសង្គមក៏អាចធ្វើឡើងបានដែរ។ ក្នុងនោះផងដែរ អ្នកសម្របសម្រួលធ្វើយ៉ាងណាឱ្យភាគីនៃវិវាទអគារសហកម្មសិទ្ធិចូលមករកការសម្របសម្រួលជាមួយគ្នាដោយស្ម័គ្រចិត្ត តាមលទ្ធភាពដែលអាចធ្វើបាន ព្រោះថានៅពេលដែលភាគីនៃវិវាទអគារសហកម្មសិទ្ធិណាម្ខាងមានវិវាទនឹងគ្នាហើយនោះ ប្រាកដជាមានភាគីនៃវិវាទម្ខាងទៀតអគារសហកម្មសិទ្ធិណាមួយពុំសូវមានឆន្ទៈចង់ចូលរួមក្នុងការសម្របសម្រួលជាមួយគ្នានោះទេ។ ដូនេះហើយអ្នកសម្របសម្រួលត្រូវប្រើប្រាស់នូវទេពកោសល្យ វិធីសាស្ត្រ ឬមធ្យោបាយផ្សេងៗ ដើម្បីធ្វើយ៉ាងណាឱ្យភាគីវិវាទអាចខិតចូលជិតគ្នា និងឈានទៅដល់ការជួបពិភាក្សាគ្នា។

**២.២.៤.២. ដំណាក់កាលចាប់ផ្តើម**

នៅក្នុងដំណាក់នេះ ករណីដែលភាគីនៃវិវាទទាំងសងខាងបានចូលរួមក្នុងកិច្ចសម្របសម្រួលនៅចំពោះមុខគ្នា អ្នកសម្រុះសម្រួលត្រូវស្តាប់ភាគីនៃវិវាទទាំងសងខាងឱ្យបានស្មើៗគ្នា ពាក់ព័ន្ធនឹងការលើកឡើងអំពីបញ្ហាវិវាទអគារសហកម្មសិទ្ធិ រួមទាំងគោលបំណងដែលភាគីនីមួយៗទាមទារចង់បាន។[34] មានន័យថានៅក្នុងដំណើរការសម្របសម្រួល ជាបឋម អ្នកសម្របសម្រួលឱ្យភាគីនៃវិវាទធ្វើសេចក្តីអះអាងបំភ្លឺរៀបរាប់អំពីអង្គហេតុនៃវិវាទដែលម្នាក់ៗយល់ឃើញ ព្រមទាំងបង្ហាញនូវភស្តុតាង ដើម្បីដាក់បង្ហាញអំពីការពិតនៃការបង្កវិវាទអគារសហកម្មសិទ្ធិ និងអ្នកណាជាអ្នកទទួលខុសត្រូវ។ អ្នកសម្របសម្រួលត្រូវគ្រប់គ្រងស្ថានភាពនេះឱ្យបានល្អប្រសើរដោយធានាកិច្ចពិភាក្សាប្រកបដោយភាពវិជ្ជមាន មានក្រមសីលធម៌ និងធម៌អហិង្សា។[35] ជាមួយគ្នានេះដែរក្នុងករណីខ្លះ អ្នកសម្រុះសម្រួលត្រូវធានាព័ត៌មានដែលទទួលបានត្រូវលាក់ទុកជាអាថ៌កំបាំង ធ្វើយ៉ាងនេះគឺដើម្បីរក្សាកិត្តិយសភាគីនីមួយៗ ហើយអាចឱ្យភាគីហ៊ានបង្ហាញប្រាប់អំពីការពិត ព្រោះពួកគេមានជំនឿចិត្តថាអ្នកសម្រុះសម្រួលនឹងមិនយករឿងរ៉ាវរបស់ភាគីណាមួយ ឱ្យអ្នកផ្សេងទៀតបានដឹង។ មួយវិញទៀតក្នុងករណី

[33] សមាគមអាដហុក ការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា, *ឧបករណ៍សម្រាប់ដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការ*, (២០១៣), ៧។

[34] សមាគមអាដហុក ការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា, *ឧបករណ៍សម្រាប់ដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការ*, (២០១៣), ១១។

[35] សមាគមអាដហុក ការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា, *ឧបករណ៍សម្រាប់ដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការ*, (២០១៣), ១៤។

ដែលស្មុគស្មាញ អ្នកសម្របសម្រួល អាចស្នើសុំឱ្យភាគីផ្តល់ព័ត៌មានជាលាយលក្ខណ៍អក្សរដែលពន្យល់អំពីអង្គហេតុ និងភស្តុតាងនានា រួមមានឯកសារ សាក្សី ដើម្បីយកមកពិចារណា ថាតើគួរត្រូវធ្វើរបៀបដូចម្តេចក្នុងការជួយស្វែងរកដំណោះស្រាយ។[36]

បន្ទាប់ពីភាគីលើកឡើងនូវមូលហេតុនៃវិវាទអគារសហកម្មសិទ្ធិរួចហើយ អ្នកសម្របសម្រួលត្រូវផ្តល់ជាយោបល់ អំពីគំនិត និងទស្សនៈ ចំពោះដំណោះស្រាយជុំវិញលើបញ្ហាទាំងនោះ ដោយព្យាយាមពន្យល់ និងបញ្ចុះបញ្ចូល ភាគីនៃវិវាទទាំងសងខាងឱ្យសម្រុះសម្រួលគ្នា ព្រមទាំងជួយភាគីនីមួយៗ ឱ្យប្តូរពីជំហរ ដែលកំណត់ទុកមុន ទៅជាជម្រើសផ្សេងៗ ដែលមានលក្ខណៈប្រាកដប្រជា និងមិនលំអៀងវិញ។ អ្នកសម្របសម្រួលជួយបង្កើតជម្រើសផ្សេងៗនៃដំណោះស្រាយ និងលើកទឹកចិត្ត ដល់គូភាគីឱ្យព្យាយាមក្នុងការចរចាគ្នាផ្អែកលើផលប្រយោជន៍រួមឱ្យអស់លទ្ធភាព តែមិនត្រូវបង្ខិតបង្ខំភាគីណាមួយឱ្យទទួលយកដំណោះស្រាយខ្លួនទេ។ [37]

ជារួមមក អ្នកសម្របសម្រួលជួយភាគីនៃវិវាទ ឱ្យរកដំណោះស្រាយដោយខ្លួនឯង ដោយឆន្ទៈផ្ទាល់ ហើយត្រូវគ្រប់គ្រងដំណើរការនៃការសម្របសម្រួល ធ្វើយ៉ាងណាឱ្យភាគីទាំងពីរ អាចចរចារកដំណះស្រាយបញ្ចប់វិវាទអគារសហកម្មសិទ្ធិ។

**២.២.៤.៣. ដំណាក់កាលបញ្ចប់**

ក្រោយពីបានឆ្លងកាត់ដំណាក់កាលចាប់ផ្តើម និងដំណាក់កាលត្រៀមចប់សព្វគ្រប់រួចមក ដំណាក់កាលចុងក្រោយនោះគឺជាដំណាក់កាលបញ្ចប់ ដែលដំណាក់បញ្ចប់នេះមានពីរករណីធំៗ គឺករណីដែលភាគីនៃវិវាទអគារសហកម្មសិទ្ធិព្រមព្រៀងគ្នាបញ្ចប់វិវាទ និងករណីដែលភាគីមិនយល់ស្របគ្នាក្នុងការបញ្ចប់វិវាទ។

ករណីទីមួយ ប្រសិនបើភាគីនៃវិវាទអគារសហកម្មសិទ្ធិមានការស្រុះស្រួលគ្នាក្នុងការបញ្ចប់វិវាទអគារសហកម្មសិទ្ធិដោយផ្អែកលើ ការយោគយល់អធ្យាស្រ័យគ្នា និងផលប្រយោជន៍រួម ដែលកើតចេញពីការជួយភាគីពិភាក្សាគ្នាពីសំណាក់អ្នកសម្របសម្រួល នោះការសម្របសម្រួលគឺទទួលបាននូវភាពជោគជ័យ ក្នុងការស្វែងរកដំណោះស្រាយរួមមួយដែលសមស្រប និងអាចទទួលយកបានពីភាគីទាំងសងខាង ដើម្បីបញ្ចប់វិវាទអគារសហកម្មសិទ្ធិ។ បន្ទាប់ពីភាគីនៃវិវាទឯកភាពគ្នាទទួលយកលើលក្ខខណ្ឌមួយចំនួន ដែលមាននៅក្នុងដំណោះស្រាយដោយស្ម័គ្រចិត្ត ដើម្បីបញ្ចប់វិវាទអគារសហកម្មសិទ្ធិរួចមក អ្នកសម្របសម្រួលត្រូវធ្វើយ៉ាងណាដើម្បីឱ្យការព្រមព្រៀងនោះធានាបាននូវអនុភាពអនុវត្តប្រកបដោយប្រសិទ្ធភាព និងមានការទទួលស្គាល់ដោយច្បាប់ ជៀសវាងបង្កើតទំនាស់នៅពេលក្រោយ អ្នកសម្របសម្រួលយកលទ្ធផលនៃដំណោះស្រាយ មកបំពេញ

[36] ស៊្មីវិន អ៊ែម អូស៊្មីរមីឡឺរ៍, *ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការប្រទេសកម្ពុជា៖ សៀវភៅសិក្សាស្តីពីទស្សនាទានសំខាន់ៗ*, បោះពុម្ពលើកទី២ (រាជធានីភ្នំពេញ, ២០១០), ១០៩។

[37] សមាគមអាដហុក ការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា, *ឧបករណ៍សម្រាប់ដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការ*, (២០១៣), ២៣។

ជាទម្រង់លិខិតលាយលក្ខណ៍អក្សរ។[38] ប៉ុន្តែកម្មវត្ថុនៃវិវាទខ្លះ ទោះបីជាមានតម្លៃប៉ុនណាក៏ដោយ ការព្រមព្រៀងដោយផ្ទាល់មិនមែនជាមធ្យោបាយដ៏ល្អនោះទេ ដោយសារតែភាពមិនអាចទុកចិត្តបាន។ ផ្ទុយទៅវិញបើក្នុងករណីដែលភាគីខ្វែងគំនិតគ្នា ឬប្រកាន់គោលជំហរចង់ឈ្នះ ចង់ចាញ់រៀងៗខ្លួន នោះវិវាទក៏ពុំអាចបញ្ចប់ត្រឹមការសម្របសម្រួលក្រៅប្រព័ន្ធតុលាការបានដែរ។

[38] សមាគមអាដហុក ការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា, *ឧបករណ៍សម្រាប់ដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការ*, (២០១៣), ២៤។

# ជំពូកទី៣

# នីតិវិធីដោះស្រាយវិវាទអគារសហកម្មសិទ្ធិក្នុងប្រព័ន្ធតុលាការ

ក្រោយពីធ្វើការដោះស្រាយវិវាទអគារសហកម្មសិទ្ធិដោយភាគីនៃវិវាទផ្ទាល់ និងការដោះស្រាយដោយអ្នកសម្របសម្រួលរួចមក នៅតែមិនអាចបញ្ចប់វិវាទនោះបានទៀត ជាជម្រើសចុងក្រោយមានតែមធ្យោបាយប្តឹងទៅតុលាការ ដើម្បីឱ្យជួយការពារសិទ្ធិស្របច្បាប់របស់ភាគីនៃវិវាទអគារសហកម្មសិទ្ធិដែលត្រូវបានបំពាន និងដោះស្រាយវិវាទតាមបែបការអនុវត្តដោយបង្ខំ។ ការប្តឹងទៅតុលាការ ត្រូវគោរពនូវកាតព្វកិច្ចអនុវត្តសកម្មភាពបណ្តឹង និងចូលរួមនិតិវិធិជាច្រើន ព្រមទាំងត្រូវបង់ប្រាក់ប្រដាប់ក្តីតុលាការ ទម្រាំតែទទួលបាននូវសេក្តីសម្រេចពីតុលាការ។ ដូចនេះហើយ ជំពូកនេះរៀបរាប់អំពី ប្រធាននៃបណ្តឹង អត្ថន័យបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធអគារសហកម្មសិទ្ធិ និងការជំនុំជម្រះលើបណ្តឹង។

## ៣.១. ប្រធាននៃបណ្តឹង

ដើម្បីជៀសវាងការបាត់បង់សុពលភាពនៃបណ្តឹងដែលធ្វើឡើងដោយដើមចោទ ដែលប្តឹងទៅតុលាការ ហើយតុលាការមិនអាចចេញសេចក្តីសម្រេចតាមការទាមទាររបស់ដើមចោទ។ ដូចនេះ បណ្តឹងរបស់ដើមចោទត្រូវដាក់ទៅ តុលាការដែលមានសមត្ថកិច្ចជំនុំជម្រះ ហើយបណ្តឹងនោះត្រូវធ្វើឡើងដោយបុគ្គលមានសមត្ថភាពធ្វើសកម្មភាពនៃបណ្តឹង ប្រសិនបើដើមចោទគ្មានសមត្ថភាពក្នុងការធ្វើសកម្មភាពនៃបណ្តឹងទេ បណ្តឹងនោះត្រូវធ្វើឡើងដោយអ្នកតំណាងតាមផ្លូវបណ្តឹង។

### ៣.១.១. សមត្ថកិច្ចតុលាការ

តុលាការដែលមានសមត្ថកិច្ចគឺជាតុលាការដែលអាចទទួលដោយស្របច្បាប់នូវពាក្យសុំ និងពាក្យបណ្តឹងដើម្បីវិនិច្ឆ័យលើរឿងក្តី និងចេញសេចក្តីសម្រេចនានា។[39]ចំពោះក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ បានកំណត់អំពីប្រភេទនៃសមត្ថកិច្ចរបស់តុលាការមួយចំនួនរួមមាន សមត្ថកិច្ចទី១កំណត់តាមភារកិច្ច[40] សមត្ថកិច្ចទី២កំណត់តាមដែនដីដែលក្នុងនោះត្រូវបែងចែកបន្តទៀតអំពី សមត្ថកិច្ចដែលកំណត់តាមលំនៅដ្ឋានចុងចម្លើយ[41] សមត្ថកិច្ចដែលកំណត់ទៅតាមទ្រព្យសម្បត្តិ ទីកន្លែងអនុវត្តកាតព្វកិច្ច ឬទីកន្លែងអចនលវត្ថុតាំងនៅ[42] និងសមត្ថកិច្ចរឿងក្តីដែលពាក់ព័ន្ធនឹងការទាមទារច្រើនចំណុច[43] និងសមត្ថកិច្ចទី៣តាមការព្រមព្រៀង[44]។

---

[39] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៧ (ចាប់ពីពេលនេះទៅហៅថាក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦)។

[40] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រៀងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, *សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី*, ១៖ ១៤។

[41] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា៨។

[42] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា៩។

[43] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា១១។

[44] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា១៣។

សហកម្មសិទ្ធិករដែលមានបំណងចង់ប្តឹងទៅតុលាការ ដើម្បីពឹងពាក់ឱ្យតុលាការជួយដោះស្រាយវិវាទរបស់ខ្លួន សហកម្មសិទ្ធិករត្រូវជ្រើសរើសប្រភេទនៃសមត្ថកិច្ចណាមួយខាងលើ ដែលតុលាការតាំងទី ទើបអាចឱ្យតុលាការនោះមានសិទ្ធិអំណាចក្នុងការដោះស្រាយ។ មិនត្រឹមតែប៉ុណ្ណោះ ប្រភេទនៃសមត្ថកិច្ចតុលាការ បានផ្តល់នូវភាពងាយស្រួល និងផលប្រយោជន៍ជាច្រើន ដល់ភាគីខាងសហកម្មសិទ្ធិករ និងភាគីម្ខាងទៀតនៃវិវាទក្នុងការធ្វើដំណើរទៅតុលាការដើម្បីបំពេញនីតិវិធី។

ឧទាហរណ៍ សហកម្មសិទ្ធិករដែលមានបំណងចង់ប្តឹង ភាគីម្ខាងទៀតនៃវិវាទអគារសហកម្មសិទ្ធិទៅកាន់តុលាការ សហកម្មសិទ្ធិករដែលជាដើមចោទ មុននឹងប្តឹង ចាំបាច់ត្រូវដឹងអំពីឈ្មោះ និងអាសយដ្ឋានរស់នៅរបស់ភាគីម្ខាងទៀតនៅឯណាឱ្យបានច្បាស់លាស់ ឬមួយក៏ទីកន្លែងដែលកើតមានឡើងវិវាទជាមួយគ្នា ទីកន្លែងដែលធ្វើកិច្ចសន្យានៅកន្លែងណា។

### ៣.១.២. ភាគី

ភាគីជាបុគ្គលទាំងឡាយដែលទាមទារនូវសេចក្តីសម្រេចរបស់តុលាការក្នុងនាមខ្លួន ដើម្បីដោះស្រាយវិវាទហៅថាដើមចោទ ចំណែកឯបុគ្គលដែលត្រូវបានទាមទារឱ្យចង្អុលឈ្មោះ ក្នុងសេចក្តីសម្រេចនោះហៅថាចុងចម្លើយ។ [45] ជាពិសេសភាគីត្រូវបានសរសេរបញ្ជាក់នៅក្នុងលិខិតនៃបណ្តឹង។ [46] ដើម្បីឱ្យសហកម្មសិទ្ធិករដែលជាភាគីមានសិទ្ធធ្វើសកម្មភាពនៃបណ្តឹង ឬទទួលសកម្មភាពបណ្តឹងរបស់តុលាការ ឬភាគីម្ខាងទៀតបានស្របច្បាប់លុះត្រាតែភាគីគោរពនូវលក្ខខណ្ឌមួយចំនួនដែលក្នុងក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ បានកំណត់អំពីសមត្ថភាពភាគី និងសមត្ថភាពក្នុងការធ្វើបណ្តឹង។

ក្នុងនេះដែរ សមត្ថភាពភាគីជាលក្ខណៈសម្បត្តិទូទៅដែលអាចក្លាយជាភាគីត្រូវមានទំនាក់ទំនងនៅក្នុងមូលហេតុវិវាទ និងមានទំនាក់ទំនងគត្តិយុត្តជាមួយគ្នាដូចជាកិច្ចសន្យាជាដើម ឬមានសិទ្ធ និងករណីយកិច្ចទទួលស្គាល់តាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី និងច្បាប់ផ្សេងទៀត អាចជាដើមចោទ ឬចុងចម្លើយនៅក្នុងបណ្តឹងរដ្ឋប្បវេណី។[47] ចំណែកឯសមត្ថភាពក្នុងការធ្វើបណ្តឹងគឺជាបុគ្គលដែលមានសមត្ថភាពធ្វើសកម្មភាពដោយខ្លួនឯងតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី និងច្បាប់ផ្សេងទៀត ក្នុងការធ្វើសកម្មភាពបណ្តឹង តួយ៉ាង អាចដាក់ពាក្យបណ្តឹង ឬអាចឆ្លើយដោះសាចំពោះបណ្តឹងដោយខ្លួនឯង និងសកម្មភាពបណ្តឹងផ្សេងទៀត។[48] ចំពោះជនដែលត្រូវបានកម្រិតសមត្ថភាពសំដៅដល់ អនីតិជន ជននៅក្រោមអាណាព្យាបាលទូទៅ និងជននៅក្រោមហិតូបត្ថម្ភ។ [49] ចំពោះអនីតិជន និងជននៅក្រោមអាណាព្យាបាលទូទៅ ពុំមានសមត្ថភាពក្នុងការធ្វើបណ្តឹងនោះទេ ដោយបណ្តឹង

---

[45] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, *សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី*, ១៖ ២២។

[46] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា៧៥។

[47] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, *សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី*, ១៖ ២៤។

[48] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា៣២។

[49] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១៦។

ត្រូវឡើងដោយអ្នកតំណាងតាមច្បាប់កំណត់។ រីឯកជននៅក្រោមហិតូបត្ថម្ភមានលក្ខណៈពិសេស ត្រង់ថាមានសមត្ថភាពក្នុងការធ្វើបណ្ដឹងដោយខ្លួនឯង មិនចាំបាច់មានការយល់ព្រមពីហិតូបត្ថម្ភកៈនោះទេ។[50] លើសពីនេះទៀតជនបរទេសណាក៏ដោយ ឱ្យតែមានសមត្ថភាពក្នុងការធ្វើបណ្ដឹងស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ជនបរទេសនោះអាចមានសិទ្ធិធ្វើសកម្មភាពបណ្ដឹង។[51]

### ៣.១.៣. អ្នកតំណាង

អ្នកតំណាងតាមផ្លូវបណ្ដឹងគឺជាអ្នកធ្វើសកម្មភាពបណ្ដឹង ឬទទួលនូវសកម្មភាពបណ្ដឹងរបស់តុលាការ ឬភាគីម្ខាងទៀតដោយលើឆន្ទៈរបស់ខ្លួនក្នុងនាមជាភាគី ហើយធ្វើសកម្មភាពជំនួសភាគី។[52] អ្នកតំណាងតាមផ្លូវបណ្ដឹងបែងចែកជាពីរប្រភេទរួមមាន អ្នកតំណាងដែលច្បាប់បានកំណត់ និងអ្នកតំណាងដោយអាណត្តិ។ អ្នកតំណាងដែលច្បាប់បានកំណត់ត្រូវបែងចែកជាពីរប្រភេទទៀតគឺ អ្នកតំណាងពិសេស[53] និងអ្នកតំណាងតាមផ្លូវច្បាប់សារធាតុមានដូចជា ជនដែលមានសិទ្ធិអំណាចមេបា ឬអ្នកអាណាព្យាបាលទូទៅជាដើម ។ អ្នកតំណាងដោយអាណត្តិរួមមាន មេធាវី តតិយជន និងតំណាងស្ថាប័នរដ្ឋ។[54]

## ៣.២. អំពីបណ្ដឹងរដ្ឋប្បវេណី

ក្រោយពីបានដឹងអំពីប្រធាននៃបណ្ដឹងរួមមក ភាគីនៃវិវាទអគារសហកម្មសិទ្ធិដែលជាដើមចោទ ត្រូវធ្វើបណ្ដឹង ដោយគោរពលក្ខខណ្ឌដែលច្បាប់បានកំណត់រួមមាន ចំណុចសំខាន់ៗដែលត្រូវសរសេរក្នុងពាក្យបណ្ដឹង និងរបៀបនៃការដាក់ពាក្យបណ្ដឹង ជាលក្ខខណ្ឌចាំបាច់ ដើម្បីជៀសវាងបណ្ដឹងនោះធ្វើឡើងដោយខុសច្បាប់ និងត្រូវលើកចោលដោយតុលាការ។ បន្ទាប់ពីបណ្ដឹងត្រូវបានដាក់ជូនតុលាការរួចហើយ តុលាការនឹងកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់។

### ៣.២.១. អត្ថន័យនៃបណ្ដឹងរដ្ឋប្បវេណី

បណ្ដឹង ជាសកម្មភាពទាមទាររបស់ដើមចោទចំពោះចុងចម្លើយដើម្បីឱ្យតុលាការចេញសាលក្រមដោយផ្អែកលើការអះអាងអំពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិ ឬទំនាក់ទំនងគតិយុត្តណាមួយតាមច្បាប់កំណត់។ កម្មវត្ថុនៃបណ្ដឹង គឺត្រូវតែជាវិវាទស្របតាមផ្លូវច្បាប់ជាក់ស្ដែង ដែលវិវាទនោះអាចដោះស្រាយបានដោយសាលក្រម។[55] ចំពោះបណ្ដឹងរដ្ឋប្បវេណីត្រូវបានបែងចែកជាបីប្រភេទរួមមាន បណ្ដឹងទាមទារឱ្យផ្ដល់តាវកាលិក បណ្ដឹងទាមទារឱ្យបញ្ជាក់ និងបណ្ដឹងទាមទារឱ្យបង្កើត ផ្លាស់ប្ដូរ ឬរំលត់នូវទំនាក់ទំនងគតិយុត្ត។

[50] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា៣៣។

[51] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា៣៤។

[52] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្ដីព្រៀងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, *សេចក្ដីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី*, ១៖ ២៨។

[53] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា៣៦។

[54] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា៥៣។

[55] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា៧៥។

### ៣.២.២. នីតិវិធីនៃការដាក់ពាក្យបណ្ដឹង

#### ៣.២.២.១. ចំណុចដែលត្រូវសរសេរក្នុងពាក្យបណ្ដឹង

ដើម្បីឱ្យបណ្ដឹងរបស់សហកម្មសិទ្ធិករដែលជាដើមចោទមានសុពលភាពតាមផ្លូវច្បាប់ ជាចាំបាច់ពាក្យបណ្ដឹងត្រូវធ្វើឡើងជាលិខិតលាយលក្ខណ៍អក្សរ។[56] ចំណុចសំខាន់ៗត្រូវសរសេរក្នុងពាក្យបណ្ដឹងរួមមាន៖

ទីមួយ អំពីឈ្មោះ និងអាស័យដ្ឋានចំពោះរូបវ័នបុគ្គល ក្នុងនេះដែរប្រសិនបើភាគីគ្មានសមត្ថភាពក្នុងការធ្វើបណ្ដឹង ត្រូវសរសរឈ្មោះ និងអាសយដ្ឋាន អ្នកតំណាងតាមច្បាប់កំណត់វិញ រីឯនីតិបុគ្គលត្រូវសរសេរនាមករណ៍ ឬទីស្នាក់ការ ឬអាស្រ័យដ្ឋានអ្នកតំណាង[57] ដោយត្រូវបញ្ជាក់ថា ភាគីណាជាដើមចោទ ភាគីណាជាចុងចម្លើយ។

ទីពីរ អំពីខ្លឹមសារនៃសាលក្រម និងអង្គហេតុចាំបាច់ដើម្បីបញ្ជាក់ការទាមទារ មានន័យថា ភាគីសហកម្មសិទ្ធិករត្រូវកំណត់កម្មវត្ថុនៃវិវាទ និងទំហំនៃការទាមទារ ដោយផ្អែកលើអង្គហេតុចាំបាច់សម្រាប់ការអះអាងបញ្ជាក់អំពី អត្ថិភាព ឬនត្ថិភាពនៃសិទ្ធិ ឬទំនាក់ទំនងគតិយុត្តិ ដែលទទួលស្គាល់តាមផ្លូវច្បាប់សារជាតុ។[58]

ទីបី គប្បីសរសេរបញ្ជាក់ឱ្យច្បាស់នូវអង្គហេតុដែលជាមូលហេតុនៃការទាមទារ និងអង្គហេតុសំខាន់ៗដែលត្រូវបញ្ជាក់ដោយភស្តុតាង មានន័យថា ត្រូវសរសេរអំពីរឿងរ៉ាវដែលជាមូលហេតុនាំឱ្យមានវិវាទ ហើយអាចបញ្ជាក់អំពីភស្តុតាងនៅក្នុងនោះក៏បាន ឧទាហរណ៍ សាក្សីជាដើម។[59]

ទីបួន ពាក្យបណ្ដឹងត្រូវបានផ្ដិតមេដៃ ឬហត្ថលេខា និងឈ្មោះអ្នកប្ដឹង។

#### ៣.២.២.២. របៀបនៃការដាក់ពាក្យបណ្ដឹង

នៅពេលដែលពាក្យបណ្ដឹងត្រូវបានសរសេររួចរាល់ហើយ ពាក្យបណ្ដឹងនោះត្រូវដាក់នៅលេខាធិការដ្ឋានសាលាដំបូងរាជធានី ខេត្ត ដែលមានសមត្ថកិច្ច។ បន្ទាប់មកមន្ត្រីលេខាធិការដ្ឋានដែលទទួលបន្ទុកអាចជួយពិនិត្យលើពាក្យបណ្ដឹង ប្រសិនបើមានការខ្វះខាតនៅក្នុងពាក្យបណ្ដឹងអាចកែចំណុចខ្វះខាតនោះបាន។ ប៉ុន្តែនៅពេលដែលពាក្យបណ្ដឹងដាក់ទៅដល់ចៅក្រមហើយ ប្រសិនបើមានចំណុចខ្វះខាត ចៅក្រមនឹងចេញដីបង្គាប់ឱ្យកែតម្រូវ ដើម្បីឱ្យបណ្ដឹងនោះមានភាពស្របច្បាប់។

សហកម្មសិទ្ធិករដែលជាដើមចោទ ត្រូវបង់ពន្ធលើពាក្យបណ្ដឹង ដែលចំនួនទឹកប្រាក់នៃការបង់ពន្ធអាស្រ័យលើតម្លៃកម្មវត្ថុនៃបណ្ដឹង [60] ហើយតម្លៃកម្មវត្ថុកំណត់នៅក្នុងប្រកាសរបស់ក្រសួងយុត្តិធម៌លេខ ២៤ កយ ប្រក,០៧ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៧ ស្ដីពី ប្រភេទពាក្យសុំដែលតម្រូវឱ្យបង់ពន្ធ ចំនួនទឹកប្រាក់ នៃពន្ធ

[56] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្ដីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, *សេចក្ដីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី*, ១៖ ៣៤។

[57] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា៧៥។

[58] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្ដីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, *សេចក្ដីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី*, ១៖ ៣៦។

[59] ដូច១៩, មាត្រា៧៥។

[60] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា៦១។

ដាក់ពាក្យសុំ និងចំនួនពន្ធដែលត្រូវឱ្យបង់ដើម្បីធ្វើសកម្មភាពក្រៅពីពាក្យសុំទៅតុលាការឱ្យសម្រេចសេចក្តី និង មាត្រាដ្ឋានសម្រាប់គណនាប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ និងតម្លៃកម្មវត្ថុនៃបណ្តឹង។ ប៉ុន្តែលើកលែងក្នុង ករណីដើមចោទមានជំនួយសង្គ្រោះលើពាក្យបណ្តឹងដែលមិនត្រូវបានបង់ពន្ធលើពាក្យបណ្តឹង [61] ។ ចុងក្រោយ ពាក្យបណ្តឹងដែលបានដាក់នោះត្រូវបានវាយត្រា និងចុះលេខ ចុះកាលបរិច្ឆេទ ហើយបញ្ជូនទៅចៅក្រមទទួល បន្ទុកដែលត្រូវបានកំណត់ក្នុងដីកាសម្រេចប្រចាំឆ្នាំរបស់ប្រធានតុលាការ[62]។

### ៣.២.៣. ការកំណត់កាលបរិច្ឆេទនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកដំបូង

បន្ទាប់ពីពាក្យបណ្តឹងត្រូវបានដាក់ហើយ ដើម្បីជៀសវាងនូវការយឺតយ៉ាវ ក្នុងការដោះស្រាយរឿងក្តី តុលាការនឹងកំណត់កាលបរិច្ឆេទត្រៀមទាញហេតុផលដោយផ្ទាល់មាត់ ក្នុងអំឡុងពេលសាមសិបថ្ងៃ លើកលែង តែមូលហេតុពិសេស[63] ក្នុងនេះដែរតុលាការនឹងកោះហៅភាគីក្នុងរឿងក្តីវិវាទអគារសហកម្មសិទ្ធិ ដែលមានឈ្មោះ និងអាស្រ័យដ្ឋាននៅក្នុងពាក្យបណ្តឹងដែលបានដាក់ហើយនោះ ឱ្យភាគីទាំងពីរចូលរួមក្នុងនីតិវិធីនៅកាលបរិច្ឆេទ ដែលភាគីអាចចូលរួមបាន[64]។

## ៣.៣. ការជំនុំជម្រះលើបណ្តឹងរដ្ឋប្បវេណី

មុននឹងតុលាការធ្វើការសម្រេចសេចក្តីលើរឿងក្តីរដ្ឋប្បវេណី ដើម្បីចេញសាលក្រម ជាគោលការណ៍ ដែលច្បាប់បានកំណត់ត្រូវឆ្លងកាត់នីតិវិធីចំនួន២គឺ (១)នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដោយផ្ទាល់ ក្នុងគោលបំណង រៀបចំណុចវិវាទនិងភស្តុតាង។ (២) នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ក្នុងគោលបំណង លើកយកលទ្ធផលនៅពេលត្រៀម និងពិនិត្យភស្តុតាង ដើម្បីអាចធ្វើការវិនិច្ឆ័យរឿងក្តីឱ្យបានល្អិតល្អន់។

### ៣.៣.១. នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកដំបូង

#### ៣.៣.១.១. អត្ថន័យ

នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល គឺជាដំណាក់កាលដើមដំបូងមួយនៃនីតិវិធីរដ្ឋប្បវេណីដែល ធ្វើឡើង ដើម្បីផ្តល់ឱកាសឱ្យគូភាគីថ្លែងការណ៍អំពីពាក្យបណ្តឹងរបស់ខ្លួន ត្រៀមរៀបចំសេចក្តីអះអាង បំភ្លឺនូវវិវាទ ដែលភាគីយល់មិនស្របគ្នា និងរៀបចំភស្តុតាងដែលទាក់ទងនឹងចំណុចវិវាទ នៅមុនពេលចាប់ផ្តើមកាលបរិច្ឆេទ ទាញហេតុផលដោយផ្ទាល់មាត់។[65]

[61] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា៦៩។
[62] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា២៦។
[63] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា៨០។
[64] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា១០៥។
[65] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា១០៣។

### ៣.៣.១.២. សកម្មភាពក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

#### ក. ការសាកល្បងផ្សះផ្សា

ចៅក្រមតម្រូវឱ្យភាគីទាំងសងខាងចូលរួមក្នុងនីតិវិធីនោះជាចាំបាច់ ហើយចៅក្រមនឹងធ្វើការសាកល្បងពន្យល់ណែនាំភាគីទាំងសងខាងឱ្យត្រូវរ៉ូវគ្នាដើម្បីបញ្ចប់វិវាទរបស់ខ្លួនជាលើកដំបូងសិន លើកលែងតែចៅក្រមយល់ឃើញថាភាគីទាំងសងមិនអាចសាកល្បងផ្សះផ្សាគ្នាបានទេ។[66] ក្នុងករណីដែលគូភាគីផ្សះផ្សាគ្នា ព្រមព្រៀងបញ្ចប់វិវាទ ចៅក្រមនឹងធ្វើកំណត់ហេតុសះជាដែលមានអានុភាពដូចសាលក្រមស្ថាពរ[67] ដើម្បីបញ្ចប់បណ្តឹង។ ដើមចោទអាចដាក់ពាក្យសុំ យកមកវិញពាក់កណ្តាលនៃពន្ធលើពាក្យបណ្តឹង បើការសះជានេះ បញ្ចប់មុនការទាញហេតុផលដោយផ្ទាល់មាត់។[68] មួយវិញទៀតក្នុងករណីដែលភាគីផ្សះផ្សាគ្នាមិនបាន ចៅក្រមនឹងបន្តនីតិវិធីទៅមុខទៀត។

#### ខ. ការថ្លែងការណ៍ពាក្យបណ្តឹង

ជាគោលការណ៍ជំនុំជម្រះក្តីដោយផ្ទាល់មាត់ ចៅក្រមឱ្យដើមចោទថ្លែងការណ៍អំពីពាក្យបណ្តឹង។ ចំណុចដែលដើមចោទថ្លែងការណ៍មានដូចជា ខ្លឹមសារនៃសាលក្រមដែលទាមទារឱ្យតុលាការចេញ អង្គហេតុចាំបាច់សម្រាប់ការទាមទារ អង្គហេតុដែលជាមូលហេតុនៃការទាមទារ និងអង្គហេតុសំខាន់ៗដែលត្រូវបញ្ជាក់ដោយភស្តុតាង។[69]

#### គ. ការកំណត់ចំណុចវិវាទ

ចៅក្រមមានតួនាទីរៀបចំសេចក្តីអះអាងរបស់ភាគី ឬសាកសួរភាគី ឬបញ្ជាក់ភស្តុតាង ដើម្បីកំណត់អំពីចំណុចវិវាទរវាងដើមចោទ និងចុងចម្លើយឱ្យបានច្បាស់លាស់ ថាតើការអះអាងអំពីការទាមទាររបស់ដើមចោទដែលមានខ្លឹមសារក្នុងពាក្យបណ្តឹង ចុងចម្លើយទទួលស្គាល់ ឬតវ៉ា ឬធ្វើសេចក្តីអះអាងតបទៅវិញអំពីអង្គហេតុនានា នៃបណ្តឹងរបស់ដើមចោទ ឬអង្គហេតុនានាក្នុងបណ្តឹងរបស់ដើមចោទមានភាពស្មុគស្មាញ និងមានភាពមិនទាន់ច្បាស់ ដែលពុំទាន់អាចឱ្យចៅក្រមយល់ច្បាស់អំពីចំណុចវិវាទ[70] ដោយតម្រូវឱ្យភាគីទាំងដើមចោទ និងចុងចម្លើយដាក់មធ្យាបាយតទល់ និងមធ្យាបាយការពារខ្លួនដែលហៅថា ភស្តុតាង នៅក្នុងកាលបរិច្ឆេទដែលភាគីចូលរួមក្នុងនីតិវិធី ឬក្នុងអំឡុងពេលសមរម្យដែលចៅក្រមជាអ្នកកំណត់។[71] ចំពោះភស្តុតាងដែលភាគីបានដាក់

---

[66] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា១០៤។

[67] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា២២២។

[68] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា៦១ កថាខណ្ឌ៨ ចំណុចខ។

[69] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រៀងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, *សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី*, ១៖ ៧៨។

[70] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា៩០។

[71] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា៩៤។

ជូនមកកាន់ចៅក្រម ភស្តុតាងនោះនឹងត្រូវលើកមកពិនិត្យទាក់ទងនឹងចំណុចវិវាទអគារសហកម្មសិទ្ធិនៅកាលបរិច្ឆេទនៃនីតិវិធីទាញហេតុផលផ្ទាល់មាត់។

**៣.៣.១.៣. ការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល**

បន្ទាប់ពីបញ្ចប់ការរៀបចំចំណុចវិវាទរួច ចៅក្រមនឹងរៀបរាប់អំពីអង្គហេតុសំខាន់ៗនៃចំណុចវិវាទ ដែលភាគីទាំងសងខាងបានធ្វើការអះអាងចំពោះមុខគ្នារួចរាល់កន្លងមក បញ្ជាក់ទៅកាន់ភាគីទាំងសងខាងឱ្យកាន់តែជ្រាបច្បាស់ចុងក្រោយ មុនពេលបិទបញ្ចប់នីតិវិធីនៅក្នុងដំណាក់នេះ ដើម្បីអាចឱ្យចៅក្រមលើកយកអង្គហេតុនៃចំណុចវិវាទដែលត្រូវបំភ្លឺ នៅពេលធ្វើការពិនិត្យភស្តុតាងដោយសមូហវិធីក្នុងការស្វែងរកការពិត នៅកាលបរិច្ឆេទទាញហេតុផលដោយផ្ទាល់មាត់។[72] នៅពេលដែលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបានចប់សព្វគ្រប់ តុលាការត្រូវកំណត់កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ និង កោះហៅគូភាគីដែលពាក់ព័ន្ធដើម្បីចូលរួមក្នុងនីតិវិធីនេះ[73] ហើយសម្រាប់ការទាញហេតុផ្ទាល់មាត់ត្រូវធ្វើឡើងនៅបរិច្ឆេទដែលភាគីទាំងសងខាងអាចចូលរួមបាន[74]។

**៣.៣.២. នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់**

**៣.៣.២.១. អត្ថន័យ**

នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ គឺជាទម្រង់មួយនៃការជម្រះក្តីដែលក្នុងនោះមានសកម្មភាពរបស់តុលាការ និងសកម្មភាពរបស់ភាគី ការពិនិត្យភស្តុតាងនានា និងការវិនិច្ឆ័យសេចក្តី ដែលក្នុងនោះដំណើរការនៃការជម្រះក្តី ភាគីត្រូវធ្វើឡើងតាមរយៈការធ្វើសេចក្តីថ្លែងការណ៍ដោយផ្ទាល់មាត់ និងការស្តាប់សេចក្តីថ្លែងការណ៍នោះដោយតុលាការ នៅសាលសវនាការជាសាធារណៈ និងនៅកាលបរិច្ឆេទដែលភាគីទាំងសងខាងអាចមានវត្តមាន។[75]

**៣.៣.២.២. ដំណើរការនៃការទាញហេតុផលដោយផ្ទាល់មាត់**

**ក. នីតិវិធីផ្សះផ្សា**

នៅកាលបរិច្ឆេទនៃការទាញហេតុផលលើកដំបូង វត្តមាននៃភាគីទាំងសងខាងជារឿងចាំបាច់បំផុតដើម្បីអាចឱ្យចៅក្រមធ្វើការផ្សះផ្សាភាគីទាំងសងខាងបញ្ចប់វិវាទ[76] ឬមកដល់ដំណាក់កាលនេះភាគីទាំងសងខាងមានឆន្ទៈក្នុងការសម្រុះសម្រួលគ្នាព្រមព្រៀងបញ្ចប់វិវាទដោយខ្លួនឯងផ្ទាល់ អាចស្នើសុំទៅចៅក្រមដើម្បីកំណត់កាលបរិច្ឆេទក្នុងការផ្សះផ្សាបន្ទាប់ក៏បាន។ ក្នុងករណីដែលគូភាគីផ្សះផ្សាគ្នា ព្រមព្រៀងបញ្ចប់វិវាទ ចៅក្រមនឹងធ្វើ

[72] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា១០៧។

[73] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា១១៣។

[74] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា១១៥។

[75] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, *សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី*, ១៖ ៨៧។

[76] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា២២០។

កំណត់ហេតុសះជាដែលមានអានុភាពដូចសាលក្រមស្ថាពរ[77] ដើម្បីបញ្ចប់បណ្តឹង។ នៅក្នុងដំណាក់កាលទាញហេតុផលដោយផ្ទាល់មាត់នេះ ដើមចោទមិនអាចដាក់ពាក្យសុំ យកមកវិញនូវពន្ធលើពាក្យបណ្តឹង ដែលបានបង់ហើយនោះទេ។[78] មួយវិញទៀតក្នុងករណីដែលភាគីផ្សះផ្សាគ្នាមិនបាន ចៅក្រមនឹងបន្តនីតិវិធីទៅមុខទៀត។

**ខ. សេចក្តីថ្លែងការណ៍**

ចៅក្រមតម្រូវឱ្យភាគីទាំងសងខាង ឬភាគីណាម្ខាងធ្វើសេចក្តីថ្លែងការណ៍អំពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលផ្ទាល់មាត់។[79] ក្នុងនេះដែរ សេចក្តីថ្លែងការណ៍នេះលើកឡើងជាពិសេសអំពីសកម្មភាពទាំងឡាយដែលបានធ្វើនៅក្នុងនីតិវិធីត្រៀម ដូចជា ការអះអាងអង្គហេតុដែលសំខាន់ៗ ការដាក់ភស្តុតាង និងលទ្ធផលនៃការរៀបចំណុចនៃវិវាទ ដូច្នេះសកម្មភាពដែលបានថ្លែងការណ៍ទាំងនោះចាត់ទុកថាបានធ្វើនៅក្នុងកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ហើយពុំចាំបាច់ធ្វើសកម្មភាព ទាំងនោះឡើងវិញទេ។[80] ជាមួយគ្នានេះដែរ ភាគីអាចអះអាងបន្ថែមទៀតអំពីអង្គហេតុ និងដាក់ភស្តុតាងមកទៀតបាន កុំឱ្យតែការអះអាងអំពីអង្គហេតុ ឬការដាក់ភស្តុតាងនោះផ្ទុយនឹងមាត្រា១០៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦។ លើសពីនេះទៀត ចៅក្រមអាចពន្យល់ដល់ភាគីទាំងសងខាងអំពីរបៀបនៃការធ្វើសេចក្តីថ្លែងការណ៍ ឬប្រសិនភាគីនៅតែពិបាកយល់ ចៅក្រមអាចជួយថ្លែងការណ៍ជំនួស ហើយសួរទៅភាគីយល់ស្រប ឬអត់។

**គ. ការពិនិត្យភស្តុតាង**

សេចក្តីសម្រេចរបស់តុលាការឈរលើគោលការណ៍ជាមូលដ្ឋានមួយចំនួនដូចជា គោលការណ៍ជម្រះក្តីផ្អែកតាមច្បាប់ និងគោលការណ៍សម្រេចសេចក្តីដោយភស្តុតាង[81] ដូចនេះ ក្រោយពីភាគីធ្វើសេចក្តីថ្លែងការណ៍រួចហើយ ចៅក្រមនឹងលើកយកភស្តុតាងដែលភាគីបានដាក់ជូនតុលាការនៅក្នុងដំណាក់ការត្រៀមសម្រាប់ទាញហេតុផលដោយផ្ទាល់មាត់ មកធ្វើការពិនិត្យ និងធ្វើការដេញដោលនៅពេលនេះតែម្តង ដោយតម្រូវឱ្យភាគីធ្វើការអះអាងបំភ្លឺអំពីអង្គហេតុនៃចំណុចវិវាទដែលពាក់ព័ន្ធភស្តុតាងទាំងនោះ ប៉ុន្តែអង្គហេតុណាមួយដែលភាគីសារភាពទទួលស្គាល់ ចៅក្រមពុំចាំបាច់ពិនិត្យភស្តុតាងទៀតទេ។[82] ចំពោះប្រភេទនៃភស្តុតាងដែលត្រូវធ្វើការពិនិត្យដូចជាការសាកសួរសាក្សី កោសល្យវិច័យ ចម្លើយរបស់ភាគី ភស្តុតាងជាឯកសារ និងការពិនិត្យវាយតម្លៃ យ៉ាងណាមិញភស្តុតាងណាមួយដែលចៅក្រមត្រូវលើយកមកពិនិត្យនោះ គឺប្រែប្រួលអាស្រ័យទៅលើរឿងក្តីនីមួយៗ។[83]

---

[77] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦មាត្រា២២២។

[78] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា៦១ កថាខណ្ឌ៨ ចំណុចខ។

[79] ហ៊ី សោភា, "នីតិវិធីរដ្ឋប្បវេណី," (សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច), ៦៨។

[80] អ៊ីវ ប៉ូលី, "នីតិវិធីរដ្ឋប្បវេណី," (សាកលវិទ្យាល័យបញ្ញាសាស្ត្រ), ៦៩។

[81] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា១២៣។

[82] ហ៊ី សោភា, "នីតិវិធីរដ្ឋប្បវេណី," (សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច), ៧០។

[83] ហ៊ី សោភា, "នីតិវិធីរដ្ឋប្បវេណី," (សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច), ៧៤។

### ៣.៣.២.៣. ការបញ្ចប់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់

ក្រោយពីការពិនិត្យភស្តុតាងចប់សព្វគ្រប់ហើយ ចៅក្រមផ្ដល់ឱកាសឱ្យគូភាគីអាចលើកឡើងនូវមតិចុងក្រោយរបស់ខ្លួនពាក់ព័ន្ធទៅនឹងភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវ នៃការទាមទាររបស់ដើមចោទ ឬចុងចម្លើយដោយផ្អែកលើលទ្ធផលនៃការពិនិត្យភស្តុតាង។ បន្ទាប់មកទៀត ចៅក្រមនឹងត្រូវបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ និងកំណត់កាលបរិច្ឆេទប្រកាសសាលក្រម។[84]

[84] អ៊ុំ ប៉ូលី, "នីតិវិធីរដ្ឋប្បវេណី," (សាកលវិទ្យាល័យបញ្ញាសាស្ត្រ), ៦៩។

# សេចក្តីសន្និដ្ឋាន

ឆ្លងកាត់តាមការបកស្រាយដោយផ្អែកលើមូលដ្ឋាននៃការសិក្សាស្រាវជ្រាវយ៉ាងលម្អិតជុំវិញប្រធានបទ "ការដោះស្រាយវិវាទអាគារសហកម្មសិទ្ធិនៅកម្ពុជា" រួចមក ឃើញថា បច្ចុប្បន្ន បើទោះជាកម្ពុជានៅជាប្រទេសកំពុងអភិវឌ្ឍន៍ក្តី ប៉ុន្តែមានការរីកចម្រើនគ្រប់វិស័យ ពិសេសមានសំណង់អាគារខ្ពស់ៗ ដូចជាអាគារសហកម្មសិទ្ធិរីកដូចផ្សិតនៅរាជធានីភ្នំពេញជាមុខព្រួញយ៉ាងសំខាន់បំផុត ដែលប្រជាពលរដ្ឋខ្មែរយើងមួយចំនួននិយមរស់នៅតាមបែបស៊ីវិល័យសម័យថ្មី។

ទន្ទឹមនឹងគុណសម្បត្តិជាច្រើននៃការរស់នៅបែបសហកម្មសិទ្ធិនេះ ក៏សង្កេតឃើញមាននូវវិវាទមួយចំនួនដែលកើតឡើងរវាងសហកម្មសិទ្ធិករនិងសហកម្មសិទ្ធិករ រវាងសហកម្មសិទ្ធិករ និងអ្នកអភិវឌ្ឍអចលនវត្ថុ ក៏ដូចជារវាងសហកម្មសិទ្ធិករ និងអង្គការគ្រប់គ្រងអគារសហកម្មសិទ្ធ ដែលវិវាទទាំងនោះច្រើនកើតឡើងដោយសារការមិនអនុវត្តករណីយកិច្ចតាមកិច្ចសន្យា ការមិនគោរពបទបញ្ជាផ្ទៃក្នុងសម្រាប់អគារសហកម្មសិទ្ធិ ការថយចុះនៃគុណភាពសំណង់ ការធ្វើសកម្មភាពពាក់ព័ន្ធនឹងសំណង់ ជាពិសេសគឺការរំលោភបំពានសិទ្ធិអ្នកជិតខាង។

តាមរយៈមូលហេតុនៃវិវាទអគារសហកម្មសិទ្ធិដែលបានរៀបរាប់ខាងលើនេះ ទាមទារត្រូវមានយន្តការដោះស្រាយ ដែលក្នុងនោះដើម្បីដោះស្រាយវិវាទសហកម្មសិទ្ធិនៅកម្ពុជា ត្រូវពឹងផ្អែកលើមធ្យោបាយពីរដែលជាជម្រើសរបស់គូភាគី តាមរយៈការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ និងការដោះស្រាយវិវាទក្នុងប្រព័ន្ធតុលាការ។ ជម្រើសទី១ គឺជានីតិវិធីនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ដែលអាចធ្វើឡើងដោយភាគី ឬដោយមានអ្នកសម្របសម្រួល។ ជម្រើសនេះ ប្រសិនបើភាគីឯកភាពគ្នា នោះពិតជាអាចបញ្ចប់វិវាទបានដោយជោគជ័យ។ ក៏ប៉ុន្តែ ប្រសិនបើភាគីមិនព្រមព្រៀងគ្នាវិញ គឺត្រូវឈានដល់ជម្រើសទី២ គឺការដោះស្រាយវិវាទក្នុងប្រព័ន្ធតុលាការ។ ជម្រើសចុងក្រោយនេះ ជាឆន្ទានុសិទ្ធិរបស់អង្គចៅក្រមក្នុងការសម្រេចសេចក្តី ដោយអនុលោមទៅតាមនីតិវិធីដែលមានចែងយ៉ាងប្រាកដជាក់ក្នុងក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦។ ដំណោះស្រាយទាំងពីរផ្លូវខាងលើនេះ ពិតជាបានឆ្លើយតបបានមួយកម្រិតធំទៅនឹងមូលហេតុនានានៃវិវាទជុំវិញបញ្ហាអគារសហកម្មសិទ្ធិនៅកម្ពុជា។

# អនុសាសន៍

បទដ្ឋានគតិយុត្តិដែលពាក់ព័ន្ធនឹងអគារសហកម្មសិទ្ធិ គួរតែមានចែងអំពីការកំណត់ទណ្ឌកម្ម ទៅលើសហកម្មសិទ្ធិករក្នុងការប្រើប្រាស់សិទ្ធិលើចំណែកឯកជនរបស់ខ្លួន ហើយរំលោភបំពានដល់ចំណែកឯកជនអ្នកជិតខាង ក្នុងអគារសហកម្មសិទ្ធិ។ ប្រសិនបើច្បាប់មិនបានចែងហើយ បទបញ្ជាផ្ទៃសម្រាប់គ្រង់គ្រង គួរតែចែងអំពីសកម្មភាពបែបណាដែលត្រូវបានហាមឃាត់ក្នុងការប្រើប្រាស់ចំណែកឯកជនឱ្យបានច្បាស់លាស់ និងចែងពាក់ព័ន្ធនឹងទណ្ឌកម្មសម្រាប់ពិន័យជាប្រាក់ សំណង់នៃការខូចខាត ឬទាមទារឱ្យភាគីបង្កឡើងរៀបចំជួសជុលឱ្យដូចសភាពដើម។ ចំពោះចំណែករួមវិញ គួរតែចែងអំពីបញ្ជីរាយមុខសម្ភារៈទាក់ទងនឹងតម្លៃ ដែលត្រូវធ្វើបដិទាននៅពេលមានការខូចខាត ទុកក្នុងបទបញ្ជាផ្ទៃក្នុងនេះផងដែរ។ ចំពោះការចែងអំពីទណ្ឌកម្មនេះ ជាកត្តាមួយចូលរួមទប់ស្កាត់ការកើនឡើងវិវាទអគារសហកម្មសិទ្ធិបានមួយចំនួន។

កិច្ចសន្យាដែលពាក់ព័ន្ធអគារសហកម្មសិទ្ធិ និងបទបញ្ជាផ្ទៃក្នុងសម្រាប់គ្រប់គ្រង គួរតែចែងឱ្យបានលម្អិតអំពីសិទ្ធិ និងកាតព្វកិច្ច ឱ្យគ្រប់ជ្រុងជ្រោយ និងច្បាស់លាស់ ដើម្បីយកជាមូលដ្ឋានក្នុងដោះស្រាយវិវាទ ព្រមទាំងអាចជៀសវាង និងកាត់បន្ថយនៃវិវាទអគារសហកម្មសិទ្ធិ។ ប្រសិនបើភាគីនៃកិច្ចសន្យាមិនបានអនុវត្តសិទ្ធិ និងករណីយកិច្ចដែលបានកំណត់ក្នុងកិច្ចសន្យា ជាគោលការណ៍ការដោះស្រាយត្រូវផ្អែកលើលក្ខខណ្ឌតាមការព្រមព្រៀងក្នុងកិច្ចសន្យាជាមុនសិន ប៉ុន្តែប្រសិនបើពុំមានកំណត់នៅក្នុងកិច្ចសន្យាទេ ទើបយកបញ្ញត្តិស្តីពីកិច្ចសន្យាលក់ទិញ និងសំណង់នៃការខូចខាត ក្នុងក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧ មកធ្វើជាមូលដ្ឋានក្នុងការដោះស្រាយ។ ក្នុងករណីសហកម្មសិទ្ធិករមួយចំនួន ប្រើប្រាស់សិទ្ធិរបស់ខ្លួន ដោយរំលោភបំពាន សិទ្ធិ និងផលប្រយោជន៍របស់អ្នកជិតខាង នាំឱ្យមានការខូចខាត នោះការទទួលខុសរដ្ឋប្បវេណី ត្រូវផ្អែកលើបញ្ញត្តិស្តីអំពីអនីត្យានុកូល ក្នុងក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧ ដើម្បីអាចឱ្យបុគ្គលណាមួយជាអ្នកទទួលខុសត្រូវសងសំណង់ការខូចខាត។

រាល់អគារសហកម្មសិទ្ធិទាំងអស់ គួរតែតម្រូវឱ្យមានធានារ៉ាប់រងលើសុវត្ថិភាពនៃអគារទាំងមូល ដើម្បីជៀសវាងវិវាទរវាងសហកម្មសិទ្ធិករនីមួយៗ តួយ៉ាង ករណីអគារសហកម្មសិទ្ធិមានការបាក់ស្រុត ដូច្នេះក្រុមហ៊ុនធានារ៉ាប់រងជាអ្នកដោះស្រាយវិវាទនេះជាមួយសហកម្មសិទ្ធិករវិញម្តង។ ចំពោះធានារ៉ាប់រងនេះ គួរតែកំណត់ជាកាតព្វកិច្ចនៅក្នុងបទបញ្ជាផ្ទៃក្នុងសម្រាប់គ្រប់គ្រង ទើបអាចអនុវត្តមានប្រសិទ្ធភាព។

រាជរដ្ឋាភិបាលគួរតែខិតខំ ត្រួតពិនិត្យ និងពង្រឹងការអនុវត្តច្បាប់របស់ក្រសួង ឬស្ថាប័នដែលមានសមត្ថកិច្ចពាក់ព័ន្ធនឹងអគារសហកម្មសិទ្ធិ។

ជាមួយគ្នានេះ ក្រសួង ឬស្ថាប័នដែលមានសមត្ថកិច្ច ត្រួតពិនិត្យ និងតាមដានលើគុណភាពនៃការសាងសាងអគារសហកម្មសិទ្ធិ និងប្រព័ន្ធសុវត្ថិភាពក្នុងអគារសហកម្មសិទ្ធិ ឱ្យមានប្រសិទ្ធភាព និងប្រសិទ្ធផល។

ជាពិសេស សហកម្មសិទ្ធិករត្រូវចូលរួមគោរពលក្ខខណ្ឌដែលមានចែងក្នុងបទបញ្ជាផ្ទៃក្នុង និងច្បាប់ទាំងឡាយ ទើបអាចកាត់បន្ថយ និងជៀសផុតពីវិវាទអគារសហកម្មសិទ្ធិ៕

# គន្ថនិទ្ទេស


**ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត**

- ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។
- ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។
- អនុក្រឹត្យស្តីពីការគ្រប់គ្រងនិងប្រើប្រាស់អគារសហកម្មសិទ្ធិ, លេខ១២៦ អនក្រ. បក, ២៣ សីហា ២០០៩។
- អនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់, លេខ៨៦ អនក្រ.បក, ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧។
- ច្បាប់ស្តីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់, លេខ នស/រកម/០៣០១/០៥, ២៨ កុម្ភៈ ២០០១។

**ច្បាប់និរាករណ៍**

- ច្បាប់ភូមិបាល, លេខ នស/រកម/០៨០១/១៤, ៣០ សីហា ២០០១។

**សៀវភៅ**

- កៅ សីហា. *ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ.* ២០១០. https://vannarachin.wordpress.com/ (ថតចម្លងថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២០)។
- ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រៀងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា. *សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី.* ភាគ១។
- គណៈកម្មការនីតិកម្ម និងយុត្តិធម៌ព្រឹទ្ធសភា និងលេខាធិការដ្ឋានអមគណៈកម្មការនីតិកម្ម និងយុត្តិធម៌ព្រឹទ្ធសភា, ចងក្រង. *ឯកសារជំនួយស្មារតីស្តីពីការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅឃុំ សង្កាត់.* ២០១៧។
- សមាគមអាដហុក ការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា. *ឧបករណ៍សម្រាប់ដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការ.* ២០១៣។
- ស៊្មីរិន អ៊ែម អូស៊្មីរមីឡឺរ៍. *ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការប្រទេសកម្ពុជា៖ សៀវភៅសិក្សាស្តីពីទស្សនាទានសំខាន់ៗ*, បោះពុម្ពលើកទី២. រាជធានីភ្នំពេញ, ២០១០។
- ហាប់ ផល្លី. "វិធីសាស្ត្រស្រាវជ្រាវ និងការសរសេរបែបសិក្សា." សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ២០១៩។
- ហ៊ី សោភា. "នីតិវិធីរដ្ឋប្បវេណី." សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច។
- ហៀង សាង. *នីតិរដ្ឋបាលទូទៅ.* ភ្នំពេញ៖ បណ្ណាល័យជាតិ, ២០១៧។

– អ៊ីវ ប៉ូលី. "នីតិវិធីរដ្ឋប្បវេណី." សាកលវិទ្យាល័យបញ្ញាសាស្ត្រ។


**ឯកសារផ្សេងៗ**

– ការិយាល័យសំណង់. *ស្ថិតិសំណង់ខ្ពស់ក្នុងរាជធានីភ្នំពេញ*. មន្ទីររៀបចំដែនដី នគររូបនីយកម្ម សំណង់ និងសុរិយោដីរាជធានីភ្នំពេញ (របាយការណ៍)។

– រិទ្ធី. "ឆ្លងចរន្តអគ្គិសនីប្រអប់ភ្លើងជាន់ទី៦,៧ នៅក្នុង ខន់ដូរ De Castle ក្លាយជាអគ្គីភ័យ ឆេះផ្ញើស សមត្ថកិច្ចនាំរថយន្តទៅអន្តរាគមន៍," *ដំណឹងពលរដ្ឋ (Peoplenews.asia)*, ០៧ សីហា ២០២០ (កាសែត)។

# ឧបសម្ពន្ធ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១២៦ —

ចុះថ្ងៃទី ១២ សីហា ២០០៩

# អនុក្រឹត្យ

## ស្តីពី

## ការគ្រប់គ្រងនិងប្រើប្រាស់អគារសហកម្មសិទ្ធិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៤/នស/៩៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើក្រមរដ្ឋប្បវេណី
- បានឃើញអនុក្រឹត្យលេខ៨៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ............ ខែ .......... ឆ្នាំ២០០៩

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

### មាត្រា១.–

អនុក្រឹត្យនេះមានគោលដៅកំណត់ អំពីការគ្រប់គ្រងនិងប្រើប្រាស់អគារសហកម្មសិទ្ធិ ព្រមទាំងយន្តការនិង នីតិវិធីសម្រាប់ធ្វើការចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិ ។

### មាត្រា២.–

អនុក្រឹត្យនេះមានគោលបំណងដូចតទៅ ៖

- ធានាការពារសិទ្ធិកម្មសិទ្ធិស្របច្បាប់ របស់អ្នកកាន់កាប់ចំណែកឯកជន នៃអគារសហកម្មសិទ្ធិ
- សម្រួលដល់ការងារគ្រប់គ្រងអគារសហកម្មសិទ្ធិ និងសហកម្មសិទ្ធិករ ដែលរស់នៅក្នុងអគារសហកម្មសិទ្ធិ
- សម្រួលដល់សហកម្មសិទ្ធិករក្នុងការលក់ ការដូរ ការធ្វើអំណោយ ការបន្តមរតក ការជួលអចិន្ត្រៃយ៍ ការដាក់ហ៊ីប៉ូតែក និងការដាក់បញ្ចាំ នូវចំណែកឯកជន ដែលជាកម្មសិទ្ធិរបស់ខ្លួន ។

### មាត្រា៣.–

អនុក្រឹត្យនេះមានវិសាលភាពអនុវត្ត ចំពោះអគារសហកម្មសិទ្ធិគ្រប់ប្រភេទ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ដែលបានសាងសង់ដោយស្របច្បាប់ ។

មានតែរូបវន្តបុគ្គល ឬនីតិជនបុគ្គលដែលមានសញ្ជាតិខ្មែរប៉ុណ្ណោះ ទើបអាចមានសិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិ លើកលែងតែមានបទប្បញ្ញត្តិចែងផ្សេងពីនេះ ។

### មាត្រា៤.–

វាក្យសព្ទដែលប្រើក្នុងអនុក្រឹត្យនេះមានន័យដូចតទៅ ៖

- **អគារសហកម្មសិទ្ធិ** សំដៅដល់អគារ ឬសំណង់ដែលមានកម្មសិទ្ធិករច្រើននាក់រស់នៅ ។ អគារសហកម្មសិទ្ធិមានចំណែកខ្លះជាកម្មសិទ្ធិផ្ទាល់ខ្លួន របស់សហកម្មសិទ្ធិករនីមួយៗហៅថា "ចំណែកឯកជន" និងមានចំណែកខ្លះជាលំហរួមសម្រាប់ការប្រើប្រាស់រួម របស់សហកម្មសិទ្ធិករទាំងអស់ហៅថា "ចំណែករួម" ។
ប្រភេទនៃអគារសហកម្មសិទ្ធិទាំងនោះមានជាអាផាតមិន ភូមិគ្រឹះ ពាក់កណ្តាលភូមិគ្រឹះ ផ្ទះល្វែងដែលមានច្រើនល្វែងនិងច្រើនជាន់ជាប់គ្នា ខុនដូ ប្រភេទផ្ទះផ្សេងទៀត ដែលមានរចនាសម្ព័ន្ធជាប់គ្នា ។
- **ចំណែកឯកជន** សំដៅដល់ចំណែកនៃអគារសហកម្មសិទ្ធិដែលស្ថិតក្រោមការកាន់កាប់ និងប្រើប្រាស់ជាឯកជនផ្ទាល់ខ្លួន ។

- **ចំណែករួម** សំដៅដល់រាល់ចំណែកនៃអគារសហកម្មសិទ្ធិ ដែលត្រូវចាត់ជាកម្មវត្ថុសម្រាប់ការប្រើប្រាស់ ឬជាប្រយោជន៍នៃសហកម្មសិទ្ធិករទាំងអស់ មានជាអាទិ៍ ដី ទីធ្លា ជណ្ដើរ ឧទ្យាន និងសួនច្បារ ផ្លូវ ច្រកចេញ-ចូល ជញ្ជាំងអឡូសិទ្ធិ ទីកន្លែងនៃសេវាកម្មរួម ។
- **អ្នកអភិវឌ្ឍអចលនវត្ថុ** សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលដាក់ទុនវិនិយោគលើការសាងសង់ អគារសហកម្មសិទ្ធិ ក្នុងគោលបំណងសម្រាប់លក់ ឬជួល ។
- **អ្នកអាណាព្យាបាល** សំដៅដល់បុគ្គលដែលមានភារកិច្ចតំណាងអនីតិជន ឬអសមត្ថជន ។
- **ហិតូបត្ថម្ភកៈ** សំដៅដល់ជនដែលតុលាការចាត់តាំងឱ្យគ្រប់គ្រងលើ ជនដែលមានសមត្ថភាពតិចតួចពេក ក្នុងការយល់ដឹងនិងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់ នៃសកម្មភាពរបស់ខ្លួន ដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី ។
- **ក្បាលដីសហកម្មសិទ្ធិ** សំដៅដល់ចំណែកដីនៃអគារសហកម្មសិទ្ធិ ដែលមានទីតាំងនិងទំហំជាក់លាក់ សម្រាប់ការសាងសង់អគារសហកម្មសិទ្ធិ ឬដែលមានអគារសហកម្មសិទ្ធិតាំងនៅ ហើយស្ថិតក្នុងគម្រោងប្លង់សាងសង់អគារសហកម្មសិទ្ធិ ។ ក្បាលដី ឬចំណែកដីនៃអគារសហកម្មសិទ្ធិនេះ ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងនិងប្រើប្រាស់រួមរបស់សហកម្មសិទ្ធិករទាំងអស់ ។
- **ឡូតិ៍** សំដៅដល់ចំណែកឯកជនដែលភ្ជាប់ទៅនឹងចំណែករួម នៃអគារសហកម្មសិទ្ធិ ។ ឡូតិ៍និមួយៗមានតម្លៃខុសៗគ្នាទៅតាមទំហំនៃចំណែកឯកជនតូច ឬធំ ហើយការគណនាត្រូវគិតទៅតាមផ្ទៃក្រឡានៃចំណែកឯកជនរបស់សហកម្មសិទ្ធិករនីមួយៗ ។
- **សិទ្ធិជួលអចិន្ត្រៃយ៍** សំដៅទៅលើសិទ្ធិជួលអចលនវត្ថុរយៈពេលវែងចាប់ពី ១៥ (ដប់ប្រាំ) ឆ្នាំឡើងទៅ ។

## ជំពូកទី២

## ការគ្រប់គ្រងនិងប្រើប្រាស់អគារសហកម្មសិទ្ធិ

### មាត្រា៥.–

រូបវន្តបុគ្គល ឬនីតិបុគ្គល មានសិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិ នៅព្រះរាជាណាចក្រកម្ពុជា ដោយគោរពតាមលក្ខខណ្ឌ និងបញ្ញត្តិទាំងឡាយនៃអនុក្រឹត្យនេះ និងបទដ្ឋានគតិយុត្ត ពាក់ព័ន្ធផ្សេងទៀតជាធរមាន ។

រូបវន្តបុគ្គលជានីតិជននិងមានសមត្ថភាពតាមផ្លូវច្បាប់ អាចជាកម្មសិទ្ធិករលើចំណែកឯកជននៃអគារសហកម្ម- សិទ្ធិ ។ ប៉ុន្តែករណីនេះ ត្រូវបានលើកលែងចំពោះការបន្តមរតក របស់ទាយាទដែលជាអនីតិជន ឬអសមត្ថជនដោយអនុញ្ញាតឱ្យមានសិទ្ធិកម្មសិទ្ធិបាន តែតម្រូវឱ្យមានអ្នកអាណាព្យាបាល ឬហិតូបត្ថម្ភកៈជាអ្នកកាន់កាប់ជំនួសរហូតដល់អនីតិជន ឬអសមត្ថជននោះមានសមត្ថភាពពេញលេញតាមផ្លូវច្បាប់ ។ ចំពោះករណីនេះ អ្នកអាណាព្យាបាលឬហិតូបត្ថម្ភកៈគ្មានសិទ្ធិចាត់ចែងនូវចំណែកឯកជននោះបានឡើយ លើកលែងតែមានការអនុញ្ញាតពីតុលាការ ។

### មាត្រា៦.–

ការផ្តល់កម្មសិទ្ធិជូនសហកម្មសិទ្ធិករ គឺផ្ដល់តែលើចំណែកឯកជននៃអគារសហកម្មសិទ្ធិប៉ុណ្ណោះ ។ ចំពោះចំណែករួមត្រូវរក្សាទុកសម្រាប់សហកម្មសិទ្ធិករទាំងអស់ នៃអគារសហកម្មសិទ្ធិប្រើប្រាស់ជារួម ។
នីតិវិធីនៃការចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិ ត្រូវមានលក្ខណៈងាយស្រួល សាមញ្ញ តម្លាភាព និងស្របតាមគោលការណ៍វិមជ្ឈការ និងវិសហមជ្ឈការ និងអភិបាលកិច្ចល្អ ។

## មាត្រា៧._

ក្បាលដីសម្រាប់សាងសង់អគារសហកម្មសិទ្ធិ ត្រូវតែជាក្បាលដីតែមួយ ដែលត្រូវបានចុះបញ្ជីរួចហើយ នៅក្នុងសៀវភៅគោលបញ្ជីដីធ្លី ។

ក្នុងករណីដែលសំណង់អគារសហកម្មសិទ្ធិមានច្រើនប្រភេទស្ថិតនៅក្បាលដីតែមួយ អ្នកអភិវឌ្ឍអចលនវត្ថុត្រូវស្នើសុំបំបែកក្បាលដីនៅរដ្ឋបាលសុរិយោដី ទៅតាមប្រភេទ និងចំនួននៃអគារសហកម្មសិទ្ធិនីមួយៗ ។ ការបំបែកក្បាលដីត្រូវធ្វើឱ្យស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន ។

អ្នកអភិវឌ្ឍអចលនវត្ថុ ឬបុគ្គលដែលបានឬកំពុងសាងសង់អគារសហកម្មសិទ្ធិ ត្រូវផ្លាស់ប្តូរប្រភេទក្បាល ដីឱ្យទៅជាក្បាលដីសហកម្មសិទ្ធិ នៅរដ្ឋបាលសុរិយោដី នៅពេលផ្ទេរលើកដំបូង នៃចំណែកឯកជនណាមួយ លើកលែងតែអគារសហកម្មសិទ្ធិ ដែលបានសង់នៅលើដីជួលអចិន្ត្រៃយ៍ ។

នៅពេលផ្លាស់ប្តូរប្រភេទក្បាលដីឱ្យទៅជា ក្បាលដីសហកម្មសិទ្ធិ អ្នកអភិវឌ្ឍអចលនវត្ថុ ឬបុគ្គលដែលបាន ឬកំពុងសាងសង់អគារសហកម្មសិទ្ធិលើក្បាលដីនោះ ត្រូវប្រគល់ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ឬប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ឬវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ នៃក្បាលដីឱ្យរដ្ឋបាលសុរិយោដី ដើម្បីធ្វើលេខាចារឹក និងរក្សាទុក ហើយរដ្ឋបាលសុរិយោដី ត្រូវចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់ចំណែកឯកជនជំនួសវិញ ។

ការផ្លាស់ប្តូរប្រភេទក្បាលដីឱ្យទៅជាក្បាលដីសហកម្មសិទ្ធិ និងទម្រង់បែបបទផ្សេងទៀត អាចត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

ក្បាលដីសហកម្មសិទ្ធិ ដែលអគារសហកម្មសិទ្ធិស្ថិតនៅ ជាទ្រព្យរួមរបស់សហកម្មសិទ្ធិករទាំងអស់ ។

## មាត្រា៨._

អ្នកអភិវឌ្ឍអចលនវត្ថុ ដែលសាងសង់អគារសហកម្មសិទ្ធិត្រូវរៀបចំបទបញ្ជាផ្ទៃក្នុងមួយ មុននឹងប្រកាសលក់ ឬជួលចំណែកឯកជននៃអគារសហកម្មសិទ្ធិ ។

បទបញ្ជាផ្ទៃក្នុងខាងលើនេះ ដែលជាការព្រមព្រៀងរវាងសហកម្មសិទ្ធិករ នៃអគារសហកម្មសិទ្ធិមិនត្រូវផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និងច្បាប់ជាធរមាន ។

ដើម្បីគ្រប់គ្រងអគារសហកម្មសិទ្ធិ សហកម្មសិទ្ធិករអាចបង្កើតក្រុមប្រឹក្សាភិបាល ឬគណៈកម្មការគ្រប់គ្រងអគារសហកម្មសិទ្ធិ តាមការព្រមព្រៀងរវាងសហកម្មសិទ្ធិករ ដូចមានចែងក្នុងបទបញ្ជាផ្ទៃក្នុង ។

ការរៀបចំបទបញ្ជាផ្ទៃក្នុង ត្រូវស្របតាមគោលការណ៍ និងលក្ខខណ្ឌអប្បបរមានៃបទបញ្ជាផ្ទៃក្នុងគំរូ ដែលមានភ្ជាប់ជាឧបសម្ព័ន្ធទី១ នៃអនុក្រឹត្យនេះ ហើយដែលត្រូវចែងជាអាទិ៍ អំពី ÷

- សិទ្ធិ កាតព្វកិច្ច និងការទទួលខុសត្រូវ របស់សហកម្មសិទ្ធិករលើចំណែកឯកជននិងលើចំណែករួមដោយមិនផ្ទុយពីគោលការណ៍កម្មសិទ្ធិ ។
- ការកំណត់ពីសមាមាត្រនៃចំណាយរួមនានា របស់សហកម្មសិទ្ធិករ សម្រាប់ការថែទាំ ការជួសជុល ចំណែករួម ការបង់ថ្លៃលើការប្រើប្រាស់សេវាសាធារណៈនានា ...។ល។
- នីតិវិធីនៃការធ្វើសេចក្តីសម្រេចចិត្ត ក្នុងករណីដែលសហកម្មសិទ្ធិករបង្កើតអង្គការគ្រប់គ្រងអគារសហកម្មសិទ្ធិ ÷

ក) - តម្រូវឱ្យមានសំឡេងគាំទ្រភាគច្រើនដាច់ខាត នៃសហកម្មសិទ្ធិករទាំងអស់ សម្រាប់ការសម្រេចចិត្តពាក់ព័ន្ធនឹងការកែសម្រួលបទបញ្ជាផ្ទៃក្នុង ការជួសជុល ឬការថែទាំអគារសហកម្មសិទ្ធិ ឬការបង់ថ្លៃសេវាសាធារណៈនានា ។

ខ)- តម្រូវឱ្យមានសំឡេងគាំទ្រយ៉ាងតិច ៧៥ (ចិតសិបប្រាំ) ភាគរយ នៃសហកម្មសិទ្ធិករទាំងអស់ សម្រាប់សម្រេចចិត្តក្នុងករណីដែលអគារចាស់ទ្រុឌទ្រោម មិនអាចប្រើប្រាស់បាន ហើយតម្រូវឱ្យរុះរើអគារ ឬសាងសង់អគារជាថ្មី ។ ក្នុងករណីមិនអាចរកការគាំទ្រយ៉ាងតិច៧៥ (ចិតសិបប្រាំ) ភាគរយ បាននោះ ការវាយតម្លៃជាផ្លូវការដោយសមត្ថកិច្ចជំនាញ ត្រូវយកជាមូលដ្ឋានសម្រាប់ការសម្រេចរបស់តុលាការ ។

## មាត្រា៩.-

ការកំណត់ព្រំខណ្ឌនៃចំណែកឯកជន ដែលមានជញ្ជាំងអឡូសិទ្ធិ ត្រូវកំណត់ត្រឹមពាក់កណ្ដាលនៃកម្រាស់ជញ្ជាំងដែលខណ្ឌចំណែកឯកជននីមួយៗ ។

យ៉ ឬរានហាលជាប់ជាមួយចំណែកឯកជន និងប្រើប្រាស់ជាឯកជន ហើយដែលមិនប៉ះពាល់ដល់ការប្រើប្រាស់ជារួមរបស់សហកម្មសិទ្ធិករផ្សេងទៀត ត្រូវចាត់ទុកជាផ្នែកនៃចំណែកឯកជន ។

# ជំពូកទី៣

# សិទ្ធិនិងភារកិច្ចរបស់សហកម្មសិទ្ធិករ

## មាត្រា១០.-

សហកម្មសិទ្ធិករនីមួយៗ មានសិទ្ធិកម្មសិទ្ធិលើចំណែកឯកជនរបស់ខ្លួន លើកលែងតែមានការកម្រិតលក្ខខណ្ឌដោយច្បាប់ ឬបញ្ញត្តិផ្សេងទៀត ។

## មាត្រា១១.-

សហកម្មសិទ្ធិករនៃចំណែកឯកជននៃអគារសហកម្មសិទ្ធិ មានសិទ្ធិចាត់ចែងលើចំណែកឯកជនរបស់ខ្លួនដោយមិនបំពានទៅលើចំណែករួម និងមិនរំខាន ឬរាំងស្ទះដល់ការប្រើប្រាស់ចំណែករួម ដោយសហកម្មសិទ្ធិករដទៃទៀត និងមិនធ្វើឱ្យប៉ះពាល់ដល់ភាពរឹងមាំនៃសំណង់ និងសោភ័ណភាពនៃអគារ ។

សិទ្ធិចាត់ចែងចំណែកឯកជនរបស់សហកម្មសិទ្ធិករ ដូចជា ការលក់ ការដូរ ការជួល ប្រទានកម្ម ការបន្តមរតក ការជួលអចិន្ត្រៃយ៍ ការបង្កើតផលុបភោគ ការប្រើប្រាស់និងអាស្រ័យនៅ ការដាក់ហ៊ីប៉ូតែក និងការដាក់បញ្ចាំត្រូវអនុវត្តតាមនីតិវិធីច្បាប់ជាធរមាន ។

សហកម្មសិទ្ធិករមិនអាចបង្កើតសេវភាព លើចំណែកឯកជនរបស់ខ្លួនបានទេ ។

## មាត្រា១២.-

រាល់ចំណែកនៃអគារ ឬដីសម្រាប់ការប្រើប្រាស់រួម ឬសម្រាប់ជាប្រយោជន៍នៃសហកម្មសិទ្ធិករនៃអគារសហកម្មសិទ្ធិ បង្កើតបានជាចំណែករួម ។ ចំណែករួមមានជាអាទិ៍ ៖

- ដី ទីធ្លា ឧទ្យាន និងសួនច្បារ ផ្លូវ ច្រកចេញចូល
- ជញ្ជាំង សសរទ្រទ្រង់សំខាន់ៗនៃអគារ ឧបករណ៍រួមរាប់បញ្ចូលចំណែកនៃបណ្ដាញទឹក ភ្លើង បណ្ដាញឧស្ម័ន ប្រព័ន្ធលូទឹកស្អុយ ដែលអាចឆ្លងកាត់ចំណែកឯកជន
- ទូរួម បំពង់ និងក្បាលបំពង់ផ្សែង និងដំបូល
- ទីកន្លែងសេវារួមផ្សេងៗដែលបានកំណត់ដោយឡែក ឬមានចែងក្នុងបទបញ្ជាផ្ទៃក្នុង

- សិទ្ធិបន្ទាប់បន្សំទាំងឡាយ ដូចមានចែងក្នុងមាត្រា១៧៩ នៃច្បាប់ភូមិបាល ។

សហកម្មសិទ្ធិករនីមួយៗមានត្រឹមតែសិទ្ធិប្រើប្រាស់តែប៉ុណ្ណោះ លើចំណែករួម ។ គ្មានករណីណាមួយដែលកម្ម-សិទ្ធិករនៃអគារសហកម្មសិទ្ធិជាន់លើបំផុត អាចលើកបន្ថែសម្រាប់តែខ្លួនឯងផ្ទាល់ ឬលក់សិទ្ធិនៃការលើកបន្ថនេះបានឡើយ ។

**មាត្រា១៣.-**

សហកម្មសិទ្ធិករនៃអគារសហកម្មសិទ្ធិ ត្រូវគោរពតាមបទបញ្ជាផ្ទៃក្នុង ដែលកំណត់របៀបគ្រប់គ្រង និងវិធាននៃការថែទាំ ព្រមទាំងការបំពេញកាតព្វកិច្ចផ្សេងៗទៀត ។

**មាត្រា១៤.-**

ចំណែករួមគឺជាកម្មសិទ្ធិអវិភាគរបស់សហកម្មសិទ្ធករ ។ សហកម្មសិទ្ធិករទាំងអស់ត្រូវធានាការថែទាំចំណែករួម ។ បន្ទុកនៃការថែទាំនេះត្រូវចែកគ្នាទៅតាមសមាមាត្រទៅនឹងតម្លៃនៃឡូតិ៍នីមួយៗ លើកលែងតែមានការព្រមព្រៀងគ្នាផ្សេងពីនេះ ឬមានចែងដោយឡែកក្នុងបទបញ្ជាផ្ទៃក្នុង ។

**មាត្រា១៥.-**

សិទ្ធិលើក្បាលដីដែលអគារសហកម្មសិទ្ធិតាំងនៅ ជាសិទ្ធិដែលមិនត្រូវបានបាត់បង់ឡើយ ទោះបីអគារ ឬចំណែកឯកជននោះបានខូចខាតក៏ដោយ ។

ក្នុងករណីដែលអគារសហកម្មសិទ្ធិចុះទ្រុឌទ្រោម មិនអាចស្នាក់នៅបាន ឬទទួលរងមហន្តរាយ ដោយប្រការ ណាមួយ សហកម្មសិទ្ធិករទាំងអស់អាចឯកភាពគ្នាជួសជុល ឬសាងសង់ឡើងវិញ ដោយទទួលបន្ទុកក្នុងការចំណាយតាមសមាមាត្រទៅនឹងតម្លៃនៃឡូតិ៍នីមួយៗ ឬតាមការព្រមព្រៀងគ្នាកន្លងមកដូចជា កិច្ចសន្យាដោយឡែក ឬបទបញ្ជាផ្ទៃក្នុងរបស់អគារសហកម្មសិទ្ធិ ។ កិច្ចសន្យាដោយឡែកត្រូវស្របតាមស្មារតីនៃបទបញ្ជាផ្ទៃក្នុង ។ ការជួសជុល ឬសាងសង់ឡើងវិញ ត្រូវអនុវត្តតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន ។

ប្រសិនបើសហកម្មសិទ្ធិករឯកភាពគ្នាក្នុងការបែងចែកដី ឬលក់ដីដែលអគារសហកម្មសិទ្ធិនោះស្ថិតនៅការបែងចែកត្រូវអនុវត្តតាមគោលការណ៍សមាមាត្រទៅនឹងតម្លៃនៃឡូតិ៍នីមួយៗ ឬតាមការព្រមព្រៀងគ្នា ពីមុនមក ប្រសិនបើមានចែងនៅក្នុងកិច្ចសន្យាដោយឡែក ឬបទបញ្ជា ផ្ទៃក្នុងរបស់អគារសហកម្មសិទ្ធិ ។

ប្រសិនបើអ្នកអភិវឌ្ឍអចលនវត្ថុ បានសាងសង់អគារសហកម្មសិទ្ធិលើដីជួលពីបុគ្គលទីបី នោះអាជ្ញាយុកាលនៃសិទ្ធិជួលអចិន្ត្រៃយ៍លើចំណែកឯកជន និងសិទ្ធិប្រើប្រាស់លើចំណែករួម មានត្រឹមតែរយៈពេល ដូចបានកំណត់ក្នុងកិច្ចសន្យាជួលដីអចិន្ត្រៃយ៍ រវាងអ្នកអភិវឌ្ឍអចលនវត្ថុ និងម្ចាស់ដីប៉ុណ្ណោះ ។ វិញ្ញាបនបត្រសម្គាល់សិទ្ធិជួលអចិន្ត្រៃយ៍មានភ្ជាប់ជាឧបសម្ព័ន្ធទី៣ នៃអនុក្រឹត្យនេះ ។

## ជំពូកទី៤

## យន្តការនិងនីតិវិធីនៃការចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិ

**មាត្រា១៦.-**

ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ មានសមត្ថកិច្ចធ្វើការចុះបញ្ជី និងចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់ចំណែកឯកជននៃអគារសហកម្មសិទ្ធិ ជូនសហកម្មសិទ្ធិករទាំងអស់តាមនីតិវិធី ដូចមានចែងក្នុងអនុក្រឹត្យនេះ ។

មានតែអគារសហកម្មសិទ្ធិដែលបានសាងសង់រួចរាល់ស្របគ្រប់ តាមច្បាប់និងបទប្បញ្ញត្តិជាធរមានប៉ុណ្ណោះ ទើបអាចជាកម្មវត្ថុនៃការចុះបញ្ជីចំណែកឯកជនបាន។

**មាត្រា១៧._**

ការចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិ ត្រូវដំណើរការដូចតទៅ ៖

១- សហកម្មសិទ្ធិករចំណែកឯកជននៃអគារសហកម្មសិទ្ធិ ត្រូវស្នើសុំចុះបញ្ជីចំណែកឯកជនរបស់ខ្លួន នៅរដ្ឋបាលសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ។

សហកម្មសិទ្ធិករត្រូវបំពេញពាក្យស្នើសុំចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិ ដោយបញ្ជាក់ច្បាស់អំពីអត្តសញ្ញាណ និងព័ត៌មានទាំងឡាយនៃចំណែកឯកជនរបស់ខ្លួន ឱ្យបានត្រឹមត្រូវនិងត្រូវភ្ជាប់ មកជាមួយនូវ ៖

- វិញ្ញាបនបត្របញ្ជាក់ភាពត្រឹមត្រូវនៃសំណង់ ឬលិខិតបិទការដ្ឋានសំណង់
- ឯកសារប្លង់ស្ថាបត្យកម្មលម្អិតនៃអគារសហកម្មសិទ្ធិ ដោយបញ្ជាក់ពីចំនួនជាន់ ចំនួនចំណែកឯកជន ដោយមានលេខយោងនិងព័ត៌មានអំពីចំណែករួមនៃអគារ
- បទបញ្ជាផ្ទៃក្នុង
- ឯកសារបញ្ជាក់អត្តសញ្ញាណសហកម្មសិទ្ធិករ
- ឯកសារពាក់ព័ន្ធផ្សេងទៀត ប្រសិនបើមាន។

២- ពាក្យស្នើសុំត្រូវយកទៅដាក់នៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ក្រុង ស្រុក ខណ្ឌ ដែលអគារសហកម្មសិទ្ធិនោះស្ថិតនៅ ។ មន្ត្រីទទួលពាក្យត្រូវចេញបង្កាន់ដៃទទួលពាក្យជូនអ្នកស្នើសុំ ។

៣- ក្រោយពេលទទួលពាក្យស្នើសុំចុះបញ្ជី ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ក្រុង ស្រុក ខណ្ឌ ត្រូវពិនិត្យទម្រង់និងឯកសារភ្ជាប់ឱ្យបានត្រឹមត្រូវ ហើយបញ្ជូនពាក្យស្នើសុំចុះបញ្ជីនេះទៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់និងសុរិយោដី រាជធានី ខេត្ត ក្នុងរយៈពេល៣ (បី) ថ្ងៃ នៃថ្ងៃធ្វើការយ៉ាងយូរ ដើម្បីពិនិត្យនិងសម្រេចឱ្យអនុវត្តដំណើរការចុះបញ្ជី ។

៤- មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់និងសុរិយោដីរាជធានី ខេត្ត ត្រូវពិនិត្យសម្រេច ក្នុងរយៈពេល ៣ (បី) ថ្ងៃ នៃថ្ងៃធ្វើការ លើពាក្យស្នើសុំចុះបញ្ជីនេះ ។

៥- ក្រោយពីមន្ទីរសម្រេចឱ្យអនុវត្តដំណើរការចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិ ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ ត្រូវធ្វើការជូនដំណឹងរយៈពេល១ (មួយ) សប្តាហ៍ មុនកាលបរិច្ឆេទនៃការចុះប្រមូលទិន្នន័យ ។

៦- មន្ត្រីជំនាញនៃការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ ក្នុងរយៈ ពេល១ (មួយ) សប្តាហ៍យ៉ាងយូរ ត្រូវចុះសហការជាមួយមន្ត្រីឃុំ សង្កាត់ អ្នកអភិវឌ្ឍអចលនវត្ថុ ឬតំណាង និងសហកម្មសិទ្ធិករ ដើម្បីប្រមូលនិងផ្ទៀងផ្ទាត់ទិន្នន័យ នៅទីតាំងជាក់ស្តែង ដើម្បីបំពេញទម្រង់បែបបទប្រមូលទិន្នន័យ ។

៧- ក្រោយប្រមូលទិន្នន័យជាក់ស្តែងអំពីចំណែកឯកជននៃអគារសហកម្មសិទ្ធិរួច មន្ត្រីជំនាញនៃការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ ត្រូវបញ្ជូនសំណុំឯកសារទាំងអស់ និងលើកយោបល់ក្នុងរយៈពេល ១ (មួយ) សប្តាហ៍ មកមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ដើម្បីពិនិត្យនិងសម្រេចឱ្យបិទផ្សាយទិន្នន័យជាសាធារណៈ ។

ប្រសិនបើមានភាពមិនច្បាស់លាស់ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានី ខេត្ត អាចស្វែងរកព័ត៌មានបន្ថែម ឬចាត់តាំងមន្ត្រីជំនាញដើម្បីចុះស៊ើបអង្កេត ឬបញ្ជាក់បន្ថែមក្នុងរយៈពេល១ (មួយ) សប្តាហ៍យ៉ាងយូរ។

៨- ក្រោយពីមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត បានសម្រេចឱ្យបិទផ្សាយជាសាធារណៈនូវទិន្នន័យដែលប្រមូលបានរួចហើយ ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ក្រុង ស្រុក ខណ្ឌ ត្រូវបិទផ្សាយជាសាធារណៈ នូវលទ្ធផលនៃការប្រមូលទិន្នន័យរយៈពេល១ (មួយ) សប្តាហ៍ ដើម្បីឱ្យសហកម្មសិទ្ធិករទាំងអស់និងអ្នកមានផលប្រយោជន៍ អាចតវ៉ាឬស្នើធ្វើការកែតម្រូវ ។ ការបិទផ្សាយជាសាធារណៈត្រូវអនុវត្តនៅទីតាំងអចលនវត្ថុផ្ទាល់ និងនៅសាលាឃុំ សង្កាត់ ដែលអចលនវត្ថុនោះស្ថិតនៅ ។

ក្នុងករណីមានការតវ៉ា ឬវិវាទ ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ក្រុង ស្រុក ខណ្ឌ ត្រូវព្យាយាមសម្រុះសម្រួលស្វែងរកការឯកភាពគ្នា ។

ក្នុងករណីមិនអាចរកការស្រុះស្រួលគ្នាបាន ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ ត្រូវបញ្ជូនករណីវិវាទនេះទៅតុលាការ ដើម្បីដោះស្រាយតាមនីតិវិធីច្បាប់ជាធរមាន ។

៩- ផុតរយៈពេលនៃការបិទផ្សាយប្រសិនបើគ្មានបណ្តឹងតវ៉ា ឬប្រសិនបើរាល់វិវាទត្រូវបានដោះស្រាយរួចរាល់ហើយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានី ខេត្ត ត្រូវធ្វើការចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិ តាមការស្នើសុំរបស់សហកម្មសិទ្ធិករក្នុងរយៈពេល ១ (មួយ) សប្តាហ៍យ៉ាងយូរ ។

## មាត្រា១៨.-

ចំណែកឯកជននីមួយៗ ត្រូវចុះបញ្ជីក្នុងសៀវភៅគោលបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិ ។ ក្នុងសៀវភៅគោលបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិ ត្រូវកត់ត្រាទិន្នន័យលម្អិតអំពីចំណែកឯកជន និងម្ចាស់កម្មសិទ្ធិនៃចំណែកឯកជន ដោយមានបញ្ជាក់ជាអាទិ៍ ឈ្មោះសហកម្មសិទ្ធិករ ទំហំ ទីតាំង ប្រភេទ ទ្រព្យនៃចំណែកឯកជន។ សៀវភៅគោលបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិ និងទម្រង់បែបបទផ្សេងទៀត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

## មាត្រា១៩.-

វិញ្ញាបនបត្រសម្គាល់ម្ចាស់ចំណែកឯកជន ដែលត្រូវបានចេញជូនសហកម្មសិទ្ធិករ តាមការស្នើសុំ ត្រូវកត់ត្រាទិន្នន័យដែលមានជាអាទិ៍ លេខយោងសម្គាល់ចំណែកឯកជន ទំហំ ទីតាំង ប្រភេទទ្រព្យ នៃចំណែកឯកជន ។ គំរូវិញ្ញាបនបត្រសម្គាល់ម្ចាស់ចំណែកឯកជននៃអគារសហកម្មសិទ្ធិ មានភ្ជាប់ជាឧបសម្ព័ន្ធទី២នៃអនុក្រឹត្យនេះ ។ រដ្ឋបាលសុរិយោដីត្រូវរៀបចំកម្មវិធីកុំព្យូទ័រ សម្រាប់បញ្ចូលទិន្នន័យចំណែកឯកជននៃអគារសហកម្មសិទ្ធិ នៅក្នុងប្រព័ន្ធព័ត៌មានវិទ្យា ដើម្បីរក្សាទុកជាឯកសារ ។

## មាត្រា២០.-

រាល់ការផ្ទេរសិទ្ធិតាមរយៈការលក់ ការដូរ ប្រទានកម្ម និងការបន្តមរតក សហកម្មសិទ្ធិករឬអ្នកទទួលសិទ្ធិត្រូវស្នើធ្វើចរន្តការនូវរាល់ការប្រែប្រួលនោះ នៅរដ្ឋបាលសុរិយោដី ។ កិច្ចប្រតិបត្តិការក្នុងការផ្ទេរសិទ្ធិនេះ ត្រូវប្រើរយៈពេល២០ (ម្ភៃ) ថ្ងៃ នៃថ្ងៃធ្វើការយ៉ាងយូរ ។ អ្នកទទួលសិទ្ធិបន្តមានសិទ្ធិ និងកាតព្វកិច្ច ដូចសហកម្មសិទ្ធិករមុនៗដែរ ។

រាល់ការដាក់ហ៊ីប៉ូតែក ការដាក់បញ្ចាំ និងការជួលអចិន្ត្រៃយ៍នូវចំណែកឯកជនរបស់ខ្លួន សហកម្មសិទ្ធិករ និងអ្នកពាក់ព័ន្ធត្រូវទៅធ្វើលេខាចារិកលើវិញ្ញាបនបត្រសម្គាល់ ម្ចាស់ចំណែកឯកជននោះនៅរដ្ឋបាលសុរិយោដី ។

## មាត្រា២១.-

រាល់ការផ្លាស់ប្តូរប្រភេទក្បាលដីដើម មកជាក្បាលដីសហកម្មសិទ្ធិ ដូចមានចែងក្នុងមាត្រា៧ នៃអនុក្រឹត្យនេះ ត្រូវបង់ថ្លៃសេវាសុរិយោដី ។

រាល់ការបំបែកក្បាលដីទៅតាមប្រភេទនិង/ឬចំនួនអគារសហកម្មសិទ្ធិ ដូចមានចែងក្នុងមាត្រា៧ នៃអនុក្រឹត្យនេះ ត្រូវបង់ថ្លៃសេវាសុរិយោដី ។

រាល់ការផ្ទេរសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិ ត្រូវបង់ថ្លៃសេវាសុរិយោដី និងបង់ពន្ធប្រថាប់ត្រាជូនរដ្ឋតាមច្បាប់កំណត់ ។

# ជំពូកទី៥

# អន្តរប្បញ្ញត្តិ

## មាត្រា២២.-

ចំពោះប្រភេទអគារសហកម្មសិទ្ធិ ដែលបានសាងសង់មុនថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧ ហើយដែលមានសហកម្មសិទ្ធិករច្រើននាក់រស់នៅ ការស្នើសុំចុះបញ្ជីចំណែកឯកជន ពុំតម្រូវឱ្យមានវិញ្ញាបនបត្របញ្ជាក់ភាពត្រឹមត្រូវនៃសំណង់ ឬលិខិតបិទការដ្ឋានសំណង់ និងឯកសារប្លង់ស្ថាបត្យកម្មលម្អិតនៃអគារសហកម្មសិទ្ធិ ដូចមានចែងក្នុងមាត្រា១៧ ចំណុចទី១ ឡើយ ។

ចំពោះប្រភេទអគារសហកម្មសិទ្ធិ ដែលបានសាងសង់ក្រោយថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧ រហូតដល់អនុក្រឹត្យនេះចូលជាធរមាន ហើយដែលអគារសហកម្មសិទ្ធិនោះ ពុំមានលិខិតអនុញ្ញាតសាងសង់ ការស្នើសុំចុះបញ្ជីចំណែកឯកជនតម្រូវឱ្យធ្វើនិយតកម្មលើប្លង់ស្ថាបត្យកម្ម នៃអគារសហកម្មសិទ្ធិជាមុនសិន ។

## មាត្រា២៣.-

ចំពោះប្រភេទអគារសហកម្មសិទ្ធិដែលបានសាងសង់មុនអនុក្រឹត្យនេះចូលជាធរមាន ការស្នើសុំចុះបញ្ជីចំណែកឯកជនតម្រូវឱ្យសហកម្មសិទ្ធិករទាំងអស់រៀបចំបទបញ្ជាផ្ទៃក្នុងជាមុនសិន ស្របតាមខ្លឹមសារអប្បបរមា ដូចមានចែងក្នុងឧបសម្ព័ន្ធទី១នៃអនុក្រឹត្យនេះ។ ក្នុងករណីដែលសហកម្មសិទ្ធិករមិនអាចស្រុះស្រួលគ្នាក្នុងការរៀបចំបទបញ្ជាផ្ទៃក្នុងទេ ការស្នើសុំចុះបញ្ជីចំណែកឯកជននឹងត្រូវកំណត់ដោយបទដ្ឋានដោយឡែក ។

## មាត្រា២៤.-

ចំពោះអគារជាភូមិគ្រឹះ ពាក់កណ្តាលភូមិគ្រឹះ ឬជាផ្ទះល្វែងដែលមានច្រើនល្វែង និងច្រើនជាន់ជាប់គ្នា ហើយមានម្ចាស់ជាកម្មសិទ្ធិករតែម្នាក់ ហើយដែលមានបំណងផ្ទេរចំណែកឯកជនណាមួយនៃអគារទៅឱ្យបុគ្គលដទៃ ការចុះបញ្ជីចំណែកឯកជនត្រូវអនុលោមតាមស្មារតីនៃអនុក្រឹត្យនេះ លើកលែងតែករណីដែលការផ្ទេរនេះអនុវត្តទៅលើផ្ទះល្វែងមួយជង់ពីលើដល់ក្រោមទៅឱ្យបុគ្គលតែមួយ ។ ការផ្ទេរចុងក្រោយនេះ ត្រូវអនុវត្តតាមនីតិវិធីដែលមានកន្លងមក ។

# ជំពូកទី៦

# ទោសប្បញ្ញត្តិ

**មាត្រា២៥.-**

សហកម្មសិទ្ធិករ ដែលធ្វើឱ្យប៉ះពាល់ចំណែករួមនៃអគារ ឬដីដោយបានកែប្រែដើម្បីការប្រើប្រាស់ជាឯកជន ឬសម្រាប់លក់ នឹងត្រូវបង្ខំឱ្យរៀបចំដូចសភាពដើមវិញ ។ សហកម្មសិទ្ធិករនោះនឹងត្រូវទទួលទណ្ឌកម្ម ដូចមានចែងក្នុងមាត្រា២៥៧ នៃច្បាប់ភូមិបាល ។

សហកម្មសិទ្ធិករដែលមិនព្រមចូលរួមទទួលបន្ទុកថែទាំចំណែករួម ឬមិនបានគោរពតាមលក្ខខណ្ឌនៃសណ្ដាប់ធ្នាប់សាធារណៈ ត្រូវទទួលទណ្ឌកម្ម ដូចមានចែងក្នុងមាត្រា ២៥៨ នៃច្បាប់ភូមិបាល ។

## ជំពូកទី៧

## អវសានប្បញ្ញត្តិ

**មាត្រា២៦.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា២៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន អភិបាលរាជធានី គ្រប់អភិបាលខេត្តត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល** :

- ក្រសួងព្រះបរមរាជវាំង
